អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Jul-2012, 16:10
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០១២**

**ម៉ោង ០៩:០១ នាទី**

**សវនាការលើកទី៨០**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក អេនឌ្រូ ចេមស៍ ម៉ាគីនថាយអ៊ឺរ
*(Mr. Andrew James MCINTYRE)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក ច័ន្ទ តារាស្មី

កញ្ញា សុង ឆវ័ន្ត

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក សាលីម ណាកចាវ៉ានី
*(Mr. Salim NAKHJAVANI)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោក អាកទួរ វែកគែន

*(Mr. Arthur VERCKEN)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រ៊ីនណា

លោក ហុង គឹមសួន

លោក សំ សុគង់

លោក ឡោ ជុនធី

លោក វ៉ែន ពៅ

លោកស្រី ជេត វណ្ណលី

លោក អូលីវីយេ បាហ៊ូញ

*(Mr. Olivior BAHOUGNE)*

លោកស្រី គ្រីស្ទីន ម៉ាទីណូ

*(Ms. Chritine MARTINAU)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណា

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្វ៊ី | អង់គ្លេស |
| លោក ថារីក អាប់ឌុលឡាក់ | អង់គ្លេស |
| លោក ហ្សាស្តេី ប៉ៅ | អង់គ្លេស |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក តុង ហុង (វេជ្ជបណ្ឌិត) | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ដេវីដ ឆេនដ័ល័រ (TCE-11) | អង់គ្លេស |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅអ្នកជំនាញ÷ លោក ដេវីដ ឆេនដ៏ល័រ** (TCE-11)
សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក ផ្តើមពី៖..........................................................ទំព័រ១៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០១:០១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ដែលតាមកាលវិភាគបានគ្រោងទុកគឺនៅថ្ងៃនេះ បន្តនីតិវិធីពិភាក្សាដេញដោលដោយ -- តាំងសំណួរចំពោះអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ដោយក្រុមតំណាងសហព្រះរាជអាជ្ញា។

ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាននិងអវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ។

លោកស្រី សែ កុលវុឌ្ឍី!

[០៩:០២:០៤]

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះមុននឹងផ្តល់វេទិកាជូនទៅក្រុមតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ អង្គជំនុំជម្រះសម្រេចលើសំណើសុំចំនួនពីរ ទីមួយ គឺសំណើសុំដាក់ឯកសាររបស់ក្រុមមេធាវីការពារក្តី នួន ជា ហើយនិងទីពីរ គឺសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ពាក់ព័ន្ធនឹងសុំមិនឲ្យអង្គជំនុំជម្រះធ្វើសវនាការនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី២០ ខែកក្កដា ឆ្នាំ២០១២។

ទីមួយ សេចក្តីសម្រេចផ្ទាល់មាត់ទាក់ទងទៅនឹងសំណើសុំដាក់ឯកសាររបស់ក្រុមមេធាវីការពារក្តី នួន ជា។ អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើលើកទីពីររបស់ក្រុមមេធាវីការពារក្តី នួន ជា តាមវិធាន៨៧ អនុវិធាន៤ នៃវិធានផ្ទៃក្នុង។ សុំការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីប្រើប្រាស់ឯកសារថ្មីសម្រាប់សួរដេញដោលអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ឯកសារ E172/27/2។ នៅក្នុងសំណើនេះ មេធាវីការពារក្តី នួន ជា សុំដាក់ឯកសារថ្មីចំនួន១១ នៅចំពោះមុខអង្គជំនុំជម្រះ ផ្អែកលើមូលដ្ឋាននៃសំណើសុំ

ទីមួយរបស់ខ្លួនតាមវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង។ ឯកសារ E172/21/1។ ដោយផ្អែកលើមូលដ្ឋានដដែលដូចដែលបានសម្រេចកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១២ អង្គជំនុំជម្រះសម្រេចបដិសេធនូវសំណើសុំរបស់មេធាវីការពារក្តី នួន ជា។

[០៩:០៤:១០]

ឯសេចក្តីសម្រេចទីពីរ លើសំណើសុំរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ខ្ញុំជាប្រធានអង្គជំនុំជម្រះក្នុងនាមអង្គជំនុំជម្រះសូមប្រគល់ភារកិច្ចជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបង្ហាញអំពីហេតុផល និងសម្រេចលើសំណើសុំនេះ។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះបានពិភាក្សាសម្រេចលើសំណើធ្វើឡើងដោយមេធាវីការពារក្តីលោក អៀង សារី គឺលោក កាណាវ៉ាស ហើយបានសម្រេចបដិសេធសំណើនោះ គឺមូលហេតុគឺដូចខាងក្រោមនេះ គឺសំណើនោះគឺថាសុំកុំឲ្យសវនាការបើកសវនាការនៅថ្ងៃសុក្រ នៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១២ ដោយសារថាមានលក្ខខណ្ឌមុន ដែលលោក កាណាវ៉ាស គាត់បានសន្យាថានឹងធ្វើការងាររបស់គាត់ចូលរួមនៅ -- ហើយនិងដឹកនាំសិក្ខាសាលាមួយ។ មូលហេតុនៃការបដិសេធសំណើនេះគឺដូចខាងក្រោមនេះ៖

[០៩:០៥:១៧]

១) ភាគីបានដឹងរួចស្រេចហើយចាប់តាំងពីសវនាការដំបូងមកថា ទោះបីជាអង្គជំនុំជម្រះធានាថាទុកថ្ងៃសុក្រសម្រាប់ការងារផ្សេងក៏ដោយ ភាគីត្រូវតែមានភាពបត់បែនបាន ដែលអាចចូលរួមសវនាការនៅថ្ងៃនោះ។ នេះជាមូលហេតុមួយ នេះជាសប្តាហ៍មួយដែលយើងបានបាត់បង់ពីរថ្ងៃសម្រាប់សវនាការទៅហើយ ហើយនៅក្នុងសំណើម្សិលមិញលោក កាណាវ៉ាស បានៗធ្វើការវិភាគមួយទាក់ទងនឹងសំណើដែលធ្វើឡើងដោយសហព្រះរាជអាជ្ញា សូមការពន្យារពេលពីរថ្ងៃចាប់ពីដើមសប្តាហ៍មក ដោយសារថាគាត់មានជំងឺ សហព្រះរាជអាជ្ញាមានជំងឺមួយរូបនោះ ហើយគាត់បាន -- ត្រូវបានចាត់តាំងដើម្បីសួរសំណួរ ប៉ុន្តែគាត់ឈឺ។

[០៩:០៦:១៨]

ហើយលោក កាណាវ៉ាស បានបញ្ជាក់ថា ប្រសិនបើផ្តល់ការអនុញ្ញាតដល់សហព្រះរាជអាជ្ញាក៏

ត្រូវផ្តល់ឲ្យមេធាវីការពារផងដែរ។ ដូច្នេះ ការប្រៀបធៀបនេះមិនសមស្របទេ ស្ថានភាពពីរខុសគ្នា។ សហព្រះរាជអាជ្ញាមិនបានដឹងជាមុនថា ខ្លួនមានជំងឺទេ។ ជាពិសេសគឺដោយសារគាត់មានជំងឺបានគាត់សូមពន្យារពេល។ ហើយដូចដែលយើងបានដឹងពីម្សិលមិញ គឺសហព្រះរាជអាជ្ញាបានទទួលការរិះគន់ដោយថា មិនបានដាក់ជំនួសនូវជំហរដែលថា រឹងមាំដើម្បីបន្ត។ ដោយសារថា ទោះបីជាមានគ្រាអាសន្នដោយសារជំងឺហ្នឹងក៏ដោយ។ ហើយមិនមានស្ថានភាពជាក់លាក់ទាក់ទងទៅនឹងសំណើដែលលើកឡើងដោយលោក កាណាវាស នោះទេ។ គាត់បានដឹងអំពីការប្តេជ្ញារបស់គាត់ ដែលគាត់បានធ្វើសម្រាប់ថ្ងៃសុក្រ ហើយគាត់បានដឹងគឺថា ពេលខ្លះអង្គជំនុំជម្រះអាចនឹងបើកសវនាការ។ គាត់គួរតែបានដឹងជាមុនថា លទ្ធភាពមួយដែលតុលាការនឹងត្រូវបើកសវនាការថ្ងៃសុក្រ ហើយគាត់អាចដាក់អ្នកជំនួសគាត់ បើគាត់អវត្តមាន។ នៅក្នុងករណីក៏ដោយ គាត់មានមេធាវីជាតិដែលមានសមត្ថភាពដែលអាចនឹងចូលរួមតំណាងលោក អៀង សារី បាននៅថ្ងៃស្អែកនេះ។

[០៩:០៧:៤៧]

នៅទីបំផុត អង្គជំនុំជម្រះបានពិចារណាអំពីអវត្តមានរបស់លោក កាណាវាស សម្រាប់ថ្ងៃស្អែក ហើយយើងថា ការសួរសំណួរដោយមេធាវី ក្រុមមេធាវីរបស់លោក អៀង សារី គឺមិនត្រូវបានសួរទេ រហូតដល់ថ្ងៃចន្ទ អាទិត្យក្រោយឯណោះបានគាត់មានឱកាសសួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី! តើលោកមានបញ្ហាអីទៅ? សូមលោកបង្ហាញនូវប្រធានបទដែលលោកមានបំណងនិយាយមុន។

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា មុន ព្រោះគាត់សូមមុន។

សូមអញ្ជើញ!

[០៩:០៨:៣១]

**លោក អេនឌ្រូ អ៊ីអនូហ្ស៊ី៖**

សូមជម្រាបសួរលោកប្រធាន លោក លោកស្រីចៅក្រម ដោយមូលហេតុដដែល ខ្ញុំបញ្ជាក់ពីម្សិលមិញ ហើយខ្ញុំប៉ុនប៉ងនឹងលើកឡើងគឺ ទាក់ទងទៅនឹងការលើកលែងវិធានដែលបានអាន ជាពិសេសគឺការស្នើសុំដាក់ឯកសាររបស់ខ្ញុំ គឺថាជាឯកសារនឹងពាក់ព័ន្ធ ហើយជាឯកសារសាធារណៈហើយតុលាការគប្បីតែអនុញ្ញាតឲ្យយើងខ្ញុំយកមកប្រើប្រាស់ ដើម្បីជាអត្ថប្រយោជន៍ដើម្បីស្វែងរកការពិតបាទ។

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំចង់បញ្ជាក់ជូនលោកឲ្យច្បាស់ថា ក្រុមមេធាវីការពារ នួន ជា ហើយនិងក្រុមមេធាវីផ្សេងទៀតដែរ មានសិទ្ធិក្នុងការប្ដឹងសាទុក្ខនឹងសេចក្ដីសម្រេច ហើយអង្គជំនុំជម្រះគឺមិនយល់ថា មានភាពចាំបាច់ដើម្បីឲ្យមេធាវីជំទាស់ ដើម្បីកត់ត្រាតុលាការទេ ហើយលោកមានសិទ្ធិតាមវិធានគឺថា ប្ដឹងឧទ្ធរណ៍នឹងសេចក្ដីសម្រេចតាមវិធានផ្ទៃក្នុងនៅពេលដែលចេញសេចក្ដីសម្រេច ឬក៏បណ្ដឹងសាទុក្ខភ្លាមៗ។ ហើយលោកមិនចាំបាច់ជំទាស់ទៅលើការសម្រេចសេចក្ដីសម្រេចភ្លាមៗ ដើម្បីកំណត់ត្រាតុលាការ។

លោក អ៊ីនូហ្វ៊ី គឺថាលោកជ្រាបហើយ។

[០៩:០៩:៤៦]

**លោក អេនគ្រូ អ៊ីនូហ្វ៊ី៖**

នេះហើយគឺជាការទម្លាប់របស់ខ្ញុំ ដើម្បីឲ្យសាធារណជនបានដឹង ដើម្បីកំណត់ត្រាតុលាការថា យើងនឹងប្ដឹងឧទ្ធរណ៍។

[០៩:០៩:៥៦]

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៌៖**

យើងមិនតម្រូវឲ្យលោកធ្វើដូច្នោះទេ ប្រហែលជាទម្លាប់អនុវត្តថ្នាក់ជាតិរបស់ ប៉ុន្តែមិនមែននៅទីនេះទេ នេះជាពេលដែលតុលាការធ្វើសេចក្ដីសម្រេច។ បើថាលោកមិនពេញចិត្ត លោកអាចចាត់ថាត្រូវប្ដឹងឧទ្ធរណ៍ ឬមិនប្ដឹងឧទ្ធរណ៍។ ហើយមិនចាំបាច់បញ្ជាក់ថាលោកនឹងប្ដឹងសាទុក្ខ ឬក៏ជំទាស់ទៅនឹងសេចក្ដីសម្រេចទេ។ ហើយនៅថ្ងៃអនាគតលោកមិនបាច់ធ្វើដូច្នេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមជម្រាបសួរលោក លោកស្រីចៅក្រម លោកប្រធាន ហើយនិងសាធារណជនទាំងអស់។ ខ្ញុំមានបញ្ហាបី។ ទីមួយ គឺវត្តមានរបស់លោក អៀង សារី សុខភាពរបស់គាត់។ ទីពីរ គឺថាប្រាស្រ័យទាក់ទងរវាងសហព្រះរាជអាជ្ញានិងលោក ឆេនដ័ល័រ ក្រោយពីបិទសវនាការម្សិលមិញ។ ហើយទីមួយ យើងចង់ដឹងថា តើអ្វីជាឯកសារពិតប្រាកដដែលលោក ឆេនដ័ល័រ បានពិនិត្យនៅយប់មិញនេះ ហើយ

ដែលថាយើងនឹងដាក់សំណើ ហើយគាត់យល់ ហើយគាត់បានស្បថ ហើយគាត់ត្រូវតែបានរៀបចំជាស្រេច គឺថាមិនបាច់ត្រៀមអ្វីទៀតទេ។

[០៩:១១:០៧]

ហើយបើសិនជាមានការណែនាំឲ្យគាត់តាមដានពិនិត្យឯកសារឡើងវិញទាំងអស់នោះ ដើម្បីត្រៀមរៀបចំធ្វើសក្ខីកម្ម ដូចអ្វីដែលយើងបានដឹងម្សិលមិញនោះ គាត់មានចេតនា ហើយគាត់បានធ្វើពីអ្វីៗដែលតុលាការបានណែនាំគាត់នោះ គាត់មិនគោរពតាម។ នេះហើយជាចំណុចសំខាន់បីដែលខ្ញុំ -- ទីមួយលោក អៀង សារី គាត់មានសុខភាពមួយ។ លោក អៀង សារី ប្រាប់ខ្ញុំថាគាត់មិនមានលទ្ធភាពនៅអង្គុយនៅទីនេះក្នុងរយៈពេលយូរទេ គឺថាមួយព្រឹកពេញក៏មិនបានផង។ មិនអាស្រ័យតែលើឆ្អឹងខ្នងរបស់គាត់ទេ ប៉ុន្តែសុខភាពផ្សេងៗទៀត គឺថាគាត់អាចអង្គុយបានតែ ១០មីនុត តែប៉ុណ្ណឹងទេ។ ក្រោយមកគឺគាត់អស់កម្លាំងហើយ។ ហើយគាត់ប៉ុនប៉ងជួបជាមួយវេជ្ជបណ្ឌិត ដើម្បីបានមតិខាងវេជ្ជសាស្ត្រ។ ដោយក្តីរន្ធត់នោះ គឺការអនុវត្តនៅកម្ពុជា ខ្ញុំមិនបានដឹងថានៅទីផ្សេងនៅក្នុងពិភពលោកបានធ្វើបែបនេះទេ។

[០៩:១២:០៧]

វេជ្ជបណ្ឌិតមិនមានឆន្ទៈក្នុងការពន្យល់ឲ្យយើងដឹងថា តើៗលោក អៀង សារី មានបញ្ហាអ្វីក្នុងសុខភាព។ គឺថាគាត់ជូនតែរបាយការណ៍លាយលក្ខណ៍អក្សរទៅអង្គជំនុំជម្រះ ហើយគឺជាទម្លាប់បែបនេះ។ ហើយក៏ទុកឲ្យយើងខ្ញុំ -- ហើយឲ្យខ្ញុំការពារកូនក្តីរបស់ខ្ញុំ។ ដោយសារថា យើងមានស្ថានភាពបែបនេះ យើងខ្ញុំស្នើសុំឲ្យវេជ្ជបណ្ឌិតឆ្លើយ តើអ្វីជាបញ្ហាពិតប្រាកដ? តើគាត់មានជំហរពិតប្រាកដខាងវេជ្ជសាស្ត្រយ៉ាងដូចម្តេចទាក់ទងនឹងលោក អៀង សារី? ចំពោះវត្តមានរបស់គាត់នៅទីនេះ គឺថាសក្ខីកម្មពីបន្ទប់ខាងក្រោមនោះគឺថាយើងអាចទទួលការណែនាំបាន ក៏ប៉ុន្តែយើងគិតថាការដែលឲ្យយើង -- គឺថាគាត់ទៅបន្ទប់ទឹករៀងរាល់ ៥នាទីម្តង ឬក៏គាត់ឈឺខ្នងបែបនេះ គឺថាគាត់មានការរំខាន គាត់មិនអាចចូលរួមដោយមានប្រសិទ្ធភាពបានទេ។

[០៩:១៣:១៤]

មួយទៀតគឺការទាក់ទងដោយគ្មានការចូលរួមរបស់ភាគីខាងយើងហ្នឹង គឺថាការចរចារវាងសហព្រះរាជអាជ្ញាជាមួយលោក ដេវីដ ឆេនដ័ល័រ គឺថាវាបង្ហាញថា លោក ឆេនដ័ល័រ អាចនឹងចាប់ផ្តើមការសន្ទនា។ ខ្ញុំមិនបានដឹងពីអ្វីទេ។ ប៉ុន្តែខ្ញុំបានឃើញថា គាត់បានធ្វើការពិភាក្សាតែពីរភាគីបែបនេះ។ ហើយការសន្ទនាបែបនោះត្រូវបានច្បាប់ហាមឃាត់។ ដើម្បីសាក្សីមួយរូបដែលថាយល់ ហើយក៏គាត់

មានទំនងជាមួយសហព្រះរាជអាជ្ញា ហើយលោក ឆេនដ៍ល័រ គឺជាកូនប្រុសរបស់មេធាវី។ គាត់ដឹង ហើយ គឺថាសហព្រះរាជអាជ្ញាហើយនិងមេធាវីក៏គប្បីថា -- ត្រូវដឹងថាកាលណាសាក្សីមកធ្វើសក្ខីកម្ម មិនមានទំនាក់ទំនងការសន្ទនាអ្វីជាមួយភាគីណាមួយនោះទេ។ ខ្ញុំ -- សហព្រះរាជអាជ្ញាបានដឹងថាគ្រាន់តែដើម្បីការកំណត់កាលវិភាគតែប៉ុណ្ណឹង។

[០៩:១៤:០៦]

ខ្ញុំមិនខ្វល់ខ្វាយថានិយាយអំពីអ្វីទេ ប៉ុន្តែបញ្ហាគឺថាលោក ឆេនដ៍ល័រ ត្រូវប្រាប់ថា ខ្ញុំអាចនិយាយជាមួយភាគីណាមួយជាឯកជនបែបនេះទេ ដែលអាចនាំឲ្យអ្នកផ្សេងទៀតយល់ច្រឡំថា អាចនឹងពិភាក្សាការសម្ងាត់។ នេះគឺជាការណែនាំតុលាការដែលត្រឹមត្រូវតាមច្បាប់។ នេះហើយគឺជាចំណុចដែលថា មិនត្រូវធ្វើ ដូច្នេះហើយខ្ញុំចាត់ទុកបញ្ហានេះជាបញ្ហាធ្ងន់ធ្ងរណាស់ ហើយតុលាការជ្រាបហើយមិនមែនជាដើមបណ្តឹងរដ្ឋប្បវេណីទេ គាត់ជាអ្នកជំនាញ គាត់បានស្បថ ហើយគាត់បានពិភាក្សាជាមួយភាគីមួយនៅពេលដំណើរការសក្ខីកម្មកំពុងបន្ត។

[០៩:១៤:៤៤]

ហើយនៅពេលដែលសាធារណជនបានដឹង គឺថាសាធារណជនបានដឹង -- ឮថាជនជាប់ចោទទាំងអស់គឺថាមានពិរុទ្ធភាពជាមុន។ ដូច្នេះ នេះហើយជាកាលៈទេសៈដែលបង្ហាញ។ ខ្ញុំសូមឲ្យតុលាការផ្តល់ការណែនាំឲ្យច្បាស់ពីបញ្ហានេះ។ សហព្រះរាជអាជ្ញា គឺថាស្ថិតនៅក្នុងភាពមួយដែលផ្គាំផ្គងមួយសហព្រះរាជអាជ្ញាដែលបានធ្វើបែបនេះ។ ដែលថា បើសិនជាត្រឹមតែសួរតែពីកាលវិភាគ អាហ្នឹងគឺជាបញ្ហាមួយខុសឆ្គងទៅហើយទម្រាំដល់បញ្ហាផ្សេងទៀត។

លោក ឆេនដ៍ល័រ បានយល់ថាគាត់ធ្វើសក្ខីកម្ម គាត់មានមួយសប្តាហ៍ ឬមួយខែពីរខែ ដើម្បីត្រៀមរៀបចំ ហើយគាត់ក៏ជាអ្នកប្រវត្តិវិទូរបស់កម្ពុជាផងទៀត។ ហើយយើងមិនចាំបាច់ចង់ដឹងថាតើគាត់ត្រូវពិនិត្យឯកសារអ្វី។ គឺឯកសាររួម គឺថាដូចជាដីកាដំណោះស្រាយ ថាតើឯកសារអ្វីដែលគាត់ត្រូវយកមកប្រើ ដើម្បីត្រៀមរៀបចំ ដើម្បីធ្វើឲ្យការចងចាំ ដើម្បីតម្រង់ទិសដៅ សក្ខីកម្មរបស់គាត់ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់សហព្រះរាជអាជ្ញា។

នេះហើយជាការបញ្ហា។ នេះហើយជាសេចក្តីប្រកាសជាសាធារណៈ ដែលឲ្យគេយល់ គឺយល់បែបនេះ។ ក្នុងលក្ខណៈជាមនុស្សដែលថា ដើម្បីតម្រង់ចម្លើយរបស់គាត់ ដើម្បីតម្រូវទៅតាមភាគីមួយ អានេះគឺជាកំហុស។ នេះហើយជាប្រធានបទបី ដែលខ្ញុំចង់ជម្រាបជូនដែលប្រសិនជា -- បន្ទាប់ទៅនេះ

គឺថាសូមតុលាការមេត្តាសួរទៅវេជ្ជបណ្ឌិត ដើម្បីឲ្យគាត់បានផ្តល់យោបល់ ថាតើបញ្ហាលោក អៀង សារី គាត់បានអាចនៅទីនេះបាន ឬក៏គាត់គួរតែទៅតាមដាននៅបន្ទប់ខាងក្រោម។ បាទ សូមអរគុណ។

[០៩:១៦:៣៣]

**ប្រធានអង្គជំនុំ៖**

លោកម៉ែខល កាណាវាស សូមបញ្ជាក់ម្តងទៀត តើលោកធ្វើសំណើសុំ គ្រាន់តែឲ្យអង្គជំនុំជម្រះសួរទៅស្តាប់នូវសម្តីរបស់គ្រូពេទ្យ? ឬក៏លោកធ្វើសំណើសុំថា ដូចរាល់ដងសុំឲ្យកូនក្តីរបស់លោកហ្នឹង គឺលះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការនេះ ដោយទៅបន្តតាមដានស្តាប់កិច្ចដំណើរការសវនាការពីចម្ងាយ ដោយសំអាងលើស្ថានភាពអ្វីខ្លះ ហើយនិងក្នុងនោះបើមានបញ្ហាគឺពាក់ព័ន្ធជាមួយនឹងចង់ដឹងច្បាស់គឺផ្អែកទៅលើមតិយោបល់របស់គ្រូពេទ្យ ដែលទទួលបន្ទុកពិនិត្យព្យាបាលថែទាំសុខភាពរបស់ជនជាប់ចោទប្រចាំនៅមន្ទីរឃុំឃាំង អ.វ.ត.ក? យើងមិនច្បាស់ទេ ខ្មែរដូចជាយើងស្តាប់មិនច្បាស់លើសំណើនេះ។

[០៩:១៧:៤២]

**លោក ម៉ែខល កាណាវាស៖**

សូមអភ័យទោស ប្រហែលជាខ្ញុំនិយាយលឿនពេកលោកប្រធាន។

ខ្ញុំមិនដឹងថា ទស្សនៈរបស់វេជ្ជបណ្ឌិតដូចម្តេចទេ ប្រហែលជាគាត់បដិសេធមិននិយាយជាមួយខ្ញុំទេ ទោះបីជាគាត់ទទួលបន្ទុកកូនក្តីរបស់ខ្ញុំក្តី។ អ៊ីចឹង ការអនុវត្តខ្ញុំគប្បីតែដឹងថា តើស្ថានភាពសុខភាពកូនក្តីរបស់ខ្ញុំដូចម្តេច? ខ្ញុំដឹងថាតើ ខ្ញុំចង់ដឹងថា ឱកទ័រ គាត់ហ្នឹងនិយាយដូចម្តេច? កូនក្តីរបស់ខ្ញុំប្រាប់ខ្ញុំថា គាត់មិនអាចចូលរួមនៅទីនេះទេ ដោយសារគាត់ឈឺខ្នង។ ហើយដោយសារថា មានភាពតានតឹងដែលដាក់បន្ទុកទៅលើគាត់នោះ ដោយហេតុថា គាត់ត្រូវតែទៅបន្ទប់ទឹករៀងរាល់ ៥នាទីម្តង ធ្វើឲ្យគាត់នឿយហត់ខ្លាំង។

ដោយជាក់ស្តែងគឺជាសំណើរបស់ខ្ញុំ ដើម្បីឲ្យគាត់បានទៅចូលរួមនៅពីបន្ទប់ខាងក្រោម។ ហើយយើងខ្ញុំដាក់សំណើនេះ ហើយយើងខ្ញុំនឹងចុះហត្ថលេខាលើលិខិតបោះបង់សិទ្ធិ គឺថា -- គឺលោកប្រធានបានបង្គាប់ឲ្យគាត់មកទីនេះ។ ឥឡូវនេះគាត់អញ្ជើញមកទីនេះ។ ឥឡូវនេះគាត់មិនបានចូលរួមក្នុងជាលក្ខណៈការពារខ្លួនរបស់គាត់ទេ។

[០៩:១៨:៥៤]

ការវត្តមានដោយរូបកាយនោះ មិនមែនមានន័យថា ផ្លូវចិត្ត បញ្ញារបស់គាត់អាចចូលរួមបានទេ។ គាត់មិនអាចផ្តង់អារម្មណ៍បាន គាត់មិនអាចស្តាប់សក្ខីកម្ម ហើយបើសិនចាំបាច់គាត់អាចផ្តល់ការណែនាំមកដល់មេធាវីបាននោះទេ។

ឥឡូវនេះ យើងមានករណីនេះនៅពេលសម្រាក យើងអាចនឹងទៅជួបគាត់ពិភាក្សាជាមួយគាត់នោះគឺថា -- ហើយយើងបានស្តាប់ពីកូនក្តីរបស់ខ្ញុំ ប៉ុន្តែវេជ្ជបណ្ឌិតមិនបានៗ ប្រាប់ឆ្លើយមកខ្ញុំទេ នៅពេលដែលគាត់ដើរចេញពីខ្ញុំដោយក្រអឺតក្រទម ហើយគាត់ -- ប្រហែលជាក្រមសីលធម៌មិនបានបង្គាប់ប្រាប់គាត់ឲ្យធ្វើអ៊ីចឹងទេ។ នេះជាកាយវិការមិនល្អទេ។ ខ្ញុំចង់បានចម្លើយខ្លះពីគាត់ ប៉ុន្តែគាត់ដើរចេញពីខ្ញុំ។ នេះជាហើយជា -- ខ្ញុំមិនដឹងថាតើលោកវេជ្ជបណ្ឌិតនឹងឆ្លើយដូចម្តេចទេ។ ប៉ុន្តែខ្ញុំស្តាប់ពីលោក អៀង សារី ប្រាប់ខ្ញុំ។ ឥឡូវនេះ គឺសាធារណជនតុលាការ បានជ្រាប បានឃើញស្រាប់ គាត់កំពុងតែឈឺខ្នង គាត់មិនអាចអង្គុយបាន។ ហើយយើងខ្ញុំនឹងចុះហត្ថលេខាឲ្យគាត់ផ្តិតមេដៃលើលិខិតបោះបង់សិទ្ធិនៅទីនេះ។

ប៉ុន្តែគាត់សុំឲ្យគាត់ទៅចូលរួមនៅបន្ទប់ខាងក្រោម។ នេះជាសំណើរបស់ខ្ញុំជូនតុលាការ បើសិនជាតុលាការមិនដឹងថា របាយការណ៍របស់តុលាការដូចម្តេចទេ តុលាការអាចមកបំភ្លឺ ហើយអាចនឹងឆ្លើយប្រាប់តុលាការ។ ប៉ុន្តែខ្ញុំបានដឹងថា គាត់បានផ្តល់ព័ត៌មានទៅមន្ត្រីច្បាប់របស់សាលាក្តីរួចហើយ។

សូមអរគុណ បាទ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីជាតិ! សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:២០:៤១]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំគ្រាន់តែមានយោបល់បន្តិច ទាក់ទងទៅនឹងអ្វីដែលលោក កាណាវាស បានលើកអម្បាញ់មិញ ទាក់ទងទៅនឹងលោកគ្រូពេទ្យ ដែលមិនឆ្លើយជាមួយនឹងលោក កាណាវាស។ ខ្ញុំគិតថា បញ្ហានេះមិនមែនជាបញ្ហាចម្លែកទេ ដែលគ្រូពេទ្យដែលជាអ្នកជំនាញ ហើយនៅក្នុងករណីនេះគឺជាអ្នកត្រូវពិនិត្យទៅលើអ្នកជំងឺ ហើយជាអ្នកដែលត្រូវឆ្លើយតបផ្ទាល់ជាមួយនឹងចៅក្រមតែម្តង នៅពេលដែលមានបញ្ហាដែលត្រូវបំភ្លឺគឺ គាត់ក្លាយជាអ្នកជំនាញខាងពេទ្យដែលមាន -- របស់តុលាការ។ ដូចករណីសាក្សី ឬក៏អ្នកជំនាញដទៃទៀតដែរ គឺភាគីមិនអាចឆ្លើយហើយតម្រូវឲ្យភាគី អ៎! ឲ្យសាក្សីហ្នឹងឆ្លើយផ្ទាល់ទៅនឹងភាគីនៅខាងក្រៅយ៉ាងដូច្នេះដែរ។ នៅក្នុងករណី

ដែលលោកគ្រូពេទ្យនេះ ត្រូវកោះអញ្ជើញដោយចៅក្រម គឺមានតែពេលនេះដែលភាគីអាចសួរ អ្នកជំនាញនៅចំពោះមុខចៅក្រមបាន។ ហើយដូចដែលករណីដែលលោក កាណាវាស បានលើកអំពីការទាក់ទងរវាងលោក ឆេនដ័ល័រ ហើយជាមួយនឹងការិយាល័យសហព្រះរាជអាជ្ញា គឺករណីនេះវាស្របគ្នា។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ!

[០៩:២២:១៤]

**លោក ហ្វាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់ឲ្យមានការភ័ន្តច្រឡំការពិភាក្សា ហើយខ្ញុំសូមបន្ថែមដោយខ្លី។ ចំណុចទីបី ដែលលោក ម៉ែខល កាណាវាស លើកឡើង ហើយខ្ញុំថាតើចង់ឲ្យសហព្រះរាជអាជ្ញាឆ្លើយតបទៅនឹងលោក កាណាវាស ដែរឬទេលោកប្រធានបាទ?

**ប្រធានអង្គជំនុំ៖**

អរគុណ។ លោកតំណាងសហព្រះរាជអាជ្ញា មានអីចង់ឆ្លើយតបទៅនឹងការកត់សម្គាល់របស់ក្រុមមេធាវីការពារក្តីដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ ខ្ញុំមានឆ្លើយតប។ សូមជម្រាបសួរលោកស្រីចៅក្រម។ ជាចំណុចបឋមរបស់ខ្ញុំ ខ្ញុំចង់ជម្រាបថា អ្វីដែលយើងប្រឈមមុខនៅពេលនេះគឺជា គំរូនៃអាកប្បកិរិយារបស់មេធាវីការពារក្តី ដែលបានស្នើសុំ ហើយដាក់សំណើនៅពេលចាប់ផ្តើមថ្ងៃ នៅពេលដែលសហព្រះរាជអាជ្ញា បានចាប់ផ្តើមនឹងសួរទៅអ្នកជំនាញ គឺថាពេលដែលយើងទទួលពេលកំណត់ គឺយើងបានប្រើពេលជិតកន្លះម៉ោងទៅហើយ។ ហើយពីម្សិលមិញនោះ ប្រហែលជាពីរថ្ងៃកន្លះ គឺថាយើងមិនអាចចំណាយតែកន្លះថ្ងៃសួរអ្នកជំនាញបានទេ។

[០៩:២៣:៣៨]

ឥឡូវនេះ ចូលទៅដល់ចំណុចមួយដែលលោក កាណាវាស បានលើកឡើងនោះ។ ចំណុចទីមួយ គឺថាសុខភាពរបស់លោក អៀង សារី ខ្ញុំនឹងនិយាយដោយសង្ខេប។ សហព្រះរាជអាជ្ញាមិនមានការជំទាស់ទៅនឹងសំណើរបស់គាត់ទេដែលគាត់ថា គាត់បានទទួលរបាយការណ៍មិនបានទទួលរបាយការណ៍

ពីវេជ្ជបណ្ឌិតនោះ។ ប៉ុន្តែគាត់ជាអ្នកជំងឺមកអំពីបន្ទប់ខាងក្រោមនោះ គឺថានៅសវនាការខាងលើនេះ នៅខាងក្រោមគឺថា គាត់មានលទ្ធភាពប្រើមេធាវី ហើយគាត់បានតាមដាននូវដំណើរការនីតិវិធីតាមវីដេអូបាន គឺថាយើងមិនជាបញ្ហាទេ ជាឆន្ទានុសិទ្ធិរបស់តុលាការក្នុងការសម្រេចថា ឱ្យទៅក្រោម ឬនៅទីនេះ។

បញ្ហាទីពីរ អំពីការចោទប្រកាន់ថា យើងមានការទាក់ទងជាមួយអ្នកជំនាញដោយគ្មានវត្តមានរបស់មេធាវីការពារក្តីនោះ យើងទាំងពីរគឺយើងមានការភ្ញាក់ផ្អើលណាស់ ដែលថាមេធាវីលើកឡើងនៅក្នុងតុលាការ ដូចដែលលោក កាណាវាស បានលើកឡើងនោះ ហើយខ្ញុំមិនចូលចិត្តឱ្យលោកដោះស្រាយបញ្ហានេះក្នុងតុលាការ ប៉ុន្តែខ្ញុំកត់ត្រានៅក្នុងតុលាការសាស្ត្រាចារ្យ ឆេនដ័ល័រ បានមកយើងខ្ញុំ ដើម្បីសួរខ្ញុំអំពីការកំណត់ពេលកាលបរិច្ឆេទ ដូចដែលខ្ញុំជូនទៅគាត់នោះ គឺដូចដែល កាណាវាស បានលើកប្រាប់តុលាការដែរ គឺថាសម្រាប់កាលវិភាគសម្រាប់ថ្ងៃនេះ និងអាទិត្យក្រោយតែប៉ុណ្ណោះ។ ហើយលោក កាណាវាស មកលើកឡើងនៅក្នុងតុលាការ ប៉ុន្តែខ្ញុំពន្យល់គាត់ពីម្សិលមិញរួចហើយ ហើយគាត់អាចឃើញនឹងការសន្ទនាហ្នឹងដោយខ្លីសង្ខេបទេ។

[០៩:២៥:២០]

នៅចំណុចទីបី ទីបញ្ចប់បញ្ហាទាក់ទងទៅនឹងឯកសារ យើងមិនចាំបាច់ចំណាយពេលច្រើនទេ គឺលោកសាស្ត្រាចារ្យហ្នឹង គាត់ -- យើងបានណែនាំឱ្យគាត់រៀបចំជាបញ្ជីឯកសារហើយ គាត់នឹងបន្ថែមអ្វីដែលគាត់មាន ហើយនៅពេលដែលយើងសួរ ហើយយើងនឹងអាចបង្ហាញឯកសារទៅសាស្ត្រាចារ្យ ហើយគាត់នឹងឆ្លើយផ្អែកទៅលើឯកសារនេះ។

ដូច្នេះនេះគឺជាអាថ៌កំបាំង ដែលថាមេធាវីការពារក្តីចង់ដឹងហ្នឹង គឺមិនជាអ្វីអាថ៌កំបាំងនោះទេ ហើយយើងនឹងដោះស្រាយជាមួយបញ្ហាជាក់លាក់មួយៗ គឺមិនមានអ្វីជាបញ្ហាចម្រូងចម្រាសជាមួយការពិភាក្សានោះទេ។ ហើយចំពោះបញ្ហានេះ ខ្ញុំក៏កត់ត្រាចំពោះការជំទាស់ពីម្សិលមិញ ហើយនិងថ្ងៃនេះផងដែរពីខាងមេធាវីការពាររបស់លោក អៀង សារី ហើយគាត់ព្យាយាមដើម្បីបំភិតបំភ័យសាក្សី។ គាត់ចង់ដាក់ៗ ឱ្យលោក ដេវីដ ឆេនដ័ល័រ នៅក្នុង -- ស្ថានភាពមួយដ៏លំបាក ហើយគឺថាមិនមានបញ្ហានេះ គឺទាក់ទងទៅនឹងសំណើសុំឯកសារនេះ គឺជាការប៉ុនប៉ងមួយដើម្បីបំភិតបំភ័យសាក្សីតែប៉ុណ្ណោះទេ។ ប្រសិនបើចង់បង្ហាញអំពីការវាយប្រហារទៅលើរូបគាត់ពីដំបូងនោះ គឺជាការប៉ុនប៉ងមួយដើម្បីធ្វើឱ្យមានការៗ លំបាកក្នុងការផ្តល់សក្ខីកម្ម។

លោក លោកស្រីចៅក្រម អនុលោមទៅតាមបញ្ហាវត្តមានរបស់លោក អៀង សារី នៅក្នុងតុលាការ យើងសុំឲ្យមានការពិនិត្យទៅលើសុខភាពរបស់គាត់ទៅតាមលក្ខណៈបច្ចេកទេស វេជ្ជបណ្ឌិត និងតុលាការ។ សូមអរគុណ។

[០៩:២៧:១១]

**ប្រធានអង្គជំនុំ៖**

យើងលែងឈប់ឲ្យនិយាយទៀតហើយ មិនអាចធ្វើត្រឡប់ចុះត្រឡប់ឡើងអ៊ីចឹងទេ។ យើងបានកម្រិតរួចហើយ ភាគីមួយនិយាយតែម្តងទេ។

មន្ត្រីក្រឡាបញ្ជីសវនាការ តើមានការពិនិត្យសុខភាពរបស់ជនជាប់ចោទ អៀង សារី ដោយៗគ្រូពេទ្យប្រចាំការនៅ អ.វ.ត.ក ដែរទេ នៅព្រឹកនេះ?

យើងមិនអនុញ្ញាតឲ្យលោកនិយាយអ្វីទៀតទេ នីតិវិធីត្រូវប្រព្រឹត្តទៅមុខ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន លោកគ្រូពេទ្យបានពិនិត្យជនជាប់ចោទហើយ ប៉ុន្តែមិនទាន់បានធ្វើរបាយការណ៍នៅឡើយ។ សូមអរគុណ។

[០៩:២៨:០៧]

**ប្រធានអង្គជំនុំ៖**

ឥឡូវនេះដើម្បីដោះស្រាយបញ្ហានេះច្បាស់ គឺសូមអញ្ជើញលោកគ្រូពេទ្យអញ្ជើញមកកាន់កន្លែងនេះ ដើម្បីធ្វើរបាយការណ៍។ ជួយរៀបចំក្បាលមីក្រូ ជិតៗអ្នកជំនាញ។

លោកមានបំណងនិយាយអីទៀត? បញ្ហាដដែល? បញ្ហាដដែលនេះយើងលែងឲ្យនិយាយហើយ

លោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា បើពុំដូច្នោះទេគឺបញ្ហានៅតែត្រឡប់ចុះត្រឡប់ឡើងដូច្នេះ។ បញ្ហាទាំងបី គឺបានលើកឡើងអស់ហើយរវាងភាគីទាំងសងខាង ឬក៏មានបញ្ហាអ្វីផ្សេងទៀត? បើបញ្ហាដដែលយើងមិនអនុញ្ញាតឲ្យលោកនិយាយទៀតទេ បញ្ចប់ត្រឹមនេះ។ យើងមានមូលដ្ឋានគ្រប់គ្រាន់សម្រេចបញ្ហា សម្រាប់ពិចារណាសម្រេចលើបញ្ហាទាំងប៉ុន្មានដែលភាគីបានលើកឡើងនេះហើយ។

[០៩:២៩:១០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:២៩:៥០]

**ប្រធានអង្គជំនុំ៖**

លោកមានបញ្ហាអីលោកមេធាវី? ឲ្យប្រធានបទជាមុនសិន ដើម្បីយើងអនុញ្ញាត ឬក៏មិនអនុញ្ញាត ពីព្រោះបញ្ហាដដែលយើងមិនអនុញ្ញាតឲ្យលោកនិយាយទេ លើកលែងតែបញ្ហាថ្មីផ្សេងទៀត។

**លោក ហ្សាស្តេី ប៉ោះ៖**

ដូចដែលខ្ញុំជម្រាបលោកប្រធាន គឺថាសំណើរបស់ខ្ញុំនេះទាក់ទងទៅនឹងបញ្ហាទីបី ដែលលើកឡើងដោយមេធាវី កាណាវាស។ ដើម្បីសម្រួលនីតិវិធី ខ្ញុំស្នើដើម្បីពិភាក្សាបញ្ហាផ្សេងទៀត ហើយនិងសហព្រះរាជអាជ្ញាបានពិភាក្សាទៅលើចំណុចមួយផ្សេងទៀតអំពីសុខភាព ហើយនិងការទាក់ទងរវាងអ្នកជំនាញ និងសហព្រះរាជអាជ្ញា។ ហើយបញ្ហាទាក់ទងទៅនឹងឯកសារដែលសហព្រះរាជអាជ្ញា ហើយបញ្ហាដែលទាក់ទងទៅនឹងឯកសារដែលសាស្ត្រាចារ្យ ឆេនដ័ល័រ នោះគឺថាជាការបន្ថែម ខ្ញុំអាចនឹងប្រើពេលតែពីរមីនុត ឬក៏មួយមីនុតប៉ុណ្ណោះទេ។

[០៩:៣១:០០]

**ប្រធានអង្គជំនុំ៖**

បាទអរគុណ អង្គជំនុំជម្រះនឹងអនុញ្ញាត ប៉ុន្តែឥឡូវនេះយើងស្តាប់លោកវេជ្ជបណ្ឌិតឡើងនិយាយរៀបរាប់អំពីបញ្ហាស្ថានភាពសុខភាពជនជាប់ចោទ អៀង សារី ជាមុនសិន។

បាទ សូមអញ្ជើញលោកវេជ្ជបណ្ឌិត!

**លោក តុង ហុង៖**

ខ្ញុំសូមរាយការណ៍ពីកំណត់ហេតុសុខភាពក្នុងពេលសវនាការ។ ខ្ញុំបាទវេជ្ជបណ្ឌិត តុង ហុង ប្រចាំការនៅ អ.វ.ត.ក សូមជម្រាបលោកប្រធានសវនាការនៃ អ.វ.ត.ក។

កម្មវត្ថុស្ថានភាពសុខភាពរបស់ជនត្រូវចោទ អៀង សារី ក្នុងពេលសវនាការ។ វេលាម៉ោងប្រាំបីសាមសិបនាទីព្រឹក សម្ពាធឈាមគាត់ ១៣/៨ សង់ទីម៉ែត្របារត, ជីបចរ ៦២ ក្នុងមួយមីនុត, ចំអែតខ្យល់អុកស៊ីហ្សែន ៩៣ភាគរយ, ចង្វាក់ដង្ហើមរបស់គាត់ ២៣ ក្នុងមួយមីនុត។ ស្ថានភាពទូទៅមិនប្រែប្រួល។ ជាអនុសាសន៍ គាត់អាចចូលរួមនៅក្នុងសវនាការបានក្នុងរយៈពេលមួយម៉ោង ឬក៏ពីរម៉ោង។

[០៩:៣២:១៩]

**ប្រធានអង្គជំនុំ៖**

បាទ មានអ្វីចង់សួរលោកវេជ្ជបណ្ឌិតដែរឬទេ លោកស្រីចៅក្រម?

E1/92.1

ភាគីផ្សេងទៀតមានអ្វីចង់សួរចំពោះវេជ្ជបណ្ឌិតដែរឬទេ?

**លោក ម៉ៃខល កាណាវាស៖**

ខ្ញុំសូម លោកប្រធាន--

[០៩:៣២:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៤:៤៨]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះអង្គជំនុំជម្រះសម្រេចថា មិនផ្តល់វេទិកាជូនទៅ -- ឲ្យទៅភាគីក្នុងការតាំងសំណួរពាក់ព័ន្ធនឹងរបាយការណ៍របស់វេជ្ជបណ្ឌិត ដោយសារមូលហេតុពេលវេលាផង។ ហើយអង្គជំនុំជម្រះអរគុណលោកវេជ្ជបណ្ឌិត ហើយអង្គជំនុំជម្រះអរគុណលោកវេជ្ជបណ្ឌិតដែលបានធ្វើរបាយការណ៍ជាក់ច្បាស់អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី ដែលមានលទ្ធភាពក្នុងការអាចអង្គុយនៅក្នុង -- តាមដានក្នុងកិច្ចដំណើរការសវនាការនេះអាចមួយម៉ោងទៅពីរម៉ោងនោះ។ ហើយបញ្ហានេះអង្គជំនុំជម្រះនឹងសម្រេចនៅលើសំណើសុំរបស់គាត់នៅក្នុង -- ឲ្យបានមុនពេលសម្រាកលើកទីមួយនៅព្រឹកនេះ។ បាទ លោកអញ្ជើញទៅកាន់ទីកន្លែងវិញបានហើយ។

បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា -- អ៊ំ! *សូរី* សូមទោស នៅបញ្ហាមួយទៀត។ សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា។ យើងអនុញ្ញាតលោកប្រើពេលវេលាខ្លីបានហើយ ពីព្រោះពេលវេលាដែលត្រូវផ្តល់ឲ្យភាគីសហព្រះរាជអាជ្ញា និងមេធាវីនាំមុខនោះដូចជាអស់ច្រើនហើយ។ ថ្ងៃនេះអស់ជិតមួយម៉ោងហើយ។

[០៩:៣៦:១៤]

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន ខ្ញុំនឹងនិយាយដោយសង្ខេប ហើយនិងព្យាយាមដោយយឺតៗដើម្បីដាក់បន្ទុកខ្លាំងពេកទៅលើអ្នកបកប្រែទេ។ ខ្ញុំបានដឹងថាសាស្ត្រាចារ្យ ឆេនដ័ល័រ និយាយម្សិលមិញ គាត់បានសិក្សាដីកាដំណោះស្រាយ មុននឹងមកធ្វើសក្ខីកម្មចំពោះអង្គជំនុំជម្រះ។ ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា យើងមិនចាត់ទុកថា ការណ៍ហ្នឹងជាបញ្ហានោះទេ។ ដូចដែលសាស្ត្រាចារ្យបានបញ្ជាក់ហើយ គឺថាដីកាដំណោះស្រាយបានធ្វើឲ្យគាត់កែប្រែគំនិតមួយចំនួន។ អ៊ីចឹងហើយគួរកត់សម្គាល់ថាដីកាដំណោះស្រាយ គឺមិន

សំខាន់អ្វីជាងដែលថាសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញានោះទេ។ ហើយខ្ញុំចង់បន្ថែមថា នេះជាដីកាបញ្ជូនរឿងមកជំនុំជម្រះ។ នេះគឺជាឯកសារដាក់បន្ទុក នេះហើយជាចំណុចសំខាន់ដែលយើងត្រូវអនុវត្តទៅមុខជាមួយនឹងសក្ខីកម្មរបស់គាត់ដែលយើងដឹងថា ភាគីទាំងអស់ដឹងថាៗតើគាត់បានពិនិត្យមើលឯកសារទាំងអស់នៅនៅក្នុងដីកាដំណោះស្រាយដែរឬអត់? បើមិនទេ តើផ្នែកណាមួយ ឯកសារណាមួយដែលគាត់បានពិនិត្យមើល? ហើយឯកសារណាដែលគាត់មិនបានមើល? យើងចង់ដឹង។

[០៩:៣៧:៣៥]

ខ្ញុំបាននឹកឃើញថាសាស្ត្រាចារ្យបាននិយាយពីម្សិលមិញថា ខ្ញុំមិនមានប្រតិចារឹកទេ ខ្ញុំមិនបានចាំពាក់ជាក់លាក់ ប៉ុន្តែសាស្ត្រាចារ្យបាននិយាយថា ខ្ញុំចង់មើលព័ត៌មានទាំងអស់នោះ ហើយគាត់បាន -- ចង់ឲ្យគាត់បញ្ជាក់ប្រាប់យើង។ នេះជាព័ត៌មានមួយចំនួននៅក្នុងដីកាដំណោះស្រាយ គឺថ្មីសម្រាប់គាត់ដែលគាត់ចង់បាន ហើយបើសិនជាគាត់យកមកជាបង្អែកនៃការប្ដូរនូវមតិយោបល់របស់គាត់នៅលើឯកសារថ្មី គាត់ចង់បានឯកសារថ្មី។ ថាតើឯកសារណាជាឯកសារថ្មីដែលគាត់ចង់បានមកជាបង្អែកនោះ? ហើយដើម្បីឲ្យច្បាស់ ហើយយើងឃើញច្បាស់ថាសាស្ត្រាចារ្យ ឆេនដ៍ល័រ មិនមានលទ្ធភាពទៅមើលឯកសារទាំងអស់ទេនៅក្នុងដីកាដំណោះស្រាយ ដោយហេតុថាផ្នែកខ្លះជាការសម្ងាត់បាទ។ ក្នុងកម្រិតមួយ សាស្ត្រាចារ្យ ឆេនដ៍ល័រ មិនអាចដឹងឯកសារសម្ងាត់នោះទេ ហើយយើងមិនដាក់ការបន្ទោសទៅលើគាត់ទេចំពោះបញ្ហានេះ។ ទាក់ទងទៅនឹងកាលៈទេសៈនេះ យើងត្រូវតែឲ្យច្បាស់ ដែលថាតើគាត់បានពឹងផ្អែកឯកសារណា នៅក្នុងដីកាដំណោះស្រាយ? ដូចដែលលោក កាណាវាស និយាយគឺថាសក្ខីកម្មរបស់លោក ឆេនដ៍ល័រ បានក្លាយទៅជាមានបញ្ហា ដោយសារតែគាត់បានអានដីកាដំណោះស្រាយធ្វើឲ្យមានប៉ះពាល់ទៅដល់ភាពយុត្តិធម៌។

[០៩:៣៩:១០]

ដូច្នេះហើយ ថាតើអ្វីជាមូលដ្ឋានដែលលោកសាស្ត្រាចារ្យ ឆេនដ៍ល័រ យកជាបង្អែកនៅថ្ងៃនេះនិងពេលទៅមុខនោះ? ថ្ងៃនេះប្រហែលជាយឺតពេលបន្តិចដើម្បីឲ្យលោកសាស្ត្រាចារ្យ ដើម្បីផ្ដល់ព័ត៌មាននេះ ប៉ុន្តែយើងនឹងត្រឡប់មកបញ្ហានេះនៅពេលដែលយើងខ្ញុំសួរសំណួរទៅគាត់។ ហើយអង្គជំនុំជម្រះមេត្តាណែនាំគាត់ដើម្បីការរំឭកគាត់ គឺថាយើងនឹងលើកមកបញ្ហា -- លើកយកបញ្ហានេះមកនិយាយនៅពេលដែលយើងសួរសំណួរគាត់ គឺឲ្យគាត់បញ្ជាក់ថា ឯកសារណាដែលគាត់ពឹងផ្អែក ឯកសារណាដែលគាត់មិនមាននោះបាទ?

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

[០៩:៣៩:៥៩]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា មេធាវីការពារក្តី គឺថាបានសួរហើយបានឆ្លើយខ្លួនឯងរួចទៅហើយ -- ឧបសម្ព័ន្ធទៅនឹងដីកាដំណោះស្រាយជាឯកសារសម្ងាត់ ហើយអ្នកជំនាញគឺគាត់មិនមានលទ្ធភាពបើកមើលបានទេ។ ខ្ញុំភ្ញាក់ផ្អើលនៅពេលដែលមេធាវីលើកឡើងបញ្ហានេះជាថ្មី ពីព្រោះខ្ញុំគិតថា យើងបានពិភាក្សារួចហើយជាពិសេសគឺថា យើងពិនិត្យជូនឯកសារទៅសាស្ត្រាចារ្យហ្នឹងជាក់លាក់មួយចំនួននៅពេលណាដែលគាត់មានមតិយោបល់ ឬក៏មានសេចក្តីសន្និដ្ឋានរងផលប៉ះពាល់ពីដំណោះស្រាយ ឬអត់ គឺសូមឱ្យគាត់បញ្ជាក់។ អានេះជាបញ្ហាមួយដែលយើងបាន អាចនឹងពិភាក្សារួចហើយ។ ហើយទាក់ទងចំណុចណាដែលគាត់បានបើកមើល អាចមើលបាន ឬមិនមើលបាននោះ គឺថាជាព័ត៌មានបន្ថែម គឺយើងនឹងជម្រាបជូននៅពេលយើងសួរទៅគាត់នោះឯង។

[០៩:៤០:៥៧]

ហើយយើងមិនគិតថា មានភាពសមស្របទេដែលមេធាវីការពារក្តី សូមឱ្យលោកសាស្ត្រាចារ្យទទួលការណែនាំឱ្យថា ឯកសារណាគាត់មិនបានបើកមើល ឬក៏មើលនោះទេ គឺថាមូលដ្ឋាននៅក្នុងសេចក្តីសន្និដ្ឋានរបស់គាត់នោះ គឺគាត់ក្នុងឋានៈជាអ្នកជំនាញផ្អែកលើការសិក្សាស្រាវជ្រាវរបស់គាត់។

*(ចៅក្រមពិភាក្សាគ្នា)*

**ប្រធានអង្គជំនុំ៖**

បាទ ទីមួយ សូមជម្រាបជូនអ្នកជំនាញសូមរំឭកអ្នកជំនាញថា ដោយសារលោកចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីក្នុងនាមអ្នកជំនាញ ឬសាក្សីនោះ គឺលោកគប្បីចៀសវាងឱ្យបានជាដាច់ខាតនូវការទាក់ទងនឹង -- ជាមួយនឹងភាគីណាមួយនៃរឿងក្តី ហើយដោយហេតុដូច្នេះហើយ បានជាអង្គជំនុំជម្រះមានការប្រញាប់ប្រញាល់មួយនៅពេលដែលចប់ ឬក៏សម្រាកតែងតែឱ្យមន្ត្រីរដ្ឋបាលតុលាការអញ្ជើញលោកទៅកន្លែងសម្រាក ដើម្បីឱ្យមានន័យថា គឺជាសម្រួលដល់អារម្មណ៍ផង ហើយកុំឱ្យមានការពាក់ព័ន្ធទៅនឹងការប្រាស្រ័យទាក់ទងជាមួយនឹងភាគីដទៃទៀត។

[០៩:៤២:១៨]

ហើយដោយឡែកបញ្ហាផ្សេងទៀត ដែលពាក់ព័ន្ធនឹងកិច្ចពិភាក្សាដេញដោលនៅក្នុងរឿងក្តីនេះ ដែលទាក់ទិនជាមួយនឹងការប្រើប្រាស់ឯកសារ ឬក៏មានការផ្ទុះផ្តងទៅនឹងដីកាដំណោះស្រាយ ឬក៏ឯកសារភ្ជាប់នឹងដីកាដំណោះស្រាយ ដែលលើកឡើងអម្បាញ់មិញនេះ គឺជារឿងដដែលទេ ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយកាលពីម្សិលមិញ ដោយអង្គជំនុំជម្រះបានប្រគល់ភារៈជូនទៅលោកស្រីចៅក្រមស៊ីលវៀ ខាតវ៉ាយថ៍។

ហើយជាបន្តសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោល ហើយបើអាចបញ្ជាក់បានក៏សូមបញ្ជាក់ផងដែរ អំពីពេលវេលានៃពីរថ្ងៃកន្លះដែលធ្វើការបែងចែកជូនដល់ភាគីទាំងពីរ។ តំណាងសហព្រះរាជអាជ្ញា និងមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី តើមានការបែងចែកពេលវេលាគ្នាយ៉ាងដូចម្តេចខ្លះ ពីរថ្ងៃកន្លះនេះ? ដើម្បីអង្គជំនុំជម្រះសម្របសម្រួលពេលវេលានេះឲ្យបានសមស្រប។

[០៩:៤៣:៣៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

នៅក្នុងបញ្ហាចុងក្រោយនេះ យើងខ្ញុំសង្ឃឹមថា នឹងមានសាលភាពទំហំការងារមួយចំនួនដែលត្រូវបំពេញបន្ថែម ដើម្បីឆ្លើយតបទៅនឹងការឆ្លើយតបតាំងពី -- ការពន្យារពេលកាលពីម្សិលមិញ និងថ្ងៃនេះ ហើយយើងនឹងត្រូវប្រើពេលពីរថ្ងៃកន្លះដែលយើងបានទទួលពីរថ្ងៃកន្លះសរុបនេះ យើងនឹងប្រើពេលធ្វើម៉េចឲ្យបានកៀកត្រឹមតែពីរថ្ងៃ ហើយសូមទុកពេលសល់ប៉ុន្មានទៅឲ្យភាគីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ហើយខ្ញុំនឹងព្យាយាមធ្វើការងារឲ្យបានឆាប់រហ័ស។ ហើយយើងនឹងព្យាយាមទាក់ទងទៅនឹងបញ្ហាសំខាន់ៗ ដែលប្រហែលជារយៈពេលពីរថ្ងៃនេះ គឺថាអាចតិចបន្តិចសម្រាប់យើងខ្ញុំ ប៉ុន្តែយើងខ្ញុំនឹងព្យាយាមធ្វើឲ្យបានបាទ។

**ប្រធានអង្គជំនុំ៖**

អរគុណបាទ។ សូមអញ្ជើញមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

[០៩:៤៥:០០]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ខ្ញុំសោកស្តាយណាស់ដែលដើមបណ្តឹងរដ្ឋប្បវេណីមានពេលដែល

សល់ទុកពីខាងសហព្រះរាជអាជ្ញា។ សហព្រះរាជអាជ្ញា គាត់មានពេលវេលាដែលគាត់គិតថា មានភាពចាំបាច់ដើម្បីសួរសំណួរ ហើយខាងភាគីដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំថាយើងគួរតែមានពេលចាំបាច់សម្រាប់ការសួរដែរ។ ដូច្នេះយើងគិតថា យើងត្រូវការពេលវេលាប្រាំម៉ោង យើងបានបញ្ជាក់ជូនលោកស្រី ស៊ីហ្សាន ឡេម ហើយ គឺយើងត្រូវការពេលវេលាប្រាំម៉ោងសម្រាប់សួរ។ ហើយនៅទីនេះយើងមានសហភាតារបស់យើងបានរៀបចំប្រធានបទដើម្បីសួរគាត់ ហើយគាត់មកពីបរទេស ជាមេធាវីបរទេសគាត់មកសួរ។ ដូច្នេះ វាមិនជាការសមស្របទេ ដែលថាដើមបណ្តឹងរដ្ឋប្បវេណីមានពេលវេលាតិចតួចនោះ។ ដូច្នេះគាត់គិតថា -- យើងគិតថាយើងត្រូវការពេលវេលាប្រាំម៉ោងសម្រាប់សួរទៅកាន់អ្នកជំនាញរូបនេះ។

[០៩:៤៥:៥៥]

**ប្រធានអង្គជំនុំ៖**

តាមវិធានថ្មីដែលអង្គជំនុំជម្រះបានកំណត់ គឺមានតែកាត់បន្ថយទេ មិនបន្ថែមពេលវេលាឲ្យទេគ្រប់ភាគីទាំងអស់។ ក្នុងន័យដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធីប្រព្រឹត្តទៅឲ្យបានឆាប់រហ័សបំផុតតាមដែលអាចធ្វើទៅបាន។ ដូច្នេះសូមពិចារណាម្តងទៀតរវាងតំណាងសហព្រះរាជអាជ្ញាជាមួយនឹងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីអំពីពេលវេលានេះ ពីព្រោះមុខងារភារកិច្ចទាំងពីរនេះ គឺស្របគ្នា។ មួយគឺចម្បងក្នុងការ -- មានភារកិច្ចក្នុងការបង្ហាញភស្តុតាងដាក់បន្ទុកទៅលើជនជាប់ចោទ។ ឯភាគីមួយទៀត គឺគ្រាន់តែជាភាគីគាំទ្រទៅលើកិច្ចការចោទប្រកាន់របស់សហព្រះរាជអាជ្ញាប៉ុណ្ណោះ។ អ៊ីចឹងពិចារណាគ្នា អង្គជំនុំជម្រះមិនពន្យារពេលឲ្យទេ មានតែកាត់បន្ថយតែប៉ុណ្ណោះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:៤៧:១២]

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមជម្រាបសួរលោកសាស្ត្រាចារ្យ ឆេនដ័ល័រ។ ជាអកុសលយើងបានខាតពេលមួយព្រឹកនេះរហូតមកដល់ពេលនេះហើយក្នុងការសួរទៅលោក ហើយខ្ញុំនឹងផ្តោះចោលនូវប្រធានបទខ្លះ ហើយខ្ញុំនឹងព្យាយាមសួរតែសំណួរសំខាន់ៗ ផ្នែកសំខាន់ៗដែលខ្ញុំចង់សួរលោកអំពីបញ្ហាមួយចំនួនដូចដែលខ្ញុំជម្រាបពីម្សិលមិញ គឺសម័យកាលមុនឆ្នាំ១៩៧៥។ ហេតុការណ៍សំខាន់ៗ ហើយនិងការវិវត្តន៍នៃគោលនយោបាយដែលលោកបានយោងទៅរកកាលពីម្សិលមិញនោះ។ នៅក្នុងសៀវភៅរបស់លោកដែលមានចំណង

ដើងថា “បងទី១” ហើយនិង “សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា” លោកបានសរសេរលំដាប់លំដោយប្រវត្តិសាស្ត្រកម្ពុជាតាំងពីមុនមក។ ហើយជាអកុសលយើងមិនបាន -- មានពេលដើម្បីពិនិត្យមើលទៅតាមលំដាប់លំដោយកាលវេលានោះទេ។ អ្វីដែលខ្ញុំនឹងសួរលោកនោះ ខ្ញុំនឹងចាប់ផ្ដើមឆ្នាំ១៩៦០ ដែលជាកាលបរិច្ឆេទដែលលោកបានចាត់ថាជាសំខាន់នៅក្នុងសៀវភៅរបស់លោក។ ហើយយើងចាត់ទុកថាជាចំណុចចាប់ផ្ដើមដើម្បីសួរលោកពីនោះមក។

ឥឡូវនេះ ដោយសារពេលវេលាយើងមានខ្លី ខ្ញុំនឹងសួរសុំឲ្យជំនួយការរបស់ខ្ញុំនឹងជូនឯកសារលើក្រដាសនូវសៀវភៅទាំងពីរនេះ ដោយមានសេចក្ដីដកស្រង់ដែលយើងនឹងប្រើ ហើយខ្ញុំនឹងអានសេចក្ដីដកស្រង់ ហើយលោកអាចពិនិត្យមើលអេក្រង់ ដើម្បីសន្សំពេលវេលា។

[០៩:៤៨:៥៨]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតដើម្បីជូនឯកសារលើក្រដាសទៅលោកសាស្ត្រាចារ្យក្នុងពេលដែលខ្ញុំនឹងអាននូវសេចក្ដីដកស្រង់នេះបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ មន្ត្រីរដ្ឋបាលតុលាការទទួលឯកសារពីតំណាងសហព្រះរាជអាជ្ញាជូនទៅសាក្សី -- ជូនទៅអ្នកជំនាញដើម្បីពិនិត្យ។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរបន្តដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យ ជាការរៀបចំ គឺថាសូមឲ្យ -- សូមកលោករង់ចាំទាល់តែមីក្រូហ្វូនបើកភ្លើងក្រហម ដើម្បីឲ្យលោកនិយាយចូល។ ហើយសូមលោកចាំបន្តិចមុននឹងឆ្លើយ ដើម្បីឲ្យការបកប្រែហ្នឹងបានកត់ត្រាត្រឹមត្រូវ ហើយបកទាន់បាទ។ បើសិនជាលោកនិយាយមុន គឺមិនអាចកត់ត្រាបានមិនអាចបកប្រែបានទេ។

យើងពិនិត្យមើលនូវសៀវភៅនិយាយអំពីសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងជំពូកទីបីឯកសារ E3/14 សៀវភៅនេះគឺនិយាយតែERN គឺ 00193299 គឺថា ឯកសារ៩៧ ERN ហ្នឹងនៅក្នុងឯកសារនេះជា -- នេះជាផ្នែកមួយដែលខ្ញុំនឹងផ្ដោតការយកចិត្តទុកដាក់ជាការពិភាក្សានៅ -- អំពីការ

ប្រជុំនៅឆ្នាំ១៩៦០ របស់បក្សកុម្មុយនីស្តកម្ពុជា។ លោកនិយាយថា សមាជនោះគឺថាបានយក -- ទាក់ទាញការយកចិត្តទុកដាក់ គឺថាមិនទាន់មានភាពប្រាកដ។ ប៉ុន្តែអង្គហេតុបីសំខាន់ គឺថា ទីមួយ គឺសាឡុត ស ត្រូវបានតែងតាំង ដើម្បីឲ្យទទួលតំណែងទីបីនៅក្នុងគណៈមជ្ឈិម គឺក្រោម ទូ សាមុត និង នួន ជា។ ទីពីរ KPRP ហ្នឹងគឺបានប្តូរឈ្មោះទៅជា "បក្សពលករកម្ពុជា"។

[០៩:៥១:១១]

ហើយបានដាក់កម្រិតមួយ ដែលថា ជាកម្រិតស្មើនឹងបក្សពលករវៀតណាម ហើយ សឹង ង៉ុកមិញ គឺថាអវត្តមាន គឺមិនមាននៅក្នុងវត្តមាន។ ហើយនៅខាងក្រោម អៀង សារី ហើយនិង កុយ ធួន គឺជាបញ្ជរន្តក្រៅពី សាឡុត ស ដែលគេបានដាក់ចូលទៅក្នុងគណៈមជ្ឈិមនេះ។ បន្ទាប់ទៅទៀតនោះ នៅក្នុងសៀវភៅដែលនៅក្នុងទំព័រមួយ "...លើសពីនេះទៅទៀត ទស្សនៈរបស់បក្សកុម្មុយនីស្តក្នុងរយៈ ៦ឆ្នាំ កន្លង គឺថាមានលទ្ធភាព គឺថាសេចក្តីដំណោះស្រាយ គឺសម្រេចនៅក្នុងកិច្ចប្រជុំឆ្នាំ៦០។ ទោះជាយ៉ាងណាក្តី គឺថាអ្នកចូលរួម គឺថាអាចនឹងចូលរួមនៅក្នុងភាគី គឺថាអ្នកឈ្នះ គឺប៉ុល ពត។ ហើយផ្សេងទៀត គឺថាមកពីបក្សកុម្មុយនីស្តឥណ្ឌូចិន ដែលៗគ្រប់គ្រងដោយ សោ ភឹម នៅក្នុងផ្នែកមួយនៅក្នុងប្រទេស។" ហើយសូមឲ្យលោកជម្រាបតុលាការអំពីអ្វីដែលលោកបាន -- លោកបានរកឃើញ ហើយនិងសេចក្តីសន្និដ្ឋានថា អ្វីជាចំណុចសំខាន់នៃមហាសន្និបាតឆ្នាំ១៩៦០ នេះ ដែលលោកបាននិយាយថា នៅពេលនោះមានការប្តូរឈ្មោះរបស់បក្សផងដែរ ហើយនិងប្តូរសមាជិកភាពផងដែរ នៅក្នុងគណៈអចិន្ត្រៃយ៍របស់គេនោះ។ បាទ សូមលោកនិយាយដោយសង្ខេប។

**លោក ដេវីដ ឆេនដ័លរ៖**

**ឆ៖** សូមអរគុណ។ ហើយសូមជម្រាបសួរ។ មុននឹងឆ្លើយសំណួរ ខ្ញុំសូមអភ័យទោសចំពោះតុលាការ អ្វីដែលខ្ញុំនឹងធ្វើសេចក្តីពន្យល់ដោយសង្ខេប ដែលខ្ញុំបានពិភាក្សាជាមួយសហព្រះរាជអាជ្ញានោះ។ ខ្ញុំមិនមានចេតនា នោះជាកំហុសមួយរបស់ខ្ញុំ ហើយខ្ញុំសូមអភ័យទោសចំពោះតុលាការ។

[០៩:៥៣:០៧]

ទាក់ទងទៅនឹងផ្នែកដែលសហព្រះរាជអាជ្ញាលើកឡើងនោះ គឺសន្និបាតឆ្នាំ១៩៦០នេះ ប៉ុល ពត បានកត់សម្គាល់ថា -- គាត់និយាយថា គឺជាកាលបរិច្ឆេទនៃការចាប់ផ្តើមបក្សកុម្មុយនីស្តកម្ពុជា។ ដែលនិយាយថា ត្រូវបានបង្កើតឡើងនៅឆ្នាំ១៩៥១ ទេ ប៉ុន្តែគេចង់ប្តូរថាមក៦០ វិញ ដែលជាកាលបរិច្ឆេទត្រឹមត្រូវ។ អ្វីដែលនៅពេលនោះគឺជាមូលដ្ឋាននោះ ពីហេតុការណ៍នោះ គឺពេលដែលគាត់បានចូលទៅជា

សមាជិកគណៈមជ្ឈិមនៅពេលទីមួយ ជាមួយនឹង អៀង សារី ហើយនិង កុយ ធួន ផងដែរ។

ក្រុមនេះបង្កើតបានជា១ភាគីមួយ ប៉ុន្តែមិន ជាភាគីទេ ប៉ុន្តែមិនបានមើលឯកសារនៅក្នុងដីកាដំណោះស្រាយ ប៉ុន្តែនៅក្នុងសៀវភៅជាក្រុមដែលសំខាន់នៅក្នុងគណៈមជ្ឈិមនោះ ដែលថាគេមិនអាចបំបែកបានទេអ្នកទាំងនេះ នៅក្នុងនេះ។ នេះជាកិច្ចប្រជុំ ជាកន្លែងមួយនៅក្នុងគណៈមជ្ឈិម។ នេះគឺបក្សកុម្មុយនីស្តកម្ពុជាគឺចង់ចាប់ផ្តើមចេញ គឺទាំងសកម្មភាព ហើយនិងឲ្យមានសំណើដែលថាសមស្របចំពោះកម្ពុជា។ ហើយមិនឲ្យស្ថិតនៅក្រោមការណែនាំរបស់វៀតណាម ឬក៏បក្សកុម្មុយនីស្តឥណ្ឌូចិននោះទេ។ នេះជាចំណុចសំខាន់។ សូមអរគុណ។

[០៩:៥៤:៥៥]

**ស៖** សូមអរគុណ។ ឥឡូវនេះចូលទៅដល់ចំណុចសំខាន់ គឺកាលបរិច្ឆេទសំខាន់មួយដែលលោកសាស្ត្រាចារ្យគិតថា បែបនោះគឺនៅក្នុងឆ្នាំ១៩៦២ ហើយទាក់ទងទាំងនៅក្នុងសៀវភៅបងទីមួយ ហើយនិងសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា ខ្ញុំនឹងអានអំពីផ្នែកមួយនៅក្នុងសៀវភៅសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជានោះ នៅ ERN 00193209 នេះគឺជាអង់គ្លេស ជាភាសាអង់គ្លេសទេ គឺភាសាខ្មែរមិនមាន។ យើងមានខ្លឹមសារដូចខាងក្រោមនេះ៖

"បន្ទាប់ពីកាលបរិច្ឆេទនេះ គឺបក្សកុម្មុយនីស្តនៅតំបន់គឺថា ខ្លាចសម្តេច សីហនុ ហើយគឺថាឯកសារបានយោងទៅថា ជាសមាជ ប៉ុន្តែគេធ្វើសេចក្តីសម្រេចដើម្បីបញ្ជាក់ថា សាឡុត ស គឺជាលេខាបក្សរបស់មជ្ឈិមបក្សជំនួស ទូ សាមុត។ ឥឡូវនេះ គឺថា ទូ សាមុត ត្រូវបានគេសម្លាប់ គឺថានៅក្នុងគណៈកម្មការធំនេះគឺថា បញ្ញវន្តដែលបានធ្វើការមកពីបារាំង គឺថាទីបី អៀង សារី ទី១០, ១៣ សុនសេន, សឺង ង៉ុកមិញ ត្រូវបានបោះឆ្នោតដោយអវត្តមាន ហើយ វន វ៉េត បានចូលក្នុងគណៈអចិន្ត្រៃយ៍នេះជាលើកដំបូង។

ហើយនឹងខ្ញុំសូមអានក្នុងគោលបំណងការបន្ត ដើម្បីនឹងសួរសំណួរលោកហ្នឹងគឺទាក់ទងអំពីសៀវភៅបងទីមួយគឺ ឯកសារ -- ខ្ញុំសូមអភ័យទោសផ្នែកដែលខ្ញុំអាននោះគឺថា អំមិញហ្នឹងមកពីសៀវភៅបងទីមួយ គឺថា E3/17។

[០៩:៥៦:៤៩]

បាទ សូមអភ័យទោស ខ្ញុំមានកំហុសមួយ។ នោះជា សៀវភៅមកពីសោកនាដកម្មទេ បាទ សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា គឺថា E3/17 បាទ មានជាភាសាខ្មែរ និងអង់គ្លេស ERN គឺ

00392977 រហូតទៅដល់ 8, ខ្មែរ ERN 00821727។ ខ្ញុំនឹងនិយាយដោយសង្ខេបអំពីសេចក្ដីដកស្រង់នេះ លោកបាននិយាយថា៖ “នៅពេលនោះ សាឡុត ស ហើយនិង សារី គឺជាសមាជិកជាន់ខ្ពស់របស់បក្ស ហើយសមាជបក្សហ្នឹង គឺបានប្រារព្ធឡើងក្រោយពីមានហេតុការណ៍នៅសៀមរាប ក្រោយមកគឺ សាឡុត ស បានជំនួស ទូ សាមុត ហើយ នួន ជា ទទួលតំណែងទីពីរ”។

ហើយនៅខាងក្រោម នៅក្នុងផ្នែកនេះដែរនៅក្នុងទំព័រដដែលនេះ លោកបាននិយាយថា៖ “អ្វីដែលសំខាន់ចំពោះសមាជនេះ គឺថាបានបញ្ជាក់ សាឡុត ស, នួន ជា និង អៀង សារី នៅក្នុងតំណែងមួយនៅក្នុងឋានានុក្រមរបស់បក្ស ហើយរក្សាតំណែងហ្នឹងជារៀងរហូតមក”។ ហើយសូមអភ័យទោសដែលថា ខ្ញុំដកស្រង់នោះផ្លោះឡើងផ្លោះចុះ។ ហើយសូមឲ្យលោក បំភ្លឺជូនតុលាការអំពីសារៈសំខាន់អំពីកិច្ចប្រជុំឆ្នាំ១៩៦២ ក្រោយពីបាត់ខ្លួន ទូ សាមុត ហើយដែលលោកថា ការដាក់សមាជិកថ្មីទៅក្នុងគណៈមជ្ឈិមបក្សថ្មីមាន ប៉ុល ពត, នួន ជា, អៀង សារី នេះបាទ។

[០៩:៥៨:៣៤]

**ឆៈ** ហើយខ្ញុំមិនមានអ្វីច្រើន ដើម្បីពន្យល់បន្ថែមទេ។ ថ្នាក់ដឹកនាំនេះជាក្រុមមួយរបស់បក្សដែលថា បញ្ហាមួយចំនួន ហើយមានភាពមិនច្បាស់លាស់។ ក្រោយមក អៀង សារី ឬក៏ សុន សេន ជាលេខបីនោះក៏មិនមានបញ្ហាទេ។ សុន សេន ក៏នៅក្នុងក្រុមមេដឹកនាំនេះដែរ។ ហើយចាប់ផ្ដើមបង្រួមគ្នានេះ ខ្ញុំគិតថា អ្នកសរសេរផ្សេងទៀត បាននិយាយថា ដូចជា រដ្ឋប្រហាររបស់ពួកបញ្ញវន្តមកពីប្រទេសបារាំងដែលថា នួន ជា មិនធ្លាប់ទៅប្រទេសបារាំងទេ គាត់ជាមនុស្សទីពីរ ក្នុងរយៈពេលយូរ ហើយមិនស្ថិតនៅ ថាមិនស្ថិតនៅក្រុមបញ្ញវន្តមកពីប្រទេសបារាំងនោះទេ។ មិនអាចធ្វើឲ្យមានការភ័ន្តច្រឡំទេ។ ដូច្នេះ ចំណុចសំខាន់គឺថា ទាំងអស់មិនមែនមកពីបារាំង គឺថា មានប្អូន ដែលរាប់ទាំង សុន សេន បង្កើតបានជាមេដឹកនាំស្នូល ដែលពេលដែលខ្មែរក្រហមកាន់អំណាចនោះ។

សារៈសំខាន់នៃកិច្ចប្រជុំនេះគឺថា គេបានកាន់ -- ឡើងកាន់អំណាចក្រោយមកនោះគឺថា -- ហើយគេបានឆ្លងផុតពីការលាក់កំបាំងអត្តសញ្ញាណរបស់គេ ដូចជា ម៉ៅ សេទុង កាលពីកុមារភាពផ្សេង ប៉ុន្តែឥឡូវនេះគេចេញមុខមកនៅក្នុងរចនាសម្ព័ន្ធ ពីព្រោះថាគេបានសង្ឃឹមថា នឹងកាន់អំណាច។ នេះហើយជាមូលហេតុដែលគេបង្កើតបក្សរបស់គេ ដើម្បីទទួលការជោគជ័យ។ ពួកគេមានសុទិដ្ឋិនិយម ហើយមានអ្នកគាំទ្រជាច្រើននៅខាងក្រៅ ដែលមិនមានការរំពឹងដូចពួកគាត់នោះទេ។

[១០:០០:៣០]

**ស៖** សូមអរគុណចំពោះការឆ្លើយដោយសង្ខេបរបស់គាត់នេះ។ ឥឡូវនេះយើងនឹងត្រឡប់ទៅមុខ គឺថាយើងផ្លាស់ចោលច្រើនឆ្នាំ ដោយសារយើងគ្មានពេលគ្រប់គ្រាន់ ហើយយើងៗ និយាយអំពីឆ្នាំ ១៩៦២ ហើយមកដល់៦០ ហើយនិង៦៧ នៅក្នុងសៀវភៅនេះទំព័រទី៥ ដែលពាក់ព័ន្ធនោះ ដើម្បីសន្សំពេល គឺថាមានខ្លឹមសារសំខាន់ៗនៅទីនេះ ប៉ុន្តែខ្ញុំនឹងអានខ្លីៗ ចំណុចសំខាន់ៗ ពីសៀវភៅដែលមានចំណងជើងថា "បងទី១"។ ERN ជាភាសាអង់គ្លេស 00392988 ហើយខ្មែរ ERN 00821739។

លោកសាស្ត្រាចារ្យ លោកបាននិយាយនៅទីនេះថា ខ្ញុំសូមដកស្រង់ លោកបាននិយាយអំពីឆ្នាំ ១៩៦៦ ជាវគ្គសិក្សា ដែលលោកនិយាយថា បានធ្វើឡើងនៅទីបញ្ជាការនៅរតនគិរី លោកនិយាយថា សូមដកស្រង់៖ "សង្គ្រាមវៀតណាមដែលកាន់តែខ្លាំងទាក់ទងទៅនឹងកម្ពុជា ធ្វើឱ្យវគ្គសិក្សាឆ្នាំ៦៦ នេះជាសំខាន់ ជាពិសេសបក្សកុម្មុយនីស្តកម្ពុជា ធ្វើឱ្យ សាឡុត ស ដែលថាយុទ្ធសាស្ត្ររបស់បក្សត្រូវតែប្តូរ"។

[១០:០២:០៧]

បន្ទាប់មកនៅខាងទំព័រខាងលើហ្នឹងលោកបាននិយាយថា៖ "សាឡុត ស ហើយនិងអ្នកផ្សេងទៀតបានធ្វើសេចក្តីសម្រេចយុទ្ធសាស្ត្រពីរ នៅក្នុងវគ្គសិក្សាឆ្នាំ១៩៦៦។ គេប្តូរឈ្មោះបក្សអំពីបក្សបដិវត្តន៍ពលករទៅជាបក្សកុម្មុយនីស្តកម្ពុជា ហើយគេបានប្តូរសមាជិកទៅតំបន់ដាច់ស្រយាលនៅរតនគិរី នៅក្នុងភូមិភាគឦសាននៃប្រទេសកម្ពុជា"។ តើលោកអាចជម្រាបយើងខ្ញុំបានទេ ដោយសង្ខេបថា ហេតុអ្វីបានជាលោកចាត់ទុកថា គាត់ទិចយុទ្ធសាស្ត្ររបស់បក្សនៅនេះ គឺថាមេដឹកនាំបានប្តូរយុទ្ធសាស្ត្រ ហើយរួមទាំងប្តូរឈ្មោះបក្សផង ហើយនិងបញ្ជូនសមាជិកបក្សដើម្បីទៅធ្វើការនៅជនបទនោះ?

**ឆ៖** គឺថាហេតុការណ៍នៅឥណ្ឌូនេស៊ី នៅឆ្នាំ១៩៦៥, ៦៦ នោះគឺថាជាកម្មុយនីស្តដែលរដ្ឋាភិបាលឥណ្ឌូនេស៊ីបានបំបាត់។ អាហ្នឹងគឺជាចំណុច។ ហើយនេះហើយគឺជាសញ្ញាមួយដែលប្រាប់មកកម្ពុជា ដែលថាអាចនឹងរដ្ឋាភិបាលបោសសម្អាតបំបាត់ នេះជាក្រុមតូច។ អ៊ីចឹងហើយដែលធ្វើឱ្យមេដឹកនាំបក្សហ្នឹងគេប្តូរយុទ្ធសាស្ត្រដែលថាពួកគេសម្រេចដកខ្លួនចេញពីមន្ទីរ១០០ ទៅកន្លែងផ្សេងដែលមានសុវត្ថិភាព។ ខ្ញុំគិតថា ពួកគេមិនធ្វើប្រតិបត្តិការដោយចំហនៅក្នុងកម្ពុជាទៀតទេ ដោយសារគេអាចមានគ្រោះថ្នាក់ ប៉ុល ពត គឺធ្វើការដោយសម្ងាត់ ហើយក៏បានបាត់ខ្លួន -- ដោយលាក់ខ្លួន។

[១០:០៤:០៤]

នេះ គឺជា -- នៅក្នុងតំបន់នេះហើយ មូលដ្ឋាននេះហើយ នៅក្នុងឦសាននៃប្រទេសកម្ពុជា

ប្រហែលជាបីឆ្នាំ ជាងបីឆ្នាំ ជាមូលដ្ឋាននោះគឺយើងមិនដឹងថាពួកគាត់ធ្វើអីទេ។ ខ្ញុំគិតថា ពួកគេធ្វើផែនការរៀបចំនយោបាយ គឺថានៅពេលដែលគេកាន់អំណាច គេត្រូវធ្វើម៉េច ហើយគេលាក់ខ្លួនពីនគរបាលរបស់សម្តេច សីហនុ ហើយគេនឹងបង្កើតរួបរួមសមាជិកបក្ស ហើយនិងបង្កើតនូវកម្លាំង ហើយគេជ្រើសរើសសមាជិកនៅតំបន់រតនគិរីនេះ គាត់បានជ្រើសរើសសមាជិកជាជនជាតិភាគតិចជាច្រើន។ នេះជាការកែប្រែដ៏សំខាន់បក្សនោះ។ ចំណុចសំខាន់ ខ្ញុំមិនបានបញ្ជាក់ក្នុងសៀវភៅទេ គឺជាហេតុការណ៍ ដែលថាគេចូលរួមជាមួយវៀតណាម ដែលថាយើងដឹងទាំងអស់គ្នា ភាគច្រើននោះគឺថាអ្វីដែលកើតឡើងនៅឥណ្ឌូនេស៊ីនោះគឺថា គឺបក្សកុម្មុយនីស្តមិនសូវចាប់អារម្មណ៍ទេ។ គេគ្រាន់តែថា យើងប្តូរយុទ្ធសាស្ត្រ ហើយយើងបន្តធ្វើការងារដើរតួទាក់ទងទៅនឹងសង្គ្រាមវៀតណាម ដើម្បីការពារខ្លួនយើង គឺថាយើងត្រូវធ្វើដូចម្តេចដើម្បីចៀសវាងបញ្ហាកុំឲ្យដូចនៅឥណ្ឌូនេស៊ី គឺមិនបានបញ្ជាក់ទេ ពីព្រោះនៅទីនេះគឺថា នៅឥណ្ឌូនេស៊ី គឺថាកុម្មុយនីស្តនៅទីនោះ គេបានចាប់ -- នៅឥណ្ឌូនេស៊ីហ្នឹង គឺថាមនុស្សរាប់ពាន់ត្រូវបានគេដាក់គុកដោយរដ្ឋាភិបាលនោះ។

[១០:០៥:៤១]

**ស៖** លោកបានបញ្ជាក់នៅពេលនេះថា ផ្អែកទៅលើការសិក្សារបស់លោក គឺថាបក្សគឺផ្អែកទៅលើការងាររបស់ខ្លួនសម្រាប់កាន់អំណាច ហើយក៏បានចំណាយពេលបីឆ្នាំជាង ហើយនៅក្នុងសៀវភៅរបស់លោក សៀវភៅបងទីមួយ ហើយនិងសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជានោះ និយាយអំពីការបះបោរនៅសំឡូត។ ហើយបន្ទាប់មកទៀត អំពីអរិភាពនៅក្នុងខែមករា ឆ្នាំ១៩៦៨ ដែលកើតឡើងជាបន្តបន្ទាប់ដែលលោកនិយាយថា ជាកំណើតរបស់កងទ័ពបដិវត្តន៍កម្ពុជាកើតឡើងបន្ទាប់ពីនោះ ឬក៏ក្នុងពេលនោះ។ ប្រហែលជាខ្ញុំចង់ពឹងផ្អែកទៅលើការចងចាំ តើលោកអាចបញ្ជាក់បានទេ តើខ្ញុំត្រូវអានជូនលោកស្តាប់ ឬក៏ដូចម្តេច? តើលោកបញ្ជាក់ដោយសង្ខេបជូនតុលាការអំពីហេតុការណ៍ដ៏សំខាន់ទាក់ទង

ទៅនឹងការតស៊ូប្រដាប់អាវុធរវាងឆ្នាំ១៩៦៧ និង៧០ហ្នឹង បានឬទេ?

**ឆ៖** ការចាប់ផ្តើមតស៊ូប្រដាប់អាវុធនេះសំខាន់ហ្នឹង គឺទៅតាមប្រវត្តិសាស្ត្ររបស់បក្សកុម្មុយ-នីស្តកម្ពុជា គឺទោះបីជាមានអាវុធតិចតួចដែលគេបានទទួលពីនគរបាល -- ចាប់យកពីនគរបាលនៅបាត់ដំបង ក៏ប៉ុន្តែមិនមានអ្វីសំខាន់ដាច់ខាតទាក់ទងទៅនឹងបក្សកុម្មុយនីស្តកម្ពុជា ហើយនិងពួកបះបោរសមាជិករបស់បក្ស បដិសេធថាខ្លួនមិនមានការទំនាក់ទំនងទេ គឺវាមានការ មានការបះបោរដែលធ្វើឡើងដោយបុគ្គលម្នាក់ៗ ដែលគេមិនពេញចិត្តនឹងនយោបាយរដ្ឋាភិបាលនៅពេលនោះ។

[១០:០៧:៥៣]

សីហនុ បានមើលឃើញថា ការបះបោរនៅសំឡូត ថានៅក្នុងសៀវភៅនេះ ខ្ញុំបាននិយាយដែរ នេះជាលើកទីមួយដែលថាប្រជាជនខ្មែរ ដោយមិនមានយកគំរូតាមពីអ្នកខាងក្រៅទេ ហើយគេចាត់ទុកថាជាខ្មាំងរបស់របប សីហនុ ទេ គឺគេចាត់ទុកថា ធ្វើឲ្យមានការភ័យខ្លាច ហើយពួកគេព្យាយាមនឹងបះបោរឡើង។ ហើយកម្លាំងនៅកម្ពុជានោះកម្រនឹងបះបោរណាស់ពីមុនមក។ ខ្ញុំមិនបាននៅក្នុងកិច្ចប្រជុំទេ ថាតើខ្ញុំមិនបាននៅក្នុងការប្រជុំនោះទេ គឺថាការទទួលខុសត្រូវរបស់ ប៉ុល ពត ហើយនិងកម្មាភិបាលរបស់គាត់ គឺថាយើងត្រូវតែបន្តការតស៊ូប្រដាប់អាវុធ។ បើមិនដូច្នោះទេ គឺយើងមិនបាច់មិនអាចដើរទៅមុខបានទេ។

ឆ្នាំ១៩៦៨-៦៩ គឺថាយើងឃើញមានការប៉ះទង្គិចគ្នារវាងកងទ័ព រវាងនឹងប្រជាជននៅតាមជនបទ ហើយក៏គេព្យាយាម -- នេះហើយគឺជាការចាប់ផ្តើមនៃសង្គ្រាមស៊ីវិលប្រឆាំងនឹងរបប សីហនុ ហើយនិងក្រោយមកដោយ លន់ នល់ ផងដែរ។

[១០:០៩:២១]

**សះ** ឥឡូវសូមចូលទៅដល់អំឡុងពេលឆ្នាំ១៩៧០។ ហើយលោកក៏បានសរសេរនៅក្នុងសៀវភៅនិយាយអំពីសោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា នៅក្នុងជំពូកទី៧ និងសៀវភៅនិយាយអំពីបងធំទី១ នៅជំពូកទី៥។ ខ្ញុំនឹងមិនអាននូវខ្លឹមសារដ៏វែងនៅក្នុងសៀវភៅទាំងនេះទេ។ ខ្ញុំគ្រាន់តែលើកឡើងយកព្រឹត្តិការណ៍មួយចំនួននៅក្នុងសៀវភៅទាំងនេះ។ ប៉ុន្តែសំខាន់បំផុតនោះ លោកបានរៀបរាប់នៅក្នុងសៀវភៅអំពីបងធំទី១ ដែលមាន ERN ជាភាសាអង់គ្លេស 00392998, ហើយ ERN ជាភាសាខ្មែរ 00821751។

លោកបានរៀបរាប់អំពីព្រឹត្តិការណ៍ទាំងនោះដូចតទៅ តាំងពីរដ្ឋប្រហារខែមីនា ឆ្នាំ៧០ ដែលធ្វើឡើង លន់ នល់ និង សិរិមតៈ ហើយលោកក៏និយាយអំពីវត្តមានរបស់ សាឡុត ស នៅទីក្រុងប៉េកាំងក៏ដូចជាការទំនាក់ទំនងគ្នានៅពេលនោះ ហើយក៏ដូចជាបញ្ហាមួយចំនួនដែលបានផ្សព្វផ្សាយតាមវិទ្យុនៅថ្ងៃទី២៣ ខែមីនា ដោយសម្តេច នរោត្តម សីហនុ។ ខ្ញុំមិនចង់រៀបរាប់លម្អិតនៅចំណុចទាំងអស់នេះទេ ប៉ុន្តែខ្ញុំសូមដកស្រង់តែមួយចំណុចទេ ដើម្បីឲ្យលោករៀបរាប់អំពីចំណុចសំខាន់ៗទៅលើចំណុចនេះ។

[១០:១១:២៤]

អ៊ីចឹងយើងមើលទៅលើសៀវភៅស្តីអំពី “បងធំទី១” នៅត្រង់ជំពូក៦ ដែលមាន ERN ជាភាសា

អង់គ្លេស 00393001, ជាភាសា -- ERN ជាភាសាខ្មែរ 00821752 ដល់ 3។ លោកបានរៀបរាប់ដូចខាងក្រោមនេះ "សាឡុត ស មិនបានលេចមុខមកពីការលាក់ខ្លួនទេ ហើយប៉ុន្មានឆ្នាំមុននោះ ក៏គាត់មិនបានបង្ហាញមុខទៅដល់រណសិរ្សរួបរួមជាតិរបស់ សីហនុ ដែរ។ ប៉ុន្តែនៅក្នុងប្រទេស គឺថាអំណាចស្ថិតនៅក្នុងដៃខ្មោចទាំងបី ដែលធ្វើការតំណាងឲ្យ នរោត្តម សីហនុ។ សីហនុ បានឆ្លើយតបមកពីទីក្រុងប៉េកាំង មក ដែលថាគាត់គ្រាន់តែជាមេដឹកនាំដែលមានតែឈ្មោះតាំងពីដើមទីមកម្ល៉េះ"។ ហើយក្រោយមកទៀតនៅក្នុងកថាខណ្ឌដដែលនេះ "ការបោះពុម្ពផ្សាយរបស់រណសិរ្ស គឺថាបោះពុម្ពនៅនឹងផ្សព្វផ្សាយនៅបោះពុម្ពនៅប៉េកាំង ហើយការប្រយុទ្ធនៅក្នុងប្រទេសកម្ពុជា គឺថាគឺប្រយុទ្ធដើម្បីសម្តេចតែប៉ុណ្ណោះ"។

[១០:១២:៤១]

អ៊ីចឹងទាក់ទងទៅនឹងព្រឹត្តិការណ៍ដូចតទៅនេះហ្នឹង សេចក្តីសម្រេចក្នុងការបង្កើតរណសិរ្ស ហើយនិងការលេចឡើងរបស់រណសិរ្ស ហើយនិងអ្វីដែលលោកបានរៀបរាប់ថា សម្តេច នរោត្តម សីហនុ គ្រាន់តែជាមេដឹកនាំដែលមានតែឈ្មោះប៉ុណ្ណោះ សូមឲ្យលោកបកស្រាយចំណុចនេះ។

**ឆ៖** នេះជាសំណួរមួយដែលពិបាកណាស់។ ជាចំណុចដែលខ្ញុំមិនបានសិក្សាឲ្យបានលម្អិតនៅឡើយនោះទេ។ តាមការយល់ឃើញរបស់សម្តេច នរោត្តម សីហនុ គឺថារដ្ឋប្រហារនេះ ធ្វើ -- គឺគាត់មានការភ្ញាក់ផ្អើលនៅពេលដែលគាត់យាង -- ព្រះអង្គយាងទៅដល់ប៉េកាំង ព្រះអង្គបានធ្វើសេចក្តីសម្រេចចិត្តចម្រូងចម្រាសមួយចំនួន នៅពេលដែលគាត់បានជួបជាមួយ ផូ អេនឡាយ ដែលជាមិត្តភក្តិរបស់ព្រះអង្គរាប់ឆ្នាំមកហើយ។ ដើម្បីថាតើគាត់ត្រូវធ្វើ ឲ្យព្រះអង្គធ្វើយ៉ាងម៉េចដើម្បីវៃបកជាមួយនឹងកងទ័ពរបស់ លន់ នល់ វិញ។ ប៉ុល ពត បានទៅដល់ប៉េកាំង មិនដឹងនិយាយពីអីទេ ប៉ុន្តែគាត់បានទៅដល់ប៉េកាំងមែន។ គាត់បានចាកចេញពីហាណូយមកយ៉ាងឆាប់រហ័ស។ ហើយក្រោយពីការបង្កើតរណសិរ្ស គឺថា ប៉ុល ពត គាត់បានលាក់ខ្លួនរបស់គាត់។ នេះ គឺជាសេចក្តីសម្រេចមួយដើម្បីបង្កើតរណសិរ្ស ដើម្បីឲ្យសម្តេច នរោត្តម សីហនុ ធ្វើជាប្រមុខដឹកនាំរណសិរ្សនេះ។

[១០:១៤:១១]

នេះ គឺជាមធ្យោបាយមួយដែលធ្វើឲ្យគាត់ទទួលបាននូវកិត្យានុភាព ហើយវាជាការពិតណាស់ដែលថា គាត់គឺជានិមិត្តរូបរបស់ប្រជាជនកម្ពុជា ហើយតាមដែលការ -- ដូច្នេះទស្សនៈនេះ គឺថាវាហាក់បីដូចជាមានលក្ខណៈផ្ទុយគ្នា។ ដូច្នេះ អំឡុងពេលនៃការបង្កើតរណសិរ្សនេះ គួរឲ្យចាប់អារម្មណ៍ណាស់។ សីហនុ គាត់បានចេញមុខជាសាធារណៈក្នុងនាមជាមេដឹកនាំរបស់រណសិរ្ស។ គាត់បានប្រាប់

ទៅអ្នកកាសែតជាច្រើន គាត់បានចងក្រងឯកសារ ដែលថាគាត់មានទំនាក់ទំនងមិនល្អទាល់តែសោះជាមួយនឹង អៀង សារី គាត់មិនបាន -- ព្រះអង្គមិនបានដឹងអំពីកម្មវិធីរបស់បក្សកុម្មុយនីស្តកម្ពុជាឲ្យបានច្បាស់លាស់នោះទេ។ ប៉ុន្តែគឺថា ព្រះអង្គបានសរសេរថា ព្រះអង្គមិនពេញចិត្តចំពោះបក្សកុម្មុយនីស្តកម្ពុជា។ នេះជារយៈពេលមួយដែលគួរឲ្យចាប់អារម្មណ៍បំផុត។ រណសិរ្សនេះគឺថា មិនមានខ្លឹមសារអីឲ្យសំខាន់សម្រាប់ប្រជាជនកម្ពុជាជាងបក្សកុម្មុយនីស្តកម្ពុជានោះទេ ដែលតាមការពិតទៅគឺថា ខ្មោចទាំងបីនេះគឺជាអ្នកបំពេញកិច្ចការទាំងអស់នេះជំនួសឲ្យព្រះអង្គតែប៉ុណ្ណោះ។ ព្រះអង្គមិនបានដឹងអំពីគោលនយោបាយ ដែលបានរៀបចំចាត់ចែងដោយបក្សកុម្មុយនីស្តកម្ពុជា ជាសម្ងាត់ដោយបក្សកុម្មុយនីស្តកម្ពុជានោះទេ។

[១០:១៥:៤៩]

**ស៖** *(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

សូមអរគុណលោកអ្នកជំនាញ ហើយដោយសារមានសំណូមពរពីខាងអ្នកបកប្រែ សុំឲ្យលោកអ្នកជំនាញនិយាយឲ្យបានយឺតជាងនេះ ពីព្រោះអ្នកបកប្រែៗ បកមិនទាន់ទេបាទ។

សូមអញ្ជើញបន្តលោកតំណាងសហព្រះរាជអាជ្ញា!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។--

**លោក ដេវីដ ឆេនដ័ល័រ៖**

សូមអរគុណលោកចៅក្រម។ ភរិយាខ្ញុំគាត់បានជម្រាបមកខ្ញុំដែរ មុននឹងខ្ញុំមកទីនេះគាត់ថា សូមឲ្យខ្ញុំនិយាយយឺតៗ។ សូមអញ្ជើញ!

[១០:១៦:៣៤]

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ខ្ញុំសូមសួរសំណួរមួយទៅលោកអ្នកជំនាញ និយាយអំពីរចនាសម្ព័ន្ធ -- ហេដ្ឋារចនាសម្ព័ន្ធរបស់បក្ស។ សារដែលខ្ញុំបានអាននេះ គឺលោកបានបញ្ជាក់ថា សម្តេច នរោត្តម សីហនុ គឺជាប្រមុខដឹកនាំដែលមានតែឈ្មោះ តែតាមការពិតគឺអំណាចដឹកនាំគឺនៅក្នុងដៃរបស់ សាឡុត ស ។ លោកក៏បានបញ្ជាក់ថា អំណាចទាំងអស់ -- កិច្ចការទាំងអស់គឺបំពេញឡើងដោយខ្មោចទាំងបី។ បើសិនណាជាលោក

ធ្វើការសិក្សាស្រាវជ្រាវទៅលើចំណុចនេះ លោកតើអាចបកស្រាយបានទេ ថាតើខ្មោចទាំងនេះជាអ្នកណានៅពេលដែលលោករៀបរាប់នៅពេលនោះ? ពិសេសនៅដើមទសវត្សរ៍ឆ្នាំ១៩៧០ នោះ សូមឲ្យលោកបញ្ជាក់ចំណុចខ្មោចទាំងបីនោះបន្តិច។

[១០:១៧:៣៧]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ពួកគាត់ទាំងបីនោះ គឺថាកាន់កាប់អំណាចអ្វីដែលគេ -- គាត់ -- អ្វីដែលពួកគេអាចធ្វើបានដោយឯករាជ្យនៅក្នុងប្រទេសនេះ។ ប៉ុន្តែតាមដែលខ្ញុំមើល គឺថាមានការសម្រេចនៅខាងក្រោយអ្នកទាំងបីនេះទៀត។ អ្នកទាំងបីនេះ គឺថាទទួលបានតួនាទីឋានៈអំណាច ប៉ុន្តែយើងមិនបានដឹងថា អ្នកទាំងបីនេះត្រូវបានគេប្រាប់ឲ្យធ្វើយ៉ាងម៉េចៗនោះទេ។

**ស៖** សូមអរគុណលោកអ្នកជំនាញ។ ចូលទៅដល់ឆ្នាំ១៩៧១ វិញ យើងបានជួបប្រទះការពិភាក្សាមួយចំនួនទៅលើគោលនយោបាយ ដែលលោកបានសិក្សាមកពីឯកសាររបស់បក្សនោះ យើងមើលទៅលើសៀវភៅបងធំទី១ ជំពូក៧ គឺឯកសារ E3/17។ ERN ជាភាសាអង់គ្លេស 00393008, ខ្មែរ ERN 00821759, ជាភាសាអង់គ្លេសគឺថា លេខបីខ្ទង់ចុងក្រោយគឺ 008 លោកអ្នកជំនាញ។ ក្រោយឆ្នាំ១៩៧០ ឯកសាររបស់បក្សគឺមាននិយាយច្រើនអំពីបញ្ហាវណ្ណៈ តស៊ូវណ្ណៈ គឺបានបញ្ជាក់ថា "កម្មាភិបាលត្រូវជ្រើសរើសចេញអំពីកសិករក្រីក្រ ពីអ្នកដែលមានប្រវត្តិក្រីក្រ ពីជនបទដាច់ស្រយាលត្រូវយកពួកគាត់ចេញមកពីតំបន់ទាំងនោះ ដូចដែលយើងយកពេជ្រចេញមកពីក្នុងដីដូច្នេះដែរ។ យើងចៀសវាងកុំយកពួកវណ្ណៈមូលធន ពួកវណ្ណៈអភិជន។" គឺថាឯកសារទាំងនេះ បានបញ្ជាក់អំពីគោលនយោបាយអំពីវណ្ណៈ ដូច្នេះសូមឲ្យលោកបកស្រាយចំណុចនេះ។

[១០:២០:០០]

**ឆ៖** បាទ ដូចខ្ញុំបានជម្រាបពីខាងដើមដូច្នោះដែរ។ មិនមានភស្តុតាងដោយផ្ទាល់ណាដែល

ច្បាស់លាស់នេះ គឺថាថ្នាក់ដឹកនាំបក្សបានជួបគ្នានៅរតនគិរី រៀបចំធ្វើ តាក់តែងគោលនយោបាយគេមិនដែលនិយាយថា ប្រសិនបើ គេនិយាយនៅពេលណាដែលពួកគេនឹងចូលមកកាន់អំណាច។ នេះគឺជារយៈពេលដែលអ្នកថ្នាក់ដឹកនាំ គឺគិតថាខ្លួនដូចជានៅក្នុងអំណាចដូច្នោះដែរ។ គឺពង្រីកសមាជិក -- នៅពេលពួកគាត់ពង្រីកសមាជិកភាពរបស់ខ្លួន គឺដើម្បីឲ្យចូលជាសមាជិកភាពនោះគឺថាដោយសារវាមានសង្គ្រាមស៊ីវិលជាមួយ លន់ នល់ រួចទៅហើយ។ ដូច្នេះគេមិនអាចទាក់ទាញអ្នកដែលកំពុងរៃ

ប្រយុទ្ធជាមួយខ្លួនបានទេ សម្រាប់ហេតុផលដោយសមហេតុផល គឺត្រូវតែយកអ្នកចេញពីវណ្ណៈកម្មករកសិករ។ ពេលនោះគឺថាមិនមានរោងចក្រអ្វីនោះទេ។ ដែលគេប្រៀបធៀបថា គឺពីទីកន្លែងណាដូចដែលយើង ទីកន្លែងដែលយើងជីកយកពេជ្រយកចេញពីក្នុងដីដូច្នោះដែរ។ ដូច្នេះយកពីកន្លែងណាដែលយល់ឃើញថាដែលជាតំបន់ដែលប្រជាជនគិតថាខ្លួនជាជនរងគ្រោះ ដែលជាការមួយដើម្បីឈានទៅដល់ការប្រឆាំងជាមួយនឹងរដ្ឋាភិបាលដូចជាបញ្ហាការបះបោរនៅសំឡូតដូច្នោះដែរ។

[១០:២១:៣៦]

**ស៖** ខ្ញុំសូមចូលទៅដល់បញ្ហា ដែលលោកបានលើកយកមកពិភាក្សាជាថ្មីម្តងទៀត គឺនិយាយអំពី "បងធំទី១" នៅត្រង់ចំណុចនេះគឺថាលោកនិយាយថា "ក្បាលម៉ាស៊ីនដឹកនាំនោះគឺថ្នាក់ដឹកនាំនោះបានផ្លាស់ពីរតនគិរីមករកតំបន់មួយជិតភ្នំសន្ទុកនៅព្រំប្រទល់ខេត្តកំពង់ធំ"។

ព្រឹត្តិការណ៍ដែលលោកលើកឡើងទាក់ទងនឹងបងធំទី១ នៅក្នុងជំពូក៦ ERN ជាភាសាអង់គ្លេស 00393005 ERN, ជាភាសាខ្មែរ 00821756។ គឺនៅខែកក្កដា ១៩៧៦ ដែលមានសន្និបាត -- ដែលមានខ្លឹមសារសន្និបាត -- នៅក្នុងសន្និបាតនោះគឺមានខ្លឹមសារដូចតទៅ៖ "នៅក្នុងខែកក្កដា ឆ្នាំ១៩៧៦ សន្និបាតសម្រាប់កម្មាភិបាលទូទាំងប្រទេសមានកម្មាភិបាលថ្នាក់ដឹកនាំប្រហែលជា ៦០នាក់ នៅ -- ធ្វើឡើងនៅក្នុងព្រៃ នៅភាគខាងត្បូង។ សាឡុត ស គឺជាអ្នកដឹកនាំសន្និបាតនេះ វាជាការចូលរួមប្រជុំរបស់សមាជិកគណៈកម្មាធិការមជ្ឈិម ដែលឈានចូលទៅដល់ពេលមួយថ្មីនៃបដិវត្តន៍កម្ពុជា ដើម្បីផ្តួលរំលំពួកចក្រពត្តិ ពួកមូលធន"។

[១០:២៣:២៥]

ហើយខាងក្រោមមកទៀតនៅក្នុងសារដដែលនេះ លោកបានលើកឡើងថា "ដោយមិនបាននិយាយអំពីបញ្ហាវៀតណាមនោះ គឺបដិវត្តន៍" សូមដកស្រង់៖ "ត្រូវតែធ្វើអ្វីសមស្របសម្រាប់ប្រទេសរបស់យើង ហើយថ្នាក់ដឹកនាំបក្សក៏មិនត្រូវបញ្ចេញឈ្មោះឲ្យគេដឹងដែរ ដើម្បីគោលបំណងនៃបដិវត្តន៍នេះឯង"។

លោកបានយោងទៅលើព្រឹត្តិប័ត្ររបស់បក្ស ដែលបានសរសេរឡើងអំពីសន្និបាតនៅពេលនោះ។ សំណួររបស់ខ្ញុំគឺដូចតទៅនេះ តើចំណុចសំខាន់ ឬក៏ថាទីមួយ តើទស្សនៈរបស់បដិវត្តន៍កម្ពុជាក្នុងការផ្តួលរំលំពួកចក្រពត្តិមូលធននិយមនៅពេលនោះគឺលោកចង់មានន័យថាម៉េច? ហើយតើចំណុចនេះវាមានខ្លឹមសារ ឬក៏សារៈសំខាន់អ្វីដែរនៅក្នុងអំឡុងពេលនោះ?

[១០:២៤:៣៤]

**ឆ៖** នៅខែកក្កដា ឆ្នាំ៧១ ថ្នាក់ដឹកនាំបានដឹងអំពីចំណុចពីរហើយ។ ទីមួយគឺដោយសារតែការវាយលុកយ៉ាងសន្ធាប់របស់ លន់ នល់ ដូច្នេះវៀតណាម ដែលបានគាំទ្រដោយខ្មែរក្រហម នៅក្នុងដំណាក់កាលនេះគឺគេដឹងថា -- គេប្រមើលមើល ឃើញអំពីជ័យជម្នះហើយ។ ដូច្នេះ គាត់យល់ឃើញថា -- ថ្នាក់ដឹកនាំយល់ឃើញថា បដិវត្តន៍របស់ខ្លួន -- តាមការពិតមិនមានការពិភាក្សាអីទេ គឺថាយើង -- គេបាននិយាយថា នឹងឈានចូលដំណាក់កាលមួយថ្មី គឺថាបដិវត្តន៍នឹងអាចផ្តួលរំលំពួកមូលធន ពួកចក្រពត្តិបានហើយ។ ឯកសារនេះគឺថា មិនបានធ្លាក់ទៅដល់ក្នុងដៃរបស់សម្តេច នរោត្តម សីហនុ ទេ ប៉ុន្តែព្រះអង្គមានទំនុកចិត្តទៅលើចំណុចនេះ ដោយសារកាលណាយើងនិយាយអំពីពួកចក្រពត្តិនិយម ពួកមូលធននិយមវា -- ចក្រពត្តិនិយមគេនិយាយសំដៅទៅលើអាមេរិក។ ពួកមូលធននិយាយគេនិយាយសំដៅទៅលើពួកអ្នកមានៗ។ ដូច្នេះ ខ្ញុំគិតថា ជាអត្ថន័យប្រកបទៅដោយសេចក្តីសម្រេចមួយ ដែលកំណត់ទៅដល់សេចក្តីថ្លែងការណ៍របស់បក្ស ដែលកំណត់ថា យើងត្រូវធ្វើដូចម្តេចនៅពេលខ្លួនចូលកាន់អំណាចនោះ។

[១០:២៦:៣៧]

**ស៖** ទាក់ទងទៅនឹងក្រុមមនុស្ស ដែលលោកទើបតែរៀបរាប់អម្បាញ់មិញនេះ។ បើយើង -- សូមមើលទៅលើកំណត់ហេតុរបស់មហាសន្និបាតមួយទៀត នៅក្នុងសៀវភៅស្តីអំពី "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ERN 00193299។ លោកបានលើកឡើងអំពីសេចក្តី ឬក៏សេចក្តីសម្រេចតែមួយ ឬក៏សេចក្តីសម្រេចផ្សេងៗទៀតរបស់មហាសន្និបាត។ ខ្ញុំសូមអានជាសង្ខេបទេ។ លោកនិយាយថា សេចក្តីសម្រេចមួយ គឺត្រូវបញ្ជូន អៀង សារី ទៅទីក្រុងប៉េកាំង និងចំណុចមួយទៀតប្រារព្ធធ្វើពេលខួប គឺរំឭកពិធីខួបថ្ងៃទី៣០ ខែកញ្ញា របស់មហាសន្និបាតឆ្នាំ១៩៦០ ដែលកំណត់អំពីថ្ងៃកំណើតថ្មីរបស់បក្ស។ នេះគឺជាអ្វីដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោក នៅត្រង់ ERN 00193299 ERN ជាភាសាអង់គ្លេស។ ប៉ុន្តែកាលបរិច្ឆេទជ្រើសរើសសម្រាប់ការប្រារព្ធធ្វើនៅតំបន់រំដោះនៅថ្ងៃទី៣០ ខែកញ្ញានោះ គឺសមាជិកថ្មីៗរបស់គណៈកម្មាធិការ គឺរួមមាន សាឡុត ស, សុន សេន និង ខៀវ សំផន បានចុះហត្ថលេខា នៅក្នុងសេចក្តីប្រកាសនេះ។ តាមខ្ញុំយល់ខ្លឹមសារត្រង់ចំណុចនេះ -- សូមកែតម្រូវខ្ញុំបើខ្ញុំយល់ច្រឡំ -- គឺមានការលើកឡើងថា សមាជិកថ្មីៗរួមមាន សាឡុត ស, សុន សេន និង ខៀវ សំផន។ តើចំណុចនេះ អាចជួយទៅដល់ការរំឭកការចងចាំរបស់លោកបានទេ អំពីការដែល ខៀវ សំផន ក្លាយទៅជាសមាជិករបស់គណៈកម្មាធិការនេះ?

[១០:២៨:៥១]

**ប្រធានអង្គជំនុំ៖**

អ្នកជំនាញកុំអាលទាន់ឆ្លើយ ចាំស្តាប់តុលាការសម្រេចពីមតិជំទាស់របស់មេធាវីការពារក្តីសិន។

សូមអញ្ជើញលោក ម៉ៃខល កាណាវាស!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ ហាក់បីដូចជា សំណួរ នេះគឺសំណួរនាំមុខដូច្នេះដែរ បើថាអាន សហព្រះរាជអាជ្ញាលោកអានខ្លឹមសារហ្នឹង សូមអានខ្លឹមសារហ្នឹងទៅ។ ដូច្នេះហាក់បីដូចជាគាត់ធ្វើការ បកស្រាយ ថាតើខ្លឹមសារនៃអត្ថបទនេះ វាមានន័យយ៉ាងដូចម្តេច? ឬក៏អាចនិយាយបានម៉្យាងទៀតថា គាត់កំពុងតែដឹកនាំ -- សួរនាំមុខទៅដល់អ្នកជំនាញនេះហើយ។ បើថា ធ្វើដូច្នេះទេ ខ្ញុំសូមសំណូមពរថា សូមឲ្យផ្អាកនូវការសួរនាំមុខបែបនេះ។ ខ្ញុំយល់ហើយថា ក្នុងគោលបំណងនេះ គឺជាគោលបំណងដើម្បី ធ្វើឲ្យអ្នកជំនាញគាត់ចងចាំឡើងវិញ ប៉ុន្តែទោះ -- បើនិយាយពី -- តាមបែបបច្ចេកទេសទៅវិញនោះ ខ្ញុំ សូមជំទាស់ពីព្រោះវាជាការសួរនាំមុខ។ សូមអរគុណលោកប្រធាន។

[១០:៣០:០៣]

**លោក អាប់ឌុលឡាក់ ចារីក៖**

លោកប្រធានតាមសំណួរនេះ គឺសមស្របហើយ ខ្ញុំសូមឲ្យលោកសាស្ត្រាចារ្យគាត់កែតម្រូវខ្ញុំ។ ដោយសារតែពេលវេលា ខ្ញុំសូមបន្តទៅមុខទៀត ហើយខ្ញុំសួរទៅត្រង់ៗទៅគាត់តែម្តង។ ឥឡូវសូម បំភ្លេចសំណួរខ្ញុំចុះ ខ្ញុំគ្រាន់តែឲ្យលោកជំនាញបញ្ជាក់អំពីសមាជិកភាពនៅក្នុងឆ្នាំ១៩៦០។

**លោក ដេវីដ ឆេនដ៍ល័រ៖**

ខ្ញុំសូមមិនឆ្លើយទៅនឹងសំណួរហ្នឹងនោះទេ។ ដោយសារខ្ញុំអត់មានសៀវភៅនេះ។

**សួរដោយលោក អាប់ឌុលឡាក់ ចារីក៖**

**ស៖** លោកសាស្ត្រាចារ្យ ថាតើក្រោយពីសម្រាក២០នាទី ឬបន្ទាប់ពីពិសាបាយថ្ងៃត្រង់ លោក អាចឆ្លើយសំណួរនេះបានទេ?

[១០:៣១:០៨]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បើសិនណាជាអ្នកណាម្នាក់មានសៀវភៅខ្ញុំមួយក្បាលនេះនៅក្នុងដៃតែម្តង ខ្ញុំអាចនឹងឆ្លើយ

ក្រោយពីឈប់សម្រាកហើយអាចឆ្លើយជូនបាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមានសៀវភៅរបស់គាត់មួយច្បាប់ បើសិនណាជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមជូនសៀវភៅរបស់គាត់នេះ ដែលខ្ញុំមាននៅក្នុងដៃនេះជូនទៅឲ្យគាត់អាន។ បើមិនដូច្នេះទេ ដើម្បីឲ្យគាត់អាចឆ្លើយនៅពេលក្រោយឈប់សម្រាកបាន។

[១០:៣១:៤១]

**ប្រធានអង្គជំនុំ៖**

សៀវភៅអីទៅ ហើយមាននៅក្នុងបញ្ជីឯកសារដែលលោកស្នើសុំដាក់ដេញដោលចំពោះមុខអង្គជំនុំជម្រះដែរឬទេ?

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានជាសៀវភៅដែលមានចំណងជើងថា "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" គឺសៀវភៅដែលកំពុងតែពិភាក -- កំពុងតែសាកសួរដេញដោលនេះឯង យើងមាននៅក្នុង -- ដាក់ចូលទៅក្នុងសំណុំរឿងហើយ យើងកំពុងពិភាក្សានេះឯង។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត។ ឥឡូវនេះដល់ពេលសមល្មមនឹងសម្រាកហើយ ហើយមុននឹងប្រកាសសម្រាក អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្ដីរបស់គាត់នៅក្រោយចាប់ផ្ដើមដំណើរការសវនាការព្រឹកមិញនេះ សុំលះបង់សិទ្ធិចូលរួមនៅក្នុងសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។ ដោយសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍ សម្រាប់រយៈពេលធ្វើសវនាការថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពបាត់បង់លទ្ធភាពផ្ចង់អារម្មណ៍ក្នុងការតាមដានស្ដាប់ ឈឺឆ្អឹងខ្នង មិនអាចអង្គុយតាមដានស្ដាប់កិច្ចដំណើរសវនាការដោយផ្ទាល់បាន។ ហើយតាមអនុសាសន៍របស់វេជ្ជបណ្ឌិត តុង ហុង ដែលទទួលពិនិត្យថែទាំព្យាបាលជនជាប់ចោទនៅមន្ទីរឃុំឃាំង នៅព្រឹកមិញនេះបានផ្ដល់យោបល់ថា ក្នុងកិច្ចដំណើរការសវនាការនៅថ្ងៃនេះ ជនជាប់ចោទមានលទ្ធភាពអាចចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការនេះបានរយៈពេលមួយទៅពីរម៉ោង។

[១០:៣៣:២០]

ហើយឥឡូវនេះតាមការសង្កេតមើលផ្ទាល់ បញ្ហាសុខភាពរបស់លោក អៀង សារី គឺមិនអាចបន្តទៅទៀតបានទេ។ ហើយក៏ដល់ពេលសមល្មមដែរ ដែលអង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យលោក អៀង សារី ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍។ ហើយអង្គជំនុំជម្រះក៏យល់ឃើញផងដែរថា នៅពេលនេះជនជាប់ចោទ អៀង សារី បានសុំលះបង់សិទ្ធិមានវត្តមានក្នុងបន្ទប់សវនាការផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ។ តាមរយៈឧបករណ៍សោតទស្សន៍ នឹងអាចសម្រួលដល់ទំនាក់ទំនងរវាងគាត់ជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ លះបង់សិទ្ធិចូលរួមដំណើរការសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនេះ។ ឲ្យលោក អៀង សារី ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍ សម្រាប់រយៈពេលសវនាការជាបន្តសម្រាប់ថ្ងៃនេះ។

[១០:៣៤:២២]

ហើយបង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់កិច្ចដំណើរការសវនាការដែលនឹងបន្តធ្វើនៅថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក អៀង សារី ទៅកាន់បន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការ ដែលមានរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់មួយខ្វះប្រាំនាទី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។ មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកសមរម្យនៅបន្ទប់សម្រាប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដែលបានកំណត់អម្បាញ់មិញនេះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៥ នាទី ដល់ម៉ោង ១០:៥៩ នាទី)*

[១០:៥៩:២២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។ សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ។ សូមអនុញ្ញាតបន្តទៅចំណុចចុងក្រោយដែលយើងបានពិភាក្សាមុនសម្រាក។ សូមលោកជម្រាបតុលាការ ថាតើលោកបានឱកាសដើម្បីពិនិត្យមើលចំណុចសំខាន់ៗក្នុងសៀវភៅរបស់លោកឡើងវិញហើយឬនៅ?

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** បាទ សូមអភ័យទោស គឺថាព័ត៌មានដែលនិយាយអំពី ខៀវ សំផន ដែលចូលទៅគណៈមជ្ឈិមមិនស្ថិតនៅក្នុងសៀវភៅនេះទេ ខ្ញុំនឹងពិនិត្យមើលនៅពេលក្រោយ។ នេះជាប្រយោគមួយ ហើយខ្ញុំអាចសន្យានឹងរកនៅថ្ងៃស្អែក។ ប៉ុន្តែពេលសម្រាកនេះ ខ្ញុំរកមិនឃើញទេ។

**ស៖** សូមអរគុណ។ អ៊ីចឹង គឺថាតើអាចពិនិត្យលើឯកសារ សូមឲ្យរក្សាទុកឯកសារដើម្បីយើងពិនិត្យនៅថ្ងៃស្អែក យើងមានជាស្រេច។

បញ្ហាបន្ទាប់ដែលខ្ញុំចង់ពិភាក្សា ហើយនឹងសួរលោកនោះ ហើយចូលទៅដល់ឆ្នាំ១៩៧២ ចំណុចនេះទាក់ទងទៅនឹងអ្វីដែលលោករៀបរាប់ថា គឺគោលបំណងរបស់អង្គការប្រឆាំងនឹងវៀតណាម នៅក្នុងក្រុមមួយចំនួន គឺក្រុមមួយចំនួននៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ ហើយដើម្បីឲ្យភាគីផ្សេងទៀតបានយល់នោះ គឺថាអ្វីដែលខ្ញុំនឹងសួរនោះ គឺខ្ញុំនឹងបង្ហាញនូវអត្ថបទជាភាសាខ្មែរ ដើម្បីឲ្យសាធារណជនអាចតាមដានបាន នៅពេលដែលយើងមានឯកសារជាភាសាខ្មែរ។ បើមានតែអង់គ្លេស ខ្ញុំនឹងបញ្ចាំងជាអង់គ្លេស ហើយខ្ញុំនឹងសុំឲ្យជំនួយការរបស់ខ្ញុំ នឹងជម្រាបជូននូវឯកសារថ្មីដែលនឹងជូនទៅលោកចាប់ពីឆ្នាំ១៩៧០ ដល់៧៥នោះ។

[១១:០១:៥៤]

ក្នុងពេលនេះ ខ្ញុំចង់ពិនិត្យមើលចំណុចដូចតទៅនេះ។ អ្វីដែលលោកពិភាក្សានៅក្នុងសៀវភៅចំណងជើងថា "បងទី១" ហើយនិង "សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា" ទាក់ទងនឹងជំហររបស់បក្សកុម្មុយនីស្តកម្ពុជាចំពោះវៀតណាមនោះ។ ហើយនិងដើម្បីបំភ្លឺ បង្ហាញអំពីចំណុចទាំងអស់នោះ នៅក្នុងសៀវភៅដែលមានចំណងជើងថា "សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា" នៅក្នុង ERN 00193309 គឺនិយាយអំពីចុងឆ្នាំ១៩៧២។ ហើយលោកបាននិយាយដូចតទៅនេះ គឺថា៖ "ដើម្បីដកខ្លួនចេញពីការត្រួតត្រារបស់វៀតណាម បក្សកុម្មុយនីស្តកម្ពុជា ក៏បានរៀបចំការប្រឆាំងនឹងវៀតណាម ហើយវាមានកងទ័ពដែលរបស់សម្តេច សីហនុ ហើយក៏បោសសម្អាតពួកដែលមកពីវៀតណាម។ ហើយនៅពេលនេះ គឺថា ខៀវ សំផន នោះក៏បានឆ្លើយថា អាចជាផែនការរបស់ សេ.អ៊ី.អា"។

[១១:០៣:២៧]

ឥឡូវនេះ យើងពិនិត្យមើលហេតុការណ៍នេះ តើលោកផ្តល់យោបល់ជូនយើងខ្ញុំបានទេ ថាតើអ្វីដែលផ្ទុះបញ្ហាំងនៅក្នុងបក្ស នៅក្នុងនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលទាក់ទងទៅនឹងបក្សកុម្មុយនីស្តវៀតណាមនោះ?

**ឆ៖** ការដកទ័ពវៀតណាមចេញពីកម្ពុជានោះ ជាផ្នែកមួយកិច្ចព្រមព្រៀងរវាងវៀតណាមខាងជើង ហើយនិងអាមេរិកាំង។ និយាយពីការដកកងទ័ព ហើយនៅពេលដែលមានការឈប់បាញ់គ្នា នៅប្រទេសវៀតណាមនេះជាមួយគ្នានៅក្នុងឡាវផងដែរ ប្រទេសឡាវ។ លន់ នល់ បានយល់ស្របទៅនឹងការបទឈប់បាញ់គ្នា។ ប៉ុន្តែខ្មែរក្រហមមិនយល់ស្របទេ ហើយកងទ័ពវៀតណាមបានដកចេញពីកម្ពុជាគេបានយោងទៅរកការពិភាក្សានៅក្នុងទីក្រុងប៉ារីស។ នេះគឺជាចេតនារបស់វៀតណាមក្នុងការ -- ដើម្បីពិនិត្យមើលអ្វីៗនៅក្នុងប្រទេសកម្ពុជានោះ។ អ្នកដែលត្រឡប់មកពីវៀតណាម ដែលមកពីវៀតណាមខាងជើង ឆ្នាំ១៩៥៤ ហើយនិង៥៥នោះ ចំនួនគឺថាវាផ្ទុយគ្នាប្រហែលជា ២០០, ៣០០ នាក់ មកភូមិភាគខាងត្បូងហើយចូលរួមជាមួយបដិវត្តន៍ក្នុងទសវត្សរ៍ឆ្នាំ៧០ ហើយក្រោយមកក៏ត្រូវបានគេបោសសម្អាតអ្នកទាំងនោះ។ ចាប់ពីដំបូងរហូតមកដល់ប្រកាសគោលនយោបាយនោះគឺថាវាមាន គឺថារហូតដល់មានកងពលបីរបស់វៀតណាមនៅប្រទេសកម្ពុជា។ ហើយខ្ញុំនឹងសួរសំណួរលោកតទៅទៀត ទាក់ទងទៅថាអាចនឹងមាន ប្រាំពីរ ទៅប្រាំបីរយនាក់ជាកម្មាភិបាលមកពីប្រទេសវៀតណាម មកបក្សកុម្មុយនីស្តកម្ពុជា ហើយក្រោយមកត្រូវបានគេបោសសម្អាតនោះ។

យើងពិនិត្យមើលក្រោយឆ្នាំ១៩៧២ មក ថាតើមានកម្មាភិបាលណាដែលត្រូវបានគេតែងតាំង ឬចាត់តាំងឲ្យធ្វើការ ទទួលអំណាចអ្វីដែរឬទេ? ឬក៏រហូតតាំងពីឆ្នាំ១៩៧០ មកដល់៧០ គេបាននៅហាណូយ ហើយមកប្រទេសកម្ពុជាក្រោយពីពេលមកនោះ។

[១១:០៦:០៦]

**ឆ៖** ប៉ុន្តែ បន្ទាប់ពីឆ្នាំ១៩៧៩ អូ! សូមកែតម្រូវ ហើយខ្ញុំនឹង -- អ្នកដែលមកពីវៀតណាម មិនមែនកម្មាភិបាលបក្សកុម្មុយនីស្តកម្ពុជាទេ គេគ្រាន់តែគាំទ្រចលនានោះទសវត្សរ៍ឆ្នាំ៥០ ប្រហែលជាគេយកទៅវៀតណាម ឲ្យចូលបក្សវៀតណាមក៏មិនដឹងក្នុងរយៈពេល១៥ឆ្នាំ ប៉ុន្តែពួកមិនទាន់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ គេគ្រាន់តែជាអ្នកគាំទ្របក្សកុម្មុយនីស្តកម្ពុជាតែប៉ុណ្ណោះ។

**ស៖** សូមអរគុណចំពោះការកែតម្រូវរបស់លោកនេះ។ ហើយប្រសិនបើយើងពិនិត្យមើលទំនាក់ទំនងជាមួយវៀតណាមដើម្បីឲ្យលម្អិតជាងនេះបន្តិចនោះ លោកបាននិយាយថា យើងនិយាយអំពីសៀវភៅសោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា ERN នោះគឺថា 0019302 រហូតទៅដល់ 200 -- ទំព័រ២១៩។ នៅក្នុង -- ថាតើអ្នកដែលយល់ស្រប ហើយនៅក្នុងឆ្នាំ១៩៧៣ គឺថាកងទ័ពវៀតណាមចេញផុតអស់ បក្សកុម្មុយនីស្តកម្ពុជា កម្មាភិបាល ហើយគេកំណត់ថា អ្នកនោះគឺជាសត្រូវទីមួយនៅឆ្នាំ១៩៧៨ ហើយ តាម៉ុក បាន -- ដើម្បីកម្ទេច ខ្មាំងទីប្រាំពីរ ហើយ នន់ សួន នោះ ប្រហែលជាដោយសារគាត់មានបទពិសោធន៍ក្នុងបក្សកុម្មុយនីស្តឥណ្ឌូចិននោះ គាត់ក៏បានជាទិសដៅមួយរបស់បក្សកុម្មុយនីស្តកម្ពុជាដែរ។ តើលោកអាចជម្រាបតុលាការបានទេអំពីការវិវត្តន៍នេះ រហូតមកដល់ឆ្នាំ១៩៧៣ ដែលបានកើតឡើងដែលថា មានការបើកចំហនូវការខកចិត្ត ហើយនិងសាធារណជនបានដឹងពីហេតុការណ៍ទាំងអស់នោះ? តើលោកអាចជម្រាបតុលាការថា ហេតុអ្វីបានជាមានសារៈសំខាន់នៅក្នុងការកែប្រែ ឬក៏ការអនុវត្តគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងឆ្នាំនេះ។

[១១:០៨:២៨]

**ឆ៖** ចំណុចសំខាន់នៅក្នុងទំព័រនេះគឺ ឆ្លុះបញ្ចាំងអំពីការរកឃើញនៃអ្នកគាំទ្រកម្ពុជាពីរដែលចេញពីប្រទេសកម្ពុជាទៅមូលដ្ឋានបដិវត្តន៍នៅឆ្នាំ១៩៧៣ ហើយបានចូលរួមចលនាខ្មែរក្រហម ហើយក៏បានយកព័ត៌មានជាក់លាក់មួយចំនួនផងដែរ។ សៀវភៅនេះ ត្រូវបានគេហាមឃាត់នៅក្នុងប្រទេសកម្ពុជា ប៉ុន្តែក្រោយមកគេបានបោះពុម្ពផ្សាយ។ នេះជាតំណាងដោយអ្នកទាំងពីរនេះ គេបាននិយាយគេបានជួបប្រទះនៅក្នុងតំបន់ខ្មែរក្រហម គេបានឆ្លើយ ហើយគេបានរាយការណ៍ពី តាម៉ុក ផងដែរ។

ហើយមិនមានអ្វីផ្ទុយគ្នាដែលជាឯកសារសម្ងាត់នោះទេ។ នេះគឺជាការបើកចំហនូវភស្តុតាងដើម្បីបង្ហាញពីទស្សនវិស័យក្នុងរយៈកាលនេះ ហើយខ្ញុំបានសម្ភាស សារិន ដោយខ្លួនឯងនៅក្នុងឆ្នាំ១៩៩៨។

[១១:១០:០១]

**ស៖** សូមអរគុណ។ ឥឡូវនេះ ចូលទៅដល់នយោបាយមួយទៀត ដែលលោកបាននិយាយពីកាលម្សិលមិញ ទាក់ទងទៅនឹងសម័យកាលមុនឆ្នាំ១៩៧៥ ឥឡូវនេះ នៅឆ្នាំ១៩៧៣ លោកបានយោងទៅរកនយោបាយមួយដែលគេនឹងបង្កើតសហករណ៍ និយាយពីការបង្កើតសហករណ៍។

នយោបាយនេះ និយាយអំពី -- រឿងនេះគឺថានិយាយនៅក្នុងសៀវភៅទាំងពីរ ទាំងសៀវភៅ “បងទី១” ហើយនិងសៀវភៅ “សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា”។ ហើយខ្ញុំសូមអនុញ្ញាត គឺថាអង់គ្លេស ERN នោះគឺថា 00393010, ខ្មែរ ERN 00821762។

ខ្ញុំសូមអនុញ្ញាត ដើម្បីបង្ហាញអត្ថបទជាសាភាខ្មែរនៅក្នុង នៅលើអេក្រង់ផង។ នេះជាសៀវភៅ “សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា” គឺថានៅដើមឆ្នាំ១៩៧៣ កងទ័ពបដិវត្តន៍កម្ពុជាបានវាយប្រហាររដ្ឋាភិបាលដើម្បីពង្រីកទឹកដី ហើយបានដាក់នូវកម្មវិធីសង្គម។ ហើយមានការតាមដានជិតស្និទ្ធនៅភូមិនិរតី គឺការអនុវត្តនូវសហករណ៍កសិករកសិកម្ម ហើយការជម្លៀសប្រជាជនដោយបង្ខំ ការបង្ក្រាបពុទ្ធសាសនា ហើយនិងការបង្កើតយុទ្ធជន ហើយនិងដកកុមារចេញពីក្រុមគ្រួសារ ហើយនិងៗ ការដាក់វិន័យការស្លៀកពាក់ គឺត្រូវតែស្លៀកពាក់សម្លៀកបំពាក់ជាកសិករ គឺត្រូវសម្លៀសបំពាក់ខោវខ្មៅអាវខ្មៅគ្រប់ពេលវេលា។

[១១:១១:៥៣]

ដោយថាមានភាពធ្ងន់ធ្ងរនៃការអនុវត្តនយោបាយនេះ គឺថាប្រជាជន២ម៉ឺននាក់បានគេចខ្លួនទៅជ្រកនៅវៀតណាមខាងត្បូង។ នេះហើយជាសេចក្ដីសម្រេចចេញឡើងដោយ សាឡុត ស នៅឆ្នាំ១៩៧១ ហើយគាត់បានអនុម័ត ហើយបង្គាប់ឲ្យអនុវត្តទូទាំងប្រទេស បន្ទាប់ពីឆ្នាំ១៩៧៥ ដែលមានលក្ខណៈដាច់ខាត ហើយលុបបំបាត់នូវទីផ្សារ សាលារៀន ទីវត្តអារាម ហើយនិងជម្លៀសប្រជាជនចេញពីទីក្រុង ហើយនិងទីប្រជុំជននានា។

ខ្ញុំនឹងសួរសំណួរ ហើយខ្ញុំចង្អុលបង្ហាញថា សៀវភៅពាក់ព័ន្ធនៅក្នុងសោកនាដកម្មកម្ពុជានេះ គឺថាគឺ ERN 00193309 រហូតដល់ 010 ដែលលោកនិយាយថា លោកយោងទៅរកខែឧសភា ឆ្នាំ១៩៧៣ នោះ។ សូមលោកជម្រាបតុលាការ ថាតើការវិវត្តន៍នៃការហេតុការណ៍ទាំងអស់នេះកើតមាន

ឡើង បន្ទាប់ពីការអនុម័តនូវសេចក្តីសម្រេច ឬក៏មានឯកសារអ្វីដែលលោករកឃើញនៅក្នុងការស្រាវជ្រាវរបស់លោកនោះ?

[១១:១៣:០៩]

**ឆ៖** តាមពិត ការអនុវត្តគោលនយោបាយនៅក្នុងនិរតីនោះ គឺមិនបានរកឃើញនេះទេ ប៉ុន្តែជាទូរលេខដែលបញ្ជូនពីបុគ្គលិករបស់ស្ថានទូតអាមេរិក ដែលក្រោយមកគាត់ធ្វើជាស្ថានទូត គឺ ខេនណេត ឃ្វីន ដែលគាត់ជិតព្រំដែនកម្ពុជានៅកាលណោះ គាត់បានឃើញផ្សែងនៃភ្លើងសង្គ្រាមពីផ្ទះរបស់គាត់ ហើយនៅពេលដែលនោះ គាត់បាននិយាយ គឺមានហេតុការណ៍ទាំងអស់នោះកើតឡើងនៅតំបន់នោះ ហើយភូមិភាគនិរតី នៅក្នុងប្រវត្តិសាស្ត្ររបស់បក្សកុម្មុយនីស្តកម្ពុជានោះ គឺគាត់បញ្ជាក់ថា គឺបក្សកុម្មុយនីស្តកម្ពុជាខ្លាំងនៅកន្លែងនេះ គឺជាតំបន់របស់ តាម៉ុក នៅខេត្តតាកែវ។

[១១:១៤:០៨]

តាម៉ុក គឺជាអ្នកដឹកនាំការកែទម្រង់នេះ ហើយគាត់បានជាសមាជិករបស់គណៈអចិន្ត្រៃយ៍ដែលជាអ្នកអនុវត្តនយោបាយរបស់បក្សនោះ។ ខ្ញុំពិនិត្យឃើញថា ចំណុចសំខាន់នៅពេលដែលគេអាចធ្វើបានខ្មែរក្រហម គឺមាន -- គេចង់ដាក់នយោបាយនេះឲ្យអនុវត្ត គឺមិនចង់ដឹងថាជោគជ័យ មិនជោគជ័យទេ គឺថាគឺគេចង់បញ្ឈប់អ្វីៗដែលមានពីមុន។ គេមិនដែលគិតពីគោលនយោបាយដែលបរាជ័យទេ គេចង់តែវែកខ្លាំងរបស់គេ ជនក្បត់។ នេះគឺជា -- ចំពោះពិភពលោកខាងក្រៅ គឺថាយើងមិនបានឃើញគេឡើក្រោមទូរលេខរបស់លោក ឃ្វីន ទេ គឺថាវាបង្ហាញពីអាកប្បកិរិយាដែលថាអាចនឹងកើតមានឡើងនៅអនាគត។ នេះហើយជាភស្តុតាងមួយបង្ហាញថា ហេតុការណ៍នោះវាសំខាន់។

**ស៖** នៅក្នុងផ្នែកមួយដែលលោកបានទាញនូវៗការបញ្ជាក់ថា នយោបាយនោះ -- បន្ទាប់មកគឺយកមកប្រើក្រោយឆ្នាំ១៩៧៥ អ៊ីចឹងវាមានទំនាក់ទំនងកាលពីមុននិងពេលក្រោយ។ នៅក្នុងការសិក្សាអំពីការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ឯកសារផ្សេងទៀត តើលោកបានរកឃើញភស្តុតាងអ្វី ឬក៏សុន្ទរកថា ដែលគាំទ្រអំពីការបន្តនូវគោលនយោបាយហ្នឹងទេ? ហើយប្រសិនបើលោកពិនិត្យឃើញតាំងពីឆ្នាំ១៩៧៣ រហូតមកក្រោយហ្នឹង រហូតមកដល់ខែមេសា ឆ្នាំ១៩៧៥ ហើយក្រោយមកទៀតនោះ?

[១១:១៦:០៧]

**ឆ៖** ចម្លើយសង្ខេបហ្នឹង គឺថាខ្ញុំមិនឃើញទេ គឺថាខ្ញុំមិននឹកឃើញថាមានសេចក្តីប្រកាសរបស់

បក្សកុម្មុយនីស្តកម្ពុជានោះទេ។ ខ្ញុំគិតថា ឯកសារអាចមាន “ទង់បដិវត្ត” ប៉ុន្តែខ្ញុំមិនអាចនិយាយយោងបានទេ។ ហើយ តាម៉ុក មិនដែលបញ្ជាក់ថា មិនសប្បាយចិត្តនោះទេ គឺថាគាត់មានការដឹកនាំអនុវត្តនយោបាយនេះ។

**ស៖** តើលោកអាចប្រាប់យើងខ្ញុំជាទូទៅបានទេ ថាតើនយោបាយទាំងនេះ ឬក៏នយោបាយនៃការបង្កើតសមូហភាព ហើយនិងការជម្លៀសដោយបង្ខំនេះ គឺថាមានចែងនៅក្នុងទង់បដិវត្តនៅឆ្នាំ ១៩៧៣ រហូតមកដល់ ១៩៧៥ ដែរឬទេ?

[១១:១៧:០០]

**ឆ៖** ហើយខ្ញុំត្រូវពិនិត្យមើលឡើងវិញ ខ្ញុំអាចឃើញឯកសារមួយ។ ខ្ញុំមិនអាចឃើញ ប៉ុន្តែខ្ញុំដូចជាមិនច្បាស់ វង់ចាំ ហើយខ្ញុំមិនអាចបញ្ជាក់បានទេ។ ខ្ញុំត្រូវពិនិត្យមើល ហើយខ្ញុំយកចម្លើយនៅថ្ងៃស្អែក ខ្ញុំមិនគិតថា ឆ្លើយពេលនេះបានទេ។

**ស៖** សូមអរគុណ។ យើងអាចនឹងពិនិត្យមើលឯកសារផ្សេងទៀត ប្រសិនបើលោកអាចបញ្ជាក់ប្រាប់យើងខ្ញុំបាននោះ។ ហេតុការណ៍មួយចំនួនទៀត ដែលលោកៗបានពិនិត្យឃើញគឺថា រយៈកាលមុនឆ្នាំ១៩៧៥នោះ គឺជាការជម្លៀសនៅតំបន់ក្រុង ឬតំបន់ទីប្រជុំជន ខ្ញុំនឹងបង្ហាញជូនលោកនូវខ្លឹមសារដែលលោកបានសរសេរនៅក្នុងសៀវភៅរបស់លោកនោះដែរ។ នៅក្នុងសៀវភៅ “បងធំទី១” នោះ ខ្មែរ ERN 00821765។ ហើយសូមអនុញ្ញាតបង្ហាញឯកសារនេះលើកអេក្រង់ផងដែរ។ អង់គ្លេស ERN 00393014។

[១១:១៨:២០]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធានសុំអនុញ្ញាត ដើម្បីបង្ហាញទំព័រភាសាខ្មែរនៅលើអេក្រង់បាទ។

បាទ សូមអរគុណ។ សូមខាងប្រព័ន្ធសោតទស្សន៍ ដើម្បីបញ្ចាំង ហើយនឹងខ្ញុំអាចអានជូន។ សូមអភ័យទោសប្រសិនបើមិនឃើញច្បាស់ទេ ខ្ញុំមើលទំព័រទាំងមូល។ សេចក្តីដកស្រង់ហ្នឹងគឺដូចខាងក្រោម៖

“ទាក់ទងទៅនឹងការវាយប្រហារទីក្រុងកំពង់ចាម គឺប្រហែលមានចេតនាដើម្បីពង្រឹងការវាយកងទ័ពវៀតណាមនៅក្បែរនោះមិនបានជួយទេ។ នៅដំណាក់កាលមួយកងទ័ពកុម្មុយនីស្តគឺបានចូលប្រហែលជាបីបួនរយម៉ែត្រនៅក្នុងទីក្រុង នៅពេលដែល -- នោះគេបានប្រមូលដកប្រជាជន ហើយនិង

គឺ -- ហើយជាគំរូសង្គ្រាមដែលកើតមានឡើងមុនសម័យអាណានិគមផងដែរ។ ជានយោបាយដើម្បីគឺដកយកប្រជាជនរបស់ខ្មាំងចេញ។ នៅពេលដែលគេចូលដល់ភ្នំពេញ ហើយទីក្រុងរបស់សាធារណរដ្ឋ និងទីប្រជុំជននោះផងដែរ”។

[១១:១៩:២៨]

ឥឡូវនេះ ដោយសារថា វាមានការទាក់ទងគ្នា ខ្ញុំអានផ្នែកមួយនិយាយនៅក្នុងសៀវភៅ “សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា” គឺនៅក្នុង ERN ភាសាអង់គ្លេស 00193314 ទំព័រ២៣១ ដែលនិយាយអំពី “ការវាយប្រហារពីរបីខែបន្ទាប់ពីខេត្តកំពង់ចាមនោះ នៅក្នុងខែមីនា ឆ្នាំ១៩៧៤ ទាក់ទងទៅនឹងទីក្រុងឧដុង្គផងដែរ នៅពេលដែលកងទ័ពនោះគឺថាកាន់កាប់ឧដុង្គហើយ នៅខាងជើងទីក្រុងឧដុង្គនៅឆ្នាំ១៩៧៤ ខែមីនា នោះ គឺថាមនុស្សប្រហែលជា២ម៉ឺននាក់ត្រូវបានជម្លៀសចេញដែលគេចាត់ទុកថាជាខ្មាំង ហើយគេយកអ្នកទាំងអស់នោះឲ្យទៅធ្វើការនៅជនបទ។ លោកសាស្ត្រាចារ្យ តើមានអ្វីជាហេតុការណ៍សំខាន់ទេនៅទីនេះ? ថាតើមានអ្វីកើតឡើងនៅឆ្នាំ១៩៧៥ ខែមេសា នៅពេលដែលខ្មែរក្រហមបានផ្តួលរបបសាធារណរដ្ឋខ្មែរហើយមកនោះ?

[១១:២០:៥៦]

**ឆ៖** ខ្ញុំគិតថា ចំពោះអ្នកជាប្រវត្តិសាស្ត្រចំណុចសំខាន់នៅកន្លែងនៃការជម្លៀសនេះ គឺបង្ហាញថា មិនៗធ្វើឲ្យប្រជាជនពេញចិត្តនោះទេ គឺថាគេមិនបានគ្រោងទុកជាមុនថា មានការជម្លៀសទេនៅឆ្នាំ១៩៧៥។ ហើយយើងមើលឃើញថា ជាអ្នកសង្កេតការណ៍នោះ កម្ពុជាគឺចលនាដែលមិនបានគ្រោងទុកជាមុនគឺថា -- ប៉ុន្តែតាមពិតគេបានគ្រោងមុនពីឆ្នាំ១៩៧៥ តាមឯកសារដែលយើងមាន។ ហើយយើងអាចទស្សន៍ទាយបាន គឺថាទាំងតាកែវ ហើយនិងឧដុង្គនោះ ហើយនៅខេត្តក្រចេះផងដែរ ត្រូវបានជម្លៀសនៅពេលដែលខ្មែរក្រហមចូលកាន់អំណាចស្ទើងគ្រែងនោះផងដែរបាទ។

នេះជាគំរូដែលមានដដែលៗ ដែលទាក់ទងនឹងទីក្រុងដែលជាគំរូយកមកប្រើនៅភ្នំពេញ ដូចជានៅបាត់ដំបងក៏វាមានការធូន់ធូរនោះដែរ។ នេះជាគំរូនៃការជម្លៀសដែលស្រដៀង គឺថាស៊ីសង្វាក់គ្នា។

[១១:២២:០០]

**សៈ** សូមអរគុណ។ ឥឡូវនេះ ខ្ញុំចង់ពិនិត្យមើលមួយនាទី ឬក៏ពីរនាទី គឺដែលបញ្ហានេះគឺនិយាយអំពីទស្សនាវដ្ដីទង់បដិវត្តដែលជាឯកសារបោះពុម្ពផ្សាយបញ្ហាមួយដែលលោកបានសរសេរក្នុងសៀវភៅរបស់លោកជាច្បាប់ពិសេសខែធ្នូ ឆ្នាំ១៩៧៦ ហើយនិងខែមករា ឆ្នាំ១៩៧៧ ឯកសារ E3/25។

ERN ដែលពាក់ព័ន្ធនោះ គឺជាភាសាខ្មែរ 00063039 រហូតដល់ 40, ជាភាសាបារាំង 00504049 រហូតដល់50, អង់គ្លេស 00491425។ អ៊ីចឹងសូមអនុញ្ញាតបង្ហាញជាភាសាខ្មែរនៅលើអេក្រង់ហើយ លោកសាស្ត្រាចារ្យខ្ញុំមានឯកសារនៅលើក្រដាសហើយខ្ញុំនឹងជូនទៅលោក គឺជាទស្សនាវដ្ដីទង់បដិវត្តនៅខែធ្នូ ឆ្នាំ១៩៧៦ ដល់ខែមករា ឆ្នាំ១៩៧៧។ ហើយនិងបង្ហាញអត្ថបទភាសាខ្មែរលើអេក្រង់ ខ្ញុំនឹងអានផ្នែកខ្លះជាភាសាអង់គ្លេសចំពោះអ្នកមិនចេះអានភាសាខ្មែរនោះ។

[១១:២៣:៤០]

ហើយទាក់ទងទៅនឹងហេតុការណ៍មួយចំនួននៅចំណុច "ក" នៅទំព័រនេះ "ការវាយប្រហារខ្លាំងខាងនយោបាយ" ជាឧទាហរណ៍ "វាយដើម្បីដកប្រជាជនទូទាំងប្រទេស គេមិនដែលដកប្រជាជនទេ។ មាគ៌ារបស់យើងគឺចង់ដកប្រជាជននៅពេលដែលយើង មួយយកមួយ មួយរយក៏យើងយក មួយពាន់ក៏យើងយក ហើយរហូតទាល់តែយើងវាយទាំងអស់ ហើយរហូតដល់យើងឈ្នះភ្នំពេញ។ មាគ៌ាដើម្បីដកប្រជាជនចេញពីខ្មាំង គឺជាមាគ៌ាដ៏ត្រឹមត្រូវ ដណ្ដើមយកពីខ្មាំង គឺត្រឹមត្រូវ"។ អ្នកនិពន្ធអត្ថបទនេះបានជូនជាឧទាហរណ៍បី។ បាទ ជាឧទាហរណ៍ពីរ ដែលឧទាហរណ៍ទីមួយនោះគឺ ការវាយប្រហារនៅបាណន់នៅឆ្នាំ១៩៧៣ យើងយកទាំងអស់នៅក្រុងបាណន់ បញ្ចេញទាំងអស់ ជនជាតិវៀតណាម ជនជាតិចិន ទាហាន ទាំង ប៉ូលិសទាំងអស់។ ពង្រឹងប្រជាជនចេញពីខ្មាំង។

[១១:២៤:៥០]

ហើយបន្ទាប់មកទៀតនៅទីបំផុតនោះ នៅក្នុងឯកសារដដែលនោះ នៅខាងក្រោមនោះ ឧទាហរណ៍ដែលទាក់ទងនឹងឧដុង្គដែលយើងបាន -- យើងបានរំដោះឧដុង្គឆ្នាំ១៩៧៤ យើងបានដកយកប្រជាជនទាំងអស់ មិនឲ្យ -- គេមិនអាចច្បាំងឈ្នះយើងទេ គេមិនមានកម្លាំងទេ។

អ្វីដែលខ្ញុំចាប់អារម្មណ៍នៅក្នុងសេចក្ដីដកស្រង់ហ្នឹង ការប្រើពាក្យខ្លះ មួយចំនួនថា ការដកយកដណ្ដើមប្រជាជនពីខ្មាំងនេះ ដែលថាដកយកប្រជាជនចេញពីខ្មាំង ពីតំបន់ដែលខ្លួនរំដោះនោះ តើមានខ្លឹមសារ ឬក៏គោលដៅដូចម្ដេច?

**ឆ៖** នេះវាមានច្បាស់ហើយនៅក្នុងគោលនយោបាយ ដូចដែលខ្ញុំបញ្ជាក់នៅក្នុងទំព័រផ្សេងៗ គឺតាំងពីនយោបាយមុនសម័យអាណានិគមម្ល៉េះ គឺថានៅពេលដែលថៃចូលមករំដោះ គឺថាពេលដែលគេចូលរំដោះហើយ គេដកប្រជាជនចេញ ដើម្បីឲ្យ -- កុំឲ្យមានមនុស្សនៅ ដើម្បីការពារសកម្មភាពយោធា។ នេះជាគំនិត ថាតើអ្នកទាំងអស់នេះជាអ្នកណា? ដោយគេមិនគិតទេ ជាវណ្ណៈ ឬក៏គេគាំទ្រ

ខាងណា? ដូចជាពួកម៉ាគីគាំទ្រខាងបដិវត្តន៍។ ប៉ុន្តែពេលដែលគេរំដោះបាន គឺគេត្រូវដកប្រជាជនចេញតាមទស្សនៈ ដើម្បីកុំឲ្យមានការវាយប្រហារតបមកវិញ ដើម្បីកុំឲ្យមានអ្នកដែលខឹងសម្បាខ្មែរក្រហមអាចបះបោរបាន។

[១១:២៦:៤០]

**ស៖** សូមអរគុណ។ ខ្ញុំនឹងពិភាក្សាចំណុចបន្ទាប់ នយោបាយមួយទៀតដែលយើងបាននិយាយបន្តិចខាងដើមហើយ និយាយអំពីជោគវាសនារបស់កម្មាភិបាលដែលមកពីហាណូយ ហើយខ្ញុំនឹងមើលដោយសង្ខេប ពិនិត្យដោយសង្ខេប នយោបាយដែលលោកបានពិភាក្សានៅក្នុងសៀវភៅនិយាយពីសំឡេងពី ស-២១នោះ។ ហើយយើងមានអត្ថបទជាភាសាខ្មែរ ឯកសារ D108/50/1.4.6។ ឥឡូវនេះយើងមានការជំទាស់។

**ប្រធានអង្គជំនុំ៖**

លោកអ្នកជំនាញកុំអាលទាន់ឆ្លើយតប! ស្តាប់ការជំទាស់របស់មេធាវីការពារក្តីជាមុនសិន។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ែខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមអភ័យទោសចំពោះដែលខ្ញុំរំខាននេះ គឺថាអ្នកជំនាញបានកែតម្រូវសហព្រះរាជអាជ្ញាហើយ គឺថា អ្នកដែលមកពីវៀតណាម គឺថាមិនមែនជាកម្មាភិបាលទេ។ អ៊ីចឹងគឺថាសូមឲ្យសហព្រះរាជអាជ្ញាសួរឡើងវិញ ពីព្រោះថា ពីការប្រើពាក្យឲ្យបានត្រឹមត្រូវ។ ចំពោះពាក្យនេះ។

**លោក អាប់ឌុលឡាក់ ថារីក៖**

ការកែតម្រូវរបស់សាស្ត្រាចារ្យហ្នឹង គាត់មិនមែនជាសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ប៉ុន្តែខ្ញុំប្រើពាក្យថា កម្មាភិបាលនេះ ជាពាក្យទូទៅ។ ប្រហែលជាសាស្ត្រាចារ្យលោកអាចកែខ្ញុំ នៅពេលដែលខ្ញុំសួរឲ្យគាត់ឆ្លើយនូវសំណួរនេះបាទ។ សូមអរគុណ។ ឥឡូវនេះខ្ញុំបន្ត។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ឥឡូវនេះយើងពិនិត្យមើលសៀវភៅមានចំណងជើងថា "សំឡេងពីស-២១" ទំព័រ២១, ២២ ខ្មែរ ERN ដែលពាក់ព័ន្ធនោះ គឺ 00191853 រហូតដល់ 2, អង់គ្លេស ERN 00192700 រហូតដល់ 1, បារាំង ERN 00357284 រហូតដល់ 5។ លោកបានពិភាក្សានូវចំណុចនេះ តួនាទីរបស់ ឌុច នៅក្នុង

ចលនាបដិវត្តន៍ ដើមឆ្នាំ១៩៧០ ទសវត្សរ៍១៩៧០ បាទ។

[១១:២៩:២៥]

ខ្ញុំចង់បានសេចក្ដីបញ្ជាក់ខ្លីពីលោកអ្នកជំនាញអំពីសកម្មភាព ដែលលោកបានរៀបរាប់នៅក្នុងសៀវភៅនេះ ទាក់ទងទៅនឹងការបង្កើតមន្ទីរសន្តិសុខនៅក្នុងសម័យកាលនោះ។

អ្វីដែលលោកនិយាយនោះ ខ្ញុំនឹងអានសេចក្ដីដកស្រង់ លោកនិយាយថា -- សូមអនុញ្ញាតបង្ហាញជាភាសាខ្មែរ ដើម្បី -- "ឌុច បានយកជំនាញរបស់គាត់ដែលគាត់បានយកមកប្រើ គឺថាមិនមានភស្តុតាងគាត់បានទៅបរទេស ឬក៏ទទួលការបណ្ដុះបណ្ដាលពីបរទេសទេ។ គាត់អាចៗ គំនិតនៅក្នុងការអនុវត្តគឺថាកំណត់ខ្សែក្បត់មុនឆ្នាំ១៩៧២ និង៧៣។ នៅពេលដែលមានប្រតិបត្តិការសម្ងាត់របស់ខ្មែរក្រហមដើម្បីបោសសម្អាតខ្មែរហាណូយ ដែលមកនៅឆ្នាំ១៩៧០ ដែលពួកគេបានទៅវៀតណាមនោះ គឺដើម្បីជួយដល់បដិវត្តន៍នោះ"។

[១១:៣០:៤០]

ហើយបន្ទាប់មកទៀតនៅខាងក្រោមបន្តិចនោះ លោកបាននិយាយថា "ទាក់ទងទៅនឹងយុទ្ធនាការនោះ លោកបាននិយាយអំពីការកាប់សម្លាប់ប្រជាជន អ្នកដែលមកពីហាណូយនោះ"។ ដកស្រង់៖ "យុទ្ធនាការនោះគឺ ត្រូវបានយកគំរូគឺថា សម្រាប់យកមកប្រើនៅស-២១"។ ខ្ញុំមិនចង់ឲ្យលោកពន្យល់បន្ថែមអ្វីដែលលើសពីហ្នឹង ដែលអាចជាការសន្និដ្ឋានបន្ថែមនោះទេ។ គឺថា លោកបានសម្ភាស ឌុច អ្វីដែលខ្ញុំចង់ដឹងពីលោកនោះគឺថា យោបល់របស់លោកថា យុទ្ធនាការនោះ គឺជាគំរូដែលយកមកប្រើនៅស-២១ តើលោកអាចពន្យល់បានទេ តើការសន្និដ្ឋានបែបនោះមានន័យដូចម្ដេច?

**ឆ៖** ជាបឋម ដើម្បីត្រឡប់ទៅនឹងសំណួរ ដែលលើកឡើងដោយមេធាវីការពារនោះ។ កម្មាភិបាលមិនប្រើដោយតឹងរ៉ឹងទេ ប៉ុន្តែគាត់មិនមែន -- ពួកនោះមិនមែនជាសមាជិកបក្សកុម្មុយនីស្តកម្ពុជាទេ។ ប៉ុន្តែចំណុចអ្នកទាំងអស់នេះ ខ្ញុំនិយាយខ្លះដែលអាចរស់រានមានជីវិត ហើយត្រឡប់មកកម្ពុជាវិញបាននោះ។ នេះគឺជាអ្នកដែលទទួលការបណ្ដុះបណ្ដាលខាងនយោបាយនៅវៀតណាមជាង១៥ឆ្នាំ ហើយគេឲ្យទទួលការបណ្ដុះបណ្ដាល ហើយគឺ អ្នកនេះជាកម្មាភិបាលកុម្មុយនីស្តដែលមានការបណ្ដុះបណ្ដាលល្អបំផុតនៅក្នុងប្រទេសកម្ពុជាពីវៀតណាមមក។ នេះហើយជាមូលហេតុដែលខ្មែរនៅក្នុងស្រុកហ្នឹងគឺ អន់ចិត្ត គឺថាគេមិនចង់ឲ្យមានអ្នកក្រៅនោះគឺថា មកជា មកពីបរទេស គេយល់ថា អ្នកទាំងនោះជាភ្នាក់ងាររបស់បរទេស ហើយគេមិនចង់បាន។ ហ្នឹងជាគំនិតមួយដែលឆ្លើយតប។

[១១:៣២:៤២]

សំណួរដែលនៅសល់នោះ សំណួរខាងដើមនោះ ខ្ញុំគិតថា គំនិតគឺថា គេពិនិត្យមើលខ្សែ ឬក៏ចាប់តាមរយៈខ្សែនោះគឺជាភស្តុតាងមួយដែលជាគំនិតដែលខ្ញុំសរសេរនៅក្នុងអារម្ភកថា នៃសៀវភៅគឺមនុស្សដែលនៅក្នុងខ្សែ គឺក្នុងបណ្តាញដែលគេមកពីខ្សែក្បត់ ដែលទាក់ទងទៅនឹងជនម្នាក់ដែលគេបានចោទពីមុន ហើយនេះជាក្រុមដែលគេអាចកំណត់បាន។ អ៊ីចឹងហើយគឺអ្នកខ្លះនៅក្នុងភូមិភាគបូព៌ាគឺអាចគេចាប់មក ហើយគេឆ្លើយដាក់នៅជាខ្សែរបស់គេនោះគឺមានសឹងថា ភាគច្រើននៅក្នុងទីកន្លែងផ្សេងៗ គឺថា គេធ្វើយ៉ាងម៉េចកុំឱ្យមានអ្នកទាំងអស់ហ្នឹងនៅកម្ពុជាតទៅទៀតនោះ។

**ស៖** ហើយនៅចំណុចចុងក្រោយនេះ យោងទៅលើការសិក្សាស្រាវជ្រាវរបស់លោកក្នុងអំឡុងពេលនេះ ថាតើអ្នកទាំងអស់នេះត្រូវបានគេបោសសម្អាត ឬក៏បញ្ជូនទៅកាន់កន្លែងទីផ្សេងទៀត ដែលអ្នកទាំងអស់នេះគឺថា ជាគោល ជាទិសដៅសំខាន់នៃការបោសសម្អាត ឬយ៉ាងណា?

[១១:៣៤:១៩]

**ឆ៖** ខ្ញុំមិនគិតថាដូច្នេះទេ។ នៅចុងទសវត្សរ៍៨០ នៅពេលខ្ញុំសម្ភាសមនុស្សមួយចំនួននៅទីក្រុងភ្នំពេញ ខ្ញុំនិយាយជាភាសាខ្មែរទៅកាន់អ្នកទាំងនោះ។ ខ្ញុំមិននិយាយជាភាសាវៀតណាមទេ។ ខ្ញុំបានសម្ភាសមនុស្សម្នាក់ដែលបានចេញចូលៗឆ្នាំ៧៣-៧៤។ មិនមែនរាល់អ្នកជំនាញទាំងអស់អាចចេញចូលបានដូច្នោះទេ។ សម្រាប់អ្នកទាំងអស់នោះគឺមិនមានចម្លើយសារភាព ឯកសារជាចម្លើយសារភាពនោះទេ ឌុច បាននិយាយថាជាក្រុមមនុស្សដែលបានរត់ចេញទៅ គឺថាជាមនុស្សដែលមានគួរឱ្យមានការមន្ទិលសង្ស័យចំពោះភាពស្មោះត្រង់របស់ពួកគេ។

**ស៖** តើអ្នកទាំងអស់នេះគឺជាប្រជាជនកម្ពុជា ឬក៏ជាប្រជាជនវៀតណាម?

**ឆ៖** អ្នកទាំងអស់នោះគឺជាប្រជាជនកម្ពុជាទាំងអស់។ ដោយសារតែខ្មែរក្រហមនៅពេលនោះក៏បានចោទប្រកាន់ថា ជាពួកក្បាលយួនខ្លួនខ្មែរ។ ដូច្នេះត្រូវតែ -- អ្នកទាំងអស់ហ្នឹងត្រូវបានគេបង្វិលក្បាល គឺថាទៅជាក្បាលយួនទៅហើយ ដោយសារអ្នកទាំងអស់នុំងមានទីតាំងរស់នៅទីក្រុងហាណូយ។ ខ្ញុំដឹងថាអ្នកទាំងអស់នោះ គឺជាប្រជាជនខ្មែរទាំងអស់ អ៊ីចឹងគេសង្ស័យថា អ្នកទាំងអស់នោះលែងមានខួរក្បាលជាប្រជាជនខ្មែរទៀតទេ។

[១១:៣៥:៥៦]

**ស៖** សូមអរគុណលោកសាក្សី ដែលបានឆ្លើយទៅនឹងប្រធានបទនេះ។ បន្ទាប់ទៅនេះ គឺខ្ញុំចូល

ទៅព្រឹត្តិការណ៍មុនឈានទៅដល់ថ្ងៃទី១៧ មេសា ៧៥។ ហើយទាក់ទងទៅនឹងចំណុចនេះ ខ្ញុំចង់ពិភាក្សាទៅលើសេចក្ដីសម្រេចមួយ ដែលយោងទៅតាមសៀវភៅរបស់លោកសរសេរថា នៅក្នុងឆ្នាំ១៩៧៤ និងទាក់ទងទៅនឹងការជម្លៀសប្រជាជនចេញទីក្រុងនិងទីប្រជុំជន។ ឥឡូវនេះខ្ញុំមើល -- ខ្ញុំសូមឲ្យជំនួយការខ្ញុំយកសៀវភៅ -- ផ្នែកនៃសៀវភៅដែលពាក់ព័ន្ធ គឺសៀវភៅស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជា ដែលលោកជាអ្នកសរសេរនេះ។ ខ្ញុំសូមឲ្យយកអត្ថបទជាក្រដាសជូនទៅសាក្សី។ ឯកសារនេះគឺ D336/7.1.69, ERN ជាភាសាខ្មែរ 00679171 ដល់ 72, ERN ជាភាសាអង់គ្លេស 00422838 ដល់ 9។

[១១:៣៧:៤៦]

ខ្លឹមសារដែលខ្ញុំចង់មកបង្ហាញលោកអ្នកជំនាញ គឺដូចតទៅនេះ៖ ខ្ញុំសូមអានខ្លឹមសារពីរបីចំណុច។ ទីមួយគឺ៖ "សប្ដាហ៍បន្ទាប់ពីថ្ងៃ១៧ មេសា ៧៥ ប្រជាជនកម្ពុជាជាង២លាននាក់ត្រូវបានជម្លៀសទៅកាន់ជនបទ"។ ខ្ញុំសូមបង្ហាញឯកសារនេះជាភាសាខ្មែរនៅអេក្រង់ ដើម្បីឲ្យសាធារណជនអាចមើលបាន។ ហើយខាងក្រោមមួយទៀត ខ្ញុំសូមដកស្រង់៖ "ការជម្លៀសប្រជាជនធ្វើឲ្យជនរងគ្រោះមានការរន្ធត់ភ្ញាក់ផ្អើលយ៉ាងខ្លាំង។ គេសង្ឃឹមថារដ្ឋាភិបាលថ្មីនឹងព្យាយាមផ្សះផ្សាទាំងអស់នេះ។ បុរសស្ត្រីទាំងអស់នេះប្រហែលជាភ្លេចគិតអំពីសង្គ្រាមស៊ីវិលដែលកើតឡើងដោយភាគីទាំងសងខាងនេះ។ គំនិតយោបល់របស់បដិវត្តន៍ឃើញថា ការជម្លៀសប្រជាជន គឺជាមធ្យោបាយតែមួយគត់ដើម្បីបំបែកបំបាក់ខ្សែរយៈរបស់ខ្មាំង"។

[១១:៣៨:៥៧]

ហើយខ្លឹមសារបន្ទាប់នោះ ទាក់ទងទៅនឹងពេលវេលានៃការធ្វើសេចក្ដីសម្រេចជម្លៀសប្រជាជននេះ។ ដកស្រង់៖ "ការជម្លៀសប្រជាជន គឺធ្វើឡើងដោយបក្សកុម្មុយនីស្តកម្ពុជាភ្លាមៗ បន្ទាប់ពីការរំដោះទីក្រុងភ្នំពេញ ហើយដែលមានការបញ្ជាពីបក្សកុម្មុយនីស្តកម្ពុជា គួរឲ្យភ្ញាក់ផ្អើលបំផុត។ ហេតុផលមួយនៃសេចក្ដីសម្រេចនេះ គឺដោយសារតែនៅទីក្រុងខ្វះចំណីអាហារ ហើយប្រជាជននៅទីក្រុងអាចមានការប៉ះពាល់ប្រឆាំងទៅនឹងបដិវត្តន៍ ហាក់បើឲ្យប្រជាជននៅទីក្រុងអាចនឹងមានអសន្តិសុខទៅដល់បដិវត្តន៍។ ហើយចំណុចនេះគឺជាការមួយចង់បញ្ជាក់ឲ្យឃើញពីជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា ហើយបញ្ជូនប្រជាជនទៅកាន់ទីជនបទ។ សាឡុត ស និងសហការីរបស់គាត់បានចំណាយពេលប្រាំពីរឆ្នាំនៅក្នុងព្រៃ និងប្រាំឆ្នាំក្នុងសង្គ្រាមស៊ីវិល។ ពួកគាត់យល់ឃើញថា ទីក្រុងគឺជាមូលដ្ឋានលានដ្ឋានចម្បងសម្រាប់ធ្វើការជំទាស់តវ៉ាប្រឆាំងនេះ។ ការបញ្ជូនទៅជនបទ គឺដើម្បីផលប្រយោជន៍

នៃការបង្កបង្កើនផលស្រូវនេះឯង”។

លោកសាស្ត្រាចារ្យ ទាក់ទងទៅនឹងសេចក្តីសម្រេចនៅក្នុងឆ្នាំ៧៤ ដែលខ្ញុំរៀបរាប់តាមលំដាប់លំដោយនេះ តើលោកអាចពន្យល់បន្ថែមទៅលើ -- បើយោងទៅលើការសិក្សាស្រាវជ្រាវរបស់លោក ថាតើអ្នកណាជាអ្នកធ្វើសេចក្តីសម្រេចនេះ? ហើយបើសិនជាអាចប្រព្រឹត្តទៅបាននោះ គឺថាសម្រេចឡើងនៅពេលណាដែរនោះ?

**ឆ៖** ខ្ញុំសុំលេខទំព័របានទេ លោកសហព្រះរាជអាជ្ញា?

[១១:៤០:៥៤]

**ស៖** សូមលោកមើលសៀវភៅប្រវត្តិសាស្ត្រកម្ពុជានៅលើទំព័រ២១០ និងទំព័រ២១១។ ទំព័រទាំងពីរនេះ អាចនឹងសម្រួលដល់លោកបាន។

**ឆ៖** ខ្ញុំអត់បាននិយាយថា ឆ្នាំ១០៧៤ (ស៊ីក) ខ្ញុំនិយាយអំពីសេចក្តីសម្រេចធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៥។ ខ្ញុំប្រើពាក្យថា “ភ្លាមៗ គឺរយៈពេលខ្លីមុនជ័យជម្នះ”។ ប៉ុន្តែភស្តុតាង មកពីភស្តុតាង-- ខ្ញុំនិយាយថា “សេចក្តីនេះសម្រេចនេះធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ១៩៧៥”។ ខ្ញុំគិតថា ប្រហែលជាអាចមានការយល់ច្រឡំ។ កាលបរិច្ឆេទដែលត្រឹមត្រូវនោះ គឺខែកុម្ភៈ ឆ្នាំ១៩៧៥ទៅវិញទេ។

[១១:៤១:៥៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំសូមអរគុណលោកអ្នកជំនាញ គឺការដែលលើកឡើងឆ្នាំ៧៤នេះ គឺខ្ញុំទាញចំណាប់អារម្មណ៍។ ខ្ញុំអរគុណណាស់ដែលលោកអ្នកជំនាញបានកែតម្រូវកាលបរិច្ឆេទនេះ។ ប៉ុន្តែក្នុងពេលនេះ គឺយើងឃើញមានការជំទាស់តវ៉ា។ ដូច្នេះសូមស្តាប់ការជំទាស់តវ៉ាសិន។

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន។ ខ្ញុំបានយកចិត្តទុកដាក់ស្តាប់យ៉ាងខ្លាំងទៅនឹងអ្វីដែលសហព្រះរាជអាជ្ញាបានអាននោះ។ សហព្រះរាជអាជ្ញាបាននិយាយថា ឆ្នាំ៧៤។ ដូច្នេះ អ្វីដែលតំណាងសហព្រះរាជអាជ្ញាចង់បាននោះ គឺគាត់អានពីកន្លែងផ្សេង ដើម្បីយកមកឈានដល់ការតាំងជាសំណួររបស់គាត់។ ខ្ញុំថានេះជាការទាញយកប្រយោជន៍របស់គាត់ហើយ។ ត្រូវតែយោង ខ្ញុំយល់ថា ត្រូវតែយោងទៅលើឯកសារជាក់លាក់ណាមួយ ហើយសុំឲ្យណែនាំទៅដល់តំណាងសហព្រះរាជអាជ្ញាឲ្យសួរ ឲ្យលើកឡើងតែឯកសារណា សួរសំណួរណាដែលទាក់ទងទៅនឹងឯកសារណាជាក់លាក់ប៉ុណ្ណោះ។

សូមអរគុណលោកប្រធាន។

[១១:៤៣:១៩]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំមិនបាននាំឲ្យអ្នកជំនាញយល់ខុសនោះទេ។ ការដែលខ្ញុំយកឆ្នាំមកប្រើប្រាស់នេះ គឺវាមាននៅសៀវភៅមួយផ្សេងទៀត។ ដើម្បីចៀសវាងកុំឲ្យមានការយល់ច្រឡំ ខ្ញុំសូមអានខ្លឹមសារ ដែលលោកអ្នកជំនាញគាត់អាចនឹងឆ្លើយមកបាននោះ។ បើសិនជាអង្គជំនុំជម្រះអនុញ្ញាត ខ្ញុំសូមអាន សៀវភៅមួយផ្សេងទៀតដែលបានលើកឡើងអំពីកាលបរិច្ឆេទដែលខ្ញុំទើបលើកឡើងអម្បាញ់មិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ ហើយសូមរំឭកជាបន្ថែមទៀតទៅដល់អ្នកជំនាញ សូមសម្រួល នូវការឆ្លើយរបស់លោកឲ្យបានយឺត។ ដល់ពេលលោកនិយាយទៅ ញាប់ពេក ហើយអ្នកបកប្រែភាសា បកប្រែភាសាមិនទាន់ទេ។

**លោក គង់ សំអុន៖**

លោកប្រធាន សូមអនុញ្ញាត។ អម្បាញ់មិញ ខ្ញុំបានឮថាលោកប្រធានអនុញ្ញាតហើយ ក៏ប៉ុន្តែ តំណាងសហព្រះរាជអាជ្ញាបានបញ្ជាក់ថា តើជាសៀវភៅអីទៅដែលលោកនឹងបង្ហាញនេះ? សូម អធ្យាស្រ័យ សូមជួយបញ្ជាក់ផង។

[១១:៤៤:៤៥]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សៀវភៅដែលខ្ញុំយោង គឺសៀវភៅបងធំទី១ ដែលមានចំណង ជើងថា“បងធំទី១” គឺឯកសារ E3/17។ ខ្លឹមសារនេះ គឺពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចជម្លៀសប្រជាជន ចេញពីទីក្រុង ដែលបានយកមក -- សេចក្តីសម្រេចដែលបានធ្វើឡើងនៅមុនខែមេសា ៧៥នោះ។ ERN ជាភាសាខ្មែរ 0082176, អង់គ្លេស ERN 0093016 នៅភាសាអង់គ្លេស គឺនៅត្រង់ទំព័រ១០២។ ហើយប្រសិនណាជាខ្ញុំអាចបង្ហាញភាសាខ្មែរ នៅលើអេក្រង់ វាជាការប្រសើរហើយ គឺនៅត្រង់ទំព័រនេះ គឺនិយាយថា “មកដល់ចុងឆ្នាំ១៩៧៤ ជួ ជេត ដែលជាលេខាភូមិភាគនិរតី គឺគាត់បានប្រជុំនៅកំពង់ឆ្នាំង គឺថាដើម្បីវាយប្រហារជាលើកទីបួន។ ប៉ុល ពត បានប្រកាសនៅក្នុងឆ្នាំ១៩៧៧ ថាគណៈមជ្ឈិមបាន សម្រេចការវាយប្រយុទ្ធជាចុងក្រោយ នៅខែមិថុនា ៧៤”។

[១១:៤៦:៣៤]

ហើយបើយើងមើលមកកថាខណ្ឌខាងក្រោមមកទៀតនោះ សារដែលខ្ញុំត្រូវអានដូចខាងក្រោមនេះ៖ “នៅពេលនោះ គណៈមជ្ឈិមបានសម្រេចថា តើគណៈបក្សកុម្មុយនីស្តកម្ពុជានឹងត្រូវចាត់វិធានការបែបនេះ។ ទីមួយ ត្រូវតែជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ និងទីក្រុងដទៃៗទៀត ដើម្បីពង្រឹងប្រជាជនជាង២លាននាក់ឲ្យទៅកាន់ទីជនបទ។ ធ្វើដូច្នេះ គឺថានោះមិនមានការគំរាមកំហែងអ្វីមកដល់បក្សនោះទេ។ ហើយបក្សអាចនឹងបំពេញការងារប្រកបទៅដោយផ្លែផ្កា”។ នៅត្រង់ចំណុចនេះ គឺគណៈមជ្ឈិមក៏បានសម្រេចលុបបំបាត់ការចាយវាយលុយកាក់ បំបាត់ទីផ្សារ និងកម្មសិទ្ធិជននៅទាំងប្រទេសផងដែរ។ ពួកកម្មាភិបាលទាំងអស់ត្រូវបានគេប្រាប់ឲ្យដឹងអំពីសេចក្ដីសម្រេចទាំងនេះ នៅពេលរៀបចំវាយលុកផ្ដាច់ព្រ័តប៉ុណ្ណោះ។

ខ្ញុំបានយោងឯកសារនេះ គឺនៅលើឆ្នាំ១៩៧៤ ដូច្នេះ សូមមេត្តាបំភ្លេចនូវការបកស្រាយ ឬក៏ថាឆ្នាំដែលខ្ញុំលើកឡើងនេះ សូមឲ្យលោកអ្នកជំនាញលើកឡើងអំពីការចងចាំរបស់លោកផ្ទាល់ទៅចុះ។

**ឆ៖** ខ្ញុំមិនបាននិយាយថា កិច្ចប្រជុំរបស់គណៈមជ្ឈិមបានធ្វើឡើងនៅឆ្នាំ៧៤នេះណាទេ ខ្ញុំគ្រាន់តែនិយាយថា សៀវភៅដែលខ្ញុំសរសេរ២០ឆ្នាំមកហើយ។ ខ្ញុំនិយាយថា នៅអំឡុងពេលនោះ គឺអំឡុងពេលដែលខ្ញុំសរសេរសៀវភៅ ខ្ញុំលើកឡើងអំពីសេចក្ដីសម្រេច ដោយមិនបាននិយាយអំពីខែឆ្នាំទេ។ ខ្ញុំគ្រាន់តែនិយាយប្រហែលជាអាចខែកុម្ភៈ ៧៥។ ខ្ញុំគ្រាន់តែផ្ដល់គំនិតថា ជាសេចក្ដីសម្រេចឆ្នាំ៧៤ ខ្ញុំមិនបានថា ឆ្នាំ៧៤ទេ គឺគ្រាន់តែសេចក្ដីសម្រេចនោះ គឺថាធ្វើឡើងនៅដើមឆ្នាំ៧៥តែប៉ុណ្ណោះ។

[១១:៤៨:៥៤]

**ស៖** សូមអរគុណលោកអ្នកជំនាញ ដែលបានបញ្ជាក់ត្រង់ចំណុចនេះ។ បាទ មានការបង្គាប់មកខ្ញុំឲ្យនិយាយឲ្យបានយឺតៗ សូមអធ្យាស្រ័យពីអ្នកបកប្រែផងដែរ។ ជាពិសេសអ្នកបកពីខាងអង់គ្លេសទៅបារាំងនោះ។ ឥឡូវនេះ និយាយអំពីពេលវេលាដែលនៃការចេញសេចក្ដីសម្រេចនោះ។ និយាយអំពីសេចក្ដីសម្រេចមួយចំនួន សូមដកស្រង់៖ “គោលបំណងនៃការចង់បានជ័យជម្នះរបស់បក្សកុម្មុយនីស្តកម្ពុជា គឺចង់ផ្ដល់សិទ្ធិសេរីភាពទៅឲ្យអ្នកក្រីក្រ ហើយជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ”។ ថាតើលោកចង់និយាយម៉េច?

**ឆ៖** ខ្ញុំនៅរក្សាខ្លឹមសារនេះដដែល ពីព្រោះខ្មែរក្រហមមិនដែលនិយាយអំពីហេតុផលចម្បងៗនៃការឈានទៅកាន់ការទទួលជ័យជម្នះនេះទេ។ គេលើកហេតុផលផ្សេងមកនិយាយជាមួយខ្ញុំវិញទេ។ គេ

បាននិយាយថា គឺដោយសារតែការបារម្ភខ្វះស្បៀងអាហារ។ ប៉ុន្តែការជម្លៀសប្រជាជននេះគឺជាការខកខានមួយដែលគេមិនដែលមានការសម្តែងការសោកស្តាយ មិនដែលនិយាយម្តងណាទេនៅក្នុងអំឡុងពេលរបបនោះទាំងមូលតែម្តង។ មិនមានអ្វីដែលបានលើកឡើងនិយាយក្នុងពេលនោះ ខៀវ សំផន បានធ្វើការជំទាស់ទៅលើចំណុចនេះ។

[១១:៥០:៥១]

ប្រជាជននៅទីក្រុងនោះត្រូវបានគេកំណត់និយមន័យថាជា "ខ្មាំង"។ អ្នកទីក្រុងនេះគឺជាខ្មាំង។ គេបានវាយរំដោះប្រជាជនទាំងនេះឲ្យរួចពីកណ្តាប់ដៃពួកមូលធននិយម ពួកចក្រពត្តិនិយម ហើយឲ្យអ្នកទាំងអស់នោះក្លាយទៅជាប្រជាជនធម្មតាដូចគេដូចឯង។ ប៉ុន្តែគេ -- ប្រជាជនត្រូវបានគេប្រាប់ថាអាមេរិកាំងនឹងទម្លាក់គ្រាប់បែកក្នុងពេលឆាប់ៗនេះ។ ហើយប្រជាជនមិនបានគិតថានឹងមានអ្វីកើតឡើងទៅដល់ពួកនោះទេ។ គឺថានឹងមានការទម្លាក់គ្រាប់បែកដូចកាលពីឆ្នាំ៧៣ អ៊ីចឹង។ ដូច្នេះជាការធ្វើឲ្យប្រជាជនមានអារម្មណ៍ខឹងសម្បាទៅដល់អាមេរិក។ ទាំងអស់នេះគឺថា គឺជារឿងចម្រូងចម្រាស់មួយដែលឈានទៅដល់វគ្គផ្តាច់ព្រាត់ដល់ការទទួលជ័យជម្នះ។ ប៉ុន្តែជាចុងបញ្ចប់គឺថាវាមានភាពឃោរឃៅ ហើយមិនដែលមានអ្នកណាសម្តែងការសោកស្តាយទៅដល់ការជម្លៀសប្រជាជនចេញពីទីក្រុងទេ។ គឺការជម្លៀសនេះ គឺចង់ឲ្យប្រជាជនទាំងអស់នេះក្លាយទៅជាកសិករធ្វើស្រែ ធ្វើចម្ការដូចគេ ដូចឯង។

[១១:៥២:២១]

**ស៖** សូមអរគុណលោកសាស្ត្រាចារ្យ។ លោកបានបញ្ជាក់ថាប្រជាជននៅទីជនបទនេះ គឺជាប្រភពនៃកម្លាំងពលកម្ម។ ខ្ញុំចង់ចូលទៅដល់ការលើកឡើងអំពីប្រជាជននៅទីប្រជុំជន ហើយនៅក្នុងសេចក្តីសន្និដ្ឋានរបស់លោក ថាតើត្រូវបានគេចាត់ថ្នាក់ជាមនុស្សប្រភេទណា? ហើយគេប្រព្រឹត្តចំពោះគាត់ដោយរបៀបណា? ខ្លឹមសារទីមួយដែលខ្ញុំចង់អាននោះគឺនៅក្នុងសៀវភៅ "បងធំទី១" នេះដែរ។ គឺឯកសារ E3/17 នេះ ERN ជាភាសាខ្មែរ 00821666, ERN ភាសាអង់គ្លេស 00392915 គឺជាឯកសារនៃ -- អានបន្តពីទំព័រដែលទើបនឹងបានអានខាងមុននេះបន្តិចនេះ។

[១១:៥៣:៥០]

ខ្លឹមសារនេះសង្ខេបទេ ខ្ញុំសូមអានតែម្តង៖ "នៅពេលដែលគេសួរទៅកងទ័ពក្មេងៗប្រដាប់ទៅដោយអាវុធនោះគឺបាន -- សូមដកស្រង់៖ "អង្គការបដិវត្តន៍ គឺជាម៉ែជាឪ" បិទការដកស្រង់។ អ្នកទាំងនេះត្រូវបានគេហៅថា "ជាពួក១៧មេសា ឬ ប្រជាជនថ្មី" ដោយសារអ្នកទាំងនេះបានចូលរួមជាមួយ

បដិវត្តន៍ទើបតែនៅពេលថ្មីៗនេះតែប៉ុណ្ណោះ។ ហើយពួកនេះគឺថាត្រូវ -- ឯប្រជាជនចាស់គឺថាត្រូវបានគេប្រព្រឹត្តជាមិនធ្ងន់ធ្ងរ ដូចជាប្រជាជនថ្មីនោះទេ។ ខ្ញុំសូមឱ្យលោកអ្នកជំនាញមេត្តាពន្យល់អំពីខ្លឹមសារនេះ។

[១១:៥៤:៤៤]

ខ្ញុំក៏ចង់យោងទៅលើខ្លឹមសារមួយទៀតដែរ គឺនៅក្នុងសៀវភៅចំណងជើងថា "សោកនាដកម្មនៃប្រវត្តិសាស្ត្រកម្ពុជា" ត្រង់ទំព័រ២៤២ យើងមានតែជាភាសាអង់គ្លេសទេ ERN ជាភាសាអង់គ្លេសគឺ 00193325។ ហើយនៅត្រង់ទំព័រនេះគឺលោកសរសេរថា "នៅក្នុងឆ្នាំ១៩៧៥ គឺមានអំពើហិង្សាកើតឡើងទ្រង់ទ្រាយធំនៅបាត់ដំបង ជាងនៅភូមិភាគដទៃទៀត ហើយប៉ុន្តែសិទ្ធិបុគ្គល គឺត្រូវតែស្ថិតនៅក្រោមបដិវត្តន៍ ហើយត្រូវតែចាត់ទុកថា ជាវណ្ណៈកម្មករក្រីក្រ។

មុននឹងពាក្យថា អង្គការត្រូវបានគេដឹងនេះ ដកស្រង់សម្តី "គឺពួក១៧មេសា"។ បិទសម្រង់។ ត្រូវបានដាក់ទណ្ឌកម្ម ឬប្រព្រឹត្តធ្ងន់ធ្ងរ ដូចជាការបំបែកបំបាក់គ្រួសារ គេបង្ខំឱ្យប្រាប់អំពីការពិត អំពីប្រវត្តិគ្រួសាររបស់ខ្លួន ឬក៏ប្រវត្តិនៃការរស់នៅរបស់ខ្លួន។ ប្រសិនណាជាគេ ខ្ញុំអាចចាប់ផ្តើមបានទៅនឹងការចាត់ចំណាត់ថ្នាក់ប្រជាជន ឱ្យទៅជាប្រជាជនថ្មី និងប្រជាជនមូលដ្ឋាន។ តាមការសិក្សាស្រាវជ្រាវរបស់លោកនោះ ថាតើការចាត់ចំណាត់ថ្នាក់ប្រជាជនបែបនេះ មានន័យយ៉ាងដូចម្តេចដែរ?

[១១:៥៦:៣០]

**ឆះ** ខ្ញុំថា ជាការស្រួលទេ គឺគេចាត់ថ្នាក់ប្រជាជននេះគឺស្រួលណាស់ គឺបដិវត្តន៍នៅពេលដែលទទួលជ័យជម្នះលើពួកគេនេះ គឺភាសាខ្មែរក្រហមនោះ គេប្រើពាក្យហាក់បីដូចជាទន់ភ្លន់ស្រាល គេហៅថា "ប្រជាជន១៧មេសា ឬ ប្រជាជនថ្មី"។ ខ្ញុំគិតថា ម្នាក់ៗយល់ច្បាស់ហើយ គឺជាប្រជាជនដែលគេកំណត់គោលដៅថា ជាខ្មាំង ឬក៏ថា ពួកគេងាយស្រួលក្នុងការកំណត់ទិសដៅថាជាខ្មាំង ងាយស្រួលក្នុងការតាមដានអ្នកទាំងនេះ។

**សះ** ហើយបើយើងមើលទៅការដាក់ទណ្ឌកម្ម ឬក៏ថា មើលទៅលើមូលហេតុនៃការដាក់ទណ្ឌកម្ម ឬប្រព្រឹត្តមកលើប្រជាជនទាំងនេះ ដូចដែលលោកសន្និដ្ឋាននោះ ដូចជា ការបង្ខិតបង្ខំបំបែកបំបាក់ពីគ្រួសារ ការបង្ខំឱ្យឆ្លើយប្រាប់នូវការពិត។ តើចំណុចនេះវាងាកចេញអំពីគោលនយោបាយ ឬក៏ទិសដៅរបស់បក្ស ឬក៏យ៉ាងណាដែរ?

[១១:៥៨:០១]

**ឆ៖** ខ្ញុំមិនអាចលើកឡើងអំពីគោលនយោបាយដើមឲ្យបានចំៗនោះទេ ប៉ុន្តែឋានៈរបស់ប្រជាជនទាំងនេះ គឺអ្វីៗវាកើតចេញអំពីចំណុចនៃការសង្ស័យទៅលើប្រជាជនទាំងនេះ វាមានបញ្ហា ឬក៏ធាតុមួយចំនួនទៀត ពាក់ព័ន្ធទៅនឹងប្រជាជនទាំងអស់នេះ គឺគេចង់ធ្វើការអប់រំកែប្រែកសាងអ្នកទាំងនេះ គឺកសាងប្រជាជនថ្មីទាំងហ្នឹង ឲ្យក្លាយទៅជាប្រជាជនខ្មែរពិតៗឲ្យធ្វើការដោយលំបាកលំបិន ដូចគេដូចឯង គោលបំណងគឺដើម្បីអប់រំកែប្រែអ្នកទាំងនេះតែម្តង។ ប៉ុន្តែអ្វីដែលខ្មែរក្រហមប្រព្រឹត្តចំពោះខ្មាំងគឺ ឬក៏ដូចជា ប្រជាជនដែលស្ថិតនៅក្នុងរបប លន់ នល់ គឺគេអប់រំកែប្រែអ្នកទាំងនេះ ថាកុំឲ្យធ្វើដូចនេះតទៅទៀត។ សម្រាប់អ្នកទាំងនេះ កាលណាគេអប់រំកែប្រែបីដងហើយ នៅតែប្រព្រឹត្តបែបនេះគឺ ចប់ហើយ។ ដូច្នេះ ការដែលធ្វើបែបនេះគឺ ខ្មែរក្រហមចង់មានអត្តន័យបែបនេះ គឺដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់ខ្លួន។

[១១:៥៩:២៤]

**ស៖** ឥឡូវនេះ បើសិនណាយើងអាចចូលទៅនឹងការចាត់ថ្នាក់ប្រជាជន ប្រហែលជាសំណួរចុងក្រោយរបស់ខ្ញុំហើយមុននឹងឈប់សម្រាក។ យោងអាស្រ័យទៅលើការសម្រេចរបស់លោកប្រធាន ឯកសារ D108/ --

**អ្នកបកប្រែ៖**

សូមអធ្យាស្រ័យលោកប្រធាន អ្នកបកតាមអត់ទាន់ ERN សូមម្តងទៀត។

**ប្រធានអង្គជំនុំ៖**

សូមម្តងទៀត! ព្រោះអ្នកបកប្រែស្តាប់អត់ទាន់។ អ៊ីចឹងបកប្រែអត់បានទេ។

**លោក អាប់ឌុលឡាក់ ថារីក៖**

បាទ អរគុណលោកប្រធាន។ ERN ជាភាសាខ្មែរ 00182517 ដល់ 18, ERN អង់គ្លេស 00192815, ហើយ ERN បារាំងគឺ 00357395។ ហើយខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះជូនឯកសារជាក្រដាសជូនដល់អ្នកជំនាញផងដែរ គឺត្រង់ទំព័រ១២២។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** នៅត្រង់ទំព័រនេះ គឺលោកនិយាយអំពីការចាត់ថ្នាក់ប្រជាជន។ សូមដកស្រង់៖ “នៅគ្រប់ទីកន្លែងទាំងអស់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ អ្នកទាំងអស់នេះ គឺគេផ្តល់ឋានៈ និងត្រូវតែឆ្លងកាត់ប្រវត្តិ -- ទោះបីជាសមាជិកត្រៀម ឬក៏សមាជិកពេញសិទ្ធិក៏ដោយ។ តែផ្ទុយទៅវិញ ប្រជាជនថ្មីដែល

មកពីទីប្រជុំជនដែលមិនមានប្រវត្តិបដិវត្តន៍នោះ ដែលក្រោយមកត្រូវគេដឹង ស្គាល់ថា ជាពួកបញ្ញើក្អែក គឺអ្នកដែលត្រូវគេជម្លៀសទៅកាន់ទីជនបទ"។ លោកអ្នកជំនាញ គឺបានចាត់ -- យោងទៅលើការចាត់ថ្នាក់ប្រជាជនជាបីប្រភេទ។ តើលោកអាចពន្យល់បង្ហាញចំពោះការចាត់ថ្នាក់នេះបានដែរឬទេ? ជាពិសេស គឺការចាត់ថ្នាក់សំដៅទៅលើពួកប៉ារ៉ាស៊ីត ឬក៏ថាពួកបញ្ញើក្អែកនេះ?

[១២:០២:១២]

**លោក ដេវីដ ឆេនដ៏ល័រ៖**

**ឆ៖** ក្នុងចំណោមប្រជាជនថ្មី គឺមិនដឹងថាតើវានឹងរីករាយដាលដោយរបៀបណានោះទេ? ការបំបែកនេះ គឺដើម្បីឲ្យអ្នកទាំងនោះក្លាយទៅជាប្រជាជនកម្ពុជាស្អាតស្អំ ក្លាយមកពីប្រជាជនកម្ពុជាដែលមិនស្អាតស្អំ ក៏ដូចជាប្រជាជន ក៏ដូចជាសមាជិកត្រៀម ដែលនឹងត្រូវឈានចូលទៅក្លាយទៅជាសមាជិកពេញសិទ្ធិរបស់បក្សនោះ។ ប៉ុន្តែនៅក្នុងឆ្នាំ៧៨ គឺបក្ស គឺបានដកចេញអំពីការចាត់ថ្នាក់ប្រជាជនបែបនេះហើយ។ គឺត្រូវឈប់ចាត់ថ្នាក់ប្រជាជនបែបនេះៗតទៅទៀតហើយ។ គឺការចាត់ថ្នាក់នេះ តាមដែលខ្ញុំយល់នោះ គឺដើម្បី ទីមួយ ពង្រឹងប្រជាជនចេញពីទីក្រុងហើយ ចាត់ថ្នាក់ប្រជាជនបែបនេះ ដើម្បីតាមដាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកសាស្ត្រាចារ្យ។ លោកប្រធាន ថាតើលោកអនុញ្ញាតឲ្យខ្ញុំសួរបន្តទៅទៀត ឬក៏ត្រូវឈប់សម្រាកសិន?

[១២:០៣:២៥]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ហើយ។ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសារអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះ សឹមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

ហើយមន្ត្រីរដ្ឋបាលតុលាការ ផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី និងអ្នកជំនាញដល់លោកអ្នកជំនាញនៅក្នុងអំឡុងពេលសម្រាកពិសារអាហារថ្ងៃត្រង់ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ វេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញបាទ!

[១២:០៤:០៧]

**លោក ហ្សាស្តេី ប៉ោះ**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំ នួន ជា ចង់សុំអនុញ្ញាតទៅតាមដានពីបន្ទប់នៅខាងក្រោម ហើយអនុលោមទៅតាមការណែនាំម្សិលមិញនោះ យើងសូមជម្រាបតុលាការថា លោក នួន ជា មិនមានជំងឺ ថាមិនផ្តង់អារម្មណ៍មិនបានទេ។ ហើយមានរោគសញ្ញាទូទៅទៀត ដែលគាត់ជំងឺមនុស្សជំងឺមនុស្សចាស់ ហើយគាត់ក៏មានជំងឺឈឺក្បាលផងដែរថ្ងៃនេះ ហើយឈឺខ្នងផងដែរ។ ហើយខ្ញុំសូមអនុញ្ញាតតុលាការសម្រេចតាមឆន្ទានុសិទ្ធិ។ ហើយយើងខ្ញុំនឹងគោរពទៅតាមនីតិវិធី ហើយសូមអនុញ្ញាតឲ្យគាត់បានទៅតាមដានពីបន្ទប់ខាងក្រោមនេះបាទ។

**ប្រធានអង្គជំនុំ៖**

បានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ស្នើសុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមប្រព័ន្ធសោតទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការនៅរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ។ ដោយបង្ហាញពីមូលហេតុនៃបញ្ហាសុខភាព មានអាការៈឈឺក្បាលឈឺខ្នង ដែលពិបាកនៅក្នុងការអង្គុយតាមដានក្នុងរយៈពេលយូរផ្ទាល់នៅកន្លែងក្នុងបន្ទបស់សវនាការ។

អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោត-ទស្សន៍សម្រាប់រយៈពេលដំណើរការសវនាការនៅរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ។

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់មកអង្គជំនុំជម្រះភ្លាមនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់ពីជនជាប់ចោទ។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនស្ថិតនៅក្រោមសាលសវនាការនេះ ក្នុងអំឡុងពេលនៃដំណើរការសវនាការនៅរសៀលនេះ។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា និងខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ។ ដោយនៅរសៀលនេះ ទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែកលោក ខៀវ សំផន ឲ្យនាំខ្លួនគាត់មកកាន់សាលសវនាការនេះវិញនៅរសៀលនេះឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៧ នាទី ដល់ម៉ោង ១៣:៣០ នាទី)*

[១៣:៣០:៥១]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

សូមអញ្ជើញ!

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរលោក លោកស្រីចៅក្រម សូមជម្រាបសួរលោកសាស្ត្រាចារ្យ ឆេនដ័ល័រ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** យើងបានពិភាក្សាមុនពេលសម្រាកនេះ អំពីចំណាត់ថ្នាក់ប្រជាជន បាទចាប់ពីឆ្នាំ១៩៧៥ តាមដែលយើងបានឃើញបាទ ហើយជាពិសេសបន្ទាប់ពីឆ្នាំ១៩៧៥ នោះ ចំណាត់ថ្នាក់ប្រជាជន ហើយនិងការប្រព្រឹត្តរបស់អង្គការទៅលើប្រជាជននោះផងដែរ។ បន្តពីចំណុចនេះទៅមុខទៀត ខ្ញុំចង់ពិភាក្សាជាមួយលោកបន្ទាប់នោះ គឺការវិភាគរបស់លោកអំពីផែនការបួនឆ្នាំរបស់របបនោះ ដែលតាមពិតជាការពិភាក្សា ឬក៏ការបង្កើតនៅសៀវភៅដែលចៅក្រម ខាតវ៉ាយថ៍ បានយោងពីម៉្យិលមិញ គឺនិយាយអំពី

ផែនការអនាគតរបស់ ប៉ុល ពត។

[១៣:៣២:៥០]

ខ្ញុំចង់ពិនិត្យមើលចំណុចនេះ ដូចដែលយើងពិនិត្យមើលថា តើអ្វីជាការសន្និដ្ឋាន ការវិភាគរបស់លោកទៅលើចំណុចនេះ។ ដើម្បីជាអត្ថប្រយោជន៍ដល់ភាគីទាំងអស់ ការវិភាគនេះ គឺនៅក្នុងផែនការនេះមាននៅក្នុងសៀវភៅ "បងទី១" បាទ ឯកសារ E3/117 ហើយនៅក្នុង -- នៅសៀវភៅផ្សេងទៀតរបស់សាស្ត្រាចារ្យ ឆេនដ័ល័រ គឺសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា" ដែលជាសៀវភៅ ខ្ញុំនឹងពិនិត្យមើលនៅពេលនេះ។

សាស្ត្រាចារ្យ ឆេនដ័ល័រ សូមលោកពិនិត្យមើលទំព័រ២១៤ រហូតដល់ ២១៦ នៅក្នុងសៀវភៅដែលខ្ញុំនឹងអានជូននៅ ERN ជាភាសាខ្មែរ 00679175 រហូតទៅដល់ 77, អង់គ្លេស ERN 00422842។ នៅក្នុងសៀវភៅដែលមានចំណងជើងថា "បងទី១" នោះលោកបានបញ្ជាក់ថា ផែនការហ្នឹងគឺត្រូវបានដាក់ដោយ ប៉ុល ពត នៅក្នុងខែសីហា។ ប៉ុន្តែនៅកន្លែងនេះ យើងនឹងពិនិត្យមើលខ្លឹមសារនៃផែនការនេះ។ ហើយនិងពិនិត្យមើលការវិភាគរបស់លោកលើខ្លឹមសារនេះ។

[១៣:៣៤:៤០]

នៅក្នុង ERN ក្នុងសៀវភៅប្រវត្តិសាស្ត្រកម្ពុជានោះ លោកបាននិយាយដូចខាងក្រោមនេះ៖

"គេអំពាវនាវឲ្យមានការដាក់រួមនូវទ្រព្យសម្បត្តិ ហើយនិងបង្កើនការផលិតស្រូវទូទាំងប្រទេសដោយមានគោលបំណងឲ្យសម្រេចបាននូវ ឲ្យបានបីតោនក្នុងមួយហិកតា ឬក៏១.៤តោន ក្នុងមួយអារហើយផលស្រូវនោះគឺថាផលិតមុនបដិវត្តន៍ហ្នឹងគឺតិចជាង ហើយមិនបាន -- ហើយបានតិចជាងមួយតោនក្នុងមួយហិកតា។ នៅពេលដែលមានសង្គ្រាមនៅអាស៊ី ទូទាំងអាស៊ីនោះ។ នៅខាងក្រោមនេះលោកបាននិយាយថា ផែនការហ្នឹងគឺត្រូវបានសរសេរដោយប្រញាប់ប្រញាល់មិនមានការ -- ពេលវេលាដើម្បីធ្វើការស្រាវជ្រាវថាតើសំណូមពររបស់ផែនការនេះមានលក្ខណៈសមស្របទៅនឹងស្ថានភាពដី ឬក៏ហេដ្ឋារចនាសម្ព័ន្ធចាំបាច់ឲ្យមានគ្រប់គ្រាន់រួចរាល់នោះទេ ប៉ុន្តែផ្ទុយទៅវិញ ផែនការនេះតម្រូវឲ្យមានយុទ្ធនាការវាយសម្រុក ដោយប្រជាជនទាំងអស់"។

[១៣:៣៥:៥៧]

ហើយនិងសេចក្ដីដកស្រង់បន្តទៅទៀតនៅក្នុងអត្ថបទដដែលនេះ។ នៅខាងក្រោមបន្តិចគឺ ដកស្រង់៖ "មិនមានសម្ភារៈអ្វីសំខាន់ណាមួយត្រូវបានផ្ដល់ជូនប្រជាជនទេ វាលែងតែការសន្យា គឺថា

ម្នាក់ៗត្រូវតែធ្វើទៅតាមគោលការណ៍រហូតទៅគំនិតនេះ រហូតដល់ឆ្នាំ១៩៨០"។ ហើយនៅក្នុងនេះ លោកក៏បាននិយាយអំពីទស្សនៈក្នុងការសម្រេចផែនការនេះ។ ក្នុងពន្យល់ទៅដល់មេដឹកនាំខ្ពស់របស់បក្ស ហើយអ្នកនិយាយដែលមិនបានបញ្ជាក់ឈ្មោះប្រហែលជា ប៉ុល ពត និយាយថា "ផែនការហ្នឹងគឺត្រូវតែសម្រេចឲ្យបានឆាប់រហ័ស។ បដិវត្តន៍កម្ពុជាប្រជាធិបតេយ្យគឺជាបទពិសោធន៍ថ្មី ហើយសំខាន់បំផុតក្នុងពិភពលោកនោះ ពីព្រោះថាយើងមិនធ្វើឲ្យដូចប្រទេសផ្សេងទេ"។ នេះជាភាសាដកស្រង់នៅក្នុងភាសានោះ។ "ហើយយើងផ្ដោះទៅរកសង្គមនិយម ហើយយើងនិងកសាងបដិវត្តន៍សង្គមនិយម ហើយយើងមិនត្រូវការរយៈពេលដើម្បីប្ដូរសង្គមនោះទេ"។

[១៣:៣៧:១៣]

ខ្ញុំសួរលោកថា ឲ្យពន្យល់ដោយសង្ខេបអំពីសេចក្ដីសន្និដ្ឋានរបស់លោកថា ជាមិនមានពេលដើម្បីធ្វើការសិក្សាដើម្បីចងក្រងផែនការនេះទេ ហើយផែនការនេះត្រូវបានចងក្រងប្រញាប់ ហើយៗ តម្រូវឲ្យមានការវាយសម្រុកដោយប្រជាជនហ្នឹងដើម្បីឲ្យសម្រេចផែនការ។

**លោក ដេវីដ ឆេនឌ័លើរ៖**

**ឆ៖** ផែនការដូចនយោបាយផ្សេងៗទៀត ដែលបានកំណត់ដែរ នៅក្នុងកម្ពុជាប្រជាធិបតេយ្យគឺផ្អែកទៅលើការសន្និដ្ឋាន ប៉ុន្តែមិនបានពិនិត្យមើលលទ្ធភាព និងសមត្ថភាពដែលត្រូវយកទៅអនុវត្តនោះទេ។ ខ្ញុំចង់និយាយថា -- ប៉ុន្តែនៅចំណុចចាប់ផ្ដើមនៅខាងដើមនោះមានសេចក្ដីពន្យល់ ប៉ុន្តែ ប៉ុល ពត និយាយថា ជា១បែបបទមួយរបស់កម្ពុជាប្រជាធិបតេយ្យ យើងត្រូវផែន -- ហេតុអ្វីបានយើងត្រូវការ? គឺយើងត្រូវការ។ គឺមិនមានការពិភាក្សាអ្វីទេ យើងត្រូវការជាបន្ទាន់ គាត់មិនបានបញ្ជាក់ទេ ពីព្រោះថាយើងត្រូវការផែនការដើម្បីឲ្យរបបបដិវត្តន៍នៅពេលកាន់អំណាចត្រូវតែមានផែនការអនុវត្តទៅមុខ គឺមិន -- ផែនការហ្នឹងប្រហែលជាត្រូវការមួយឆ្នាំមុន ប៉ុន្តែគឺថាឆាប់ជាងហ្នឹង គឺថាខ្លីៗមុនពេលដែលកាន់អំណាច។ គឺដកស្រង់អំពីការគិតគូរ អំពីអ្វីដែលគេចង់ឲ្យកើតមានឡើងនៅក្នុងកម្ពុជាប្រជាធិបតេយ្យក្រោមការដឹកនាំដែលហៅថាមេដឹកនាំដ៏ឈ្លាសវៃរបស់បក្សកុម្មុយនីស្តកម្ពុជានោះឯង។

[១៣:៣៩:០៩]

ខ្ញុំគិតថា ជាការគ្រាប់តាមមិនបានបញ្ជាក់ថាយកតាមគំរូណាទេ ដូចជាបីតោនក្នុងមួយហិកតានេះ នៅពេលដែលខ្ញុំអានសៀវភៅ "សំឡេងពី ២១" នោះ គឺអាចនឹងយកគំរូមកពីគំរូប្រទេសចិននៅក្នុងឆ្នាំ១៩៧១ ហ្នឹង គឺថាអាចនឹងយកមកពីប្រទេសចិនដូចជាឃ្លា ដូចជាមហាលោតផ្លោះ ជាដើមហ្នឹង

គឺយកតាមគំរូចិន។ គំនិតដែលថាកម្ពុជាសំបូរដោយកសិកម្ម ធនធានកសិកម្មហ្នឹង គឺត្រឹមត្រូវហើយ វាមានសក្តានុពលដែលអាចមើលឃើញនៅពេលនោះ គឺមិននិយាយទៅដល់ធនធានប្រេងទេ នៅពេលនោះ។ ប៉ុន្តែវិស័យកសិកម្មគឺជាប្រភពចំណូលរបស់កម្ពុជា។ ផែនការនេះគឺថាអាចនឹងមានអត្ថន័យដែរ ប៉ុន្តែអនុវត្តមិនបានជោគជ័យទេ ដូចដែលខ្ញុំលើកខាងដើម។ មិនបានពិចារណា ថាតើត្រូវ ធ្វើអ្វី គឺក្នុងឆ្នាំ ៧៥, ៧៦ គេយក -- គេគ្រាន់តែផ្តោតទៅលើថាមហាលោតផ្លោះទៅខាងមុខតែប៉ុណ្ណឹង។ គឺថាគឺផ្អែកទៅលើក្តីសង្ឃឹម ឬការសន្និដ្ឋានមួយដែលគេរំដោះប្រទេសបាន គឺថាជនក្រីក្រឲ្យទៅជាអ្នកដឹកនាំ គឺថាជីវិតប្រចាំថ្ងៃ។ គឺជាកត្តាជំរុញនៃគ្រឿងម៉ាស៊ីនរបស់បដិវត្តឲ្យទៅមុខក្នុងការផលិតទៅតាមផែនការរបស់គេនេះ។ គឺមានការងារនៅក្នុងផែនការដែលយើងត្រូវពិភាក្សា ដូចជាប្រសិន បើយើងមានប្រភពរក -- គឺថាចំណុចសំខាន់នៅទីនេះ គឺគេចង់ដាក់ឲ្យការប្រាថ្នារបស់គេ របស់កម្ពុជាហ្នឹង គឺថាចង់បង្កបង្កើតផលហ្នឹង គឺថាទៅលើការស្រមើលស្រមទេ។ គឺថាទិសដៅនោះគឺបានកំណត់ហើយ ប៉ុន្តែមានការជោគជ័យមួយចំនួនទេ។ គឺថា ប៉ុល ពត មិនបានគិតទេ ប៉ុន្តែភាគច្រើននោះ គឺថាតំបន់សម្រេចបានដែរ។

សំណួរ យើងបានពិភាក្សានៅកន្លែងនេះ អំពីគំនិតដែលចេញមកពី ប៉ុល ពត តើលោកអាចសន្និដ្ឋានបានដែរឬទេ? ថាតើផ្នែកណាមួយ? តើបុគ្គលណាខ្លះ ឬក៏ក្រុមណាខ្លះ ដែលជាអ្នកចេញអនុម័តនូវផែនការនេះ?

[១៣:៤១:៤៥]

**ឆៈ** ខ្ញុំមិនច្រានចោលអត្ថបទដែលខ្ញុំវិភាគ សិក្សានោះទេ គឺមិនចេញពី ប៉ុល ពត តែម្នាក់ឯងនោះ គឺថាចេញពីមេដឹកនាំបក្ស គឺជាសមាសភាពសេចក្តីព្រាងដែលរួមគ្នា គឺអ្នកស្នើខ្លះ -- គឺថាផ្នែកខ្លះ ខៀវ សំផន បានសរសេរ ផ្នែកខ្លះគឺបានសរសេររួមគ្នា ហើយបានអនុម័តរួមគ្នា ហើយចេញពីមេដឹកនាំសមូហភាព។

ជាថ្មីម្តងទៀត គឺយើងមិនអាចរកឃើញហត្ថលេខានៅលើឯកសារកម្ពុជាប្រជាធិបតេយ្យទេ គឺមានតែមេដឹកនាំទេ ដែលអាចពន្យល់ ថាតើគេធ្វើដូចម្តេចនោះ។ ហើយអ៊ីចឹងគឺថា ផែនការនេះ គឺចេញពីការសម្រេចសមូហភាពរបស់ថ្នាក់ដឹកនាំ។ ហើយនៅពេល -- អាចនិយាយថាចេញពីគណៈមជ្ឈិម ប៉ុន្តែមិនមានឯកសារបញ្ជាក់ឲ្យច្បាស់ទេ។

[១៣:៤២:៤០]

**ស៖** សូមអរគុណ។ តាមអ្វីដែលលោកអាចពិនិត្យមើល អំពីវិធី ថាផែនការនោះ គឺផ្សព្វផ្សាយទៅដល់អ្នកដែលយកទៅអនុវត្តនោះ តើលោកអាចពន្យល់បានដូចម្ដេច?

**ឆ៖** អត់ទេ គឺថាមិនអាចដាក់ឲ្យអនុវត្តបានទេ ផែនការនេះ។ ហេតុផលនោះ គឺថាគេមិនបានដឹង គេមិនយល់ ហើយវាមានទំនាក់ទំនងទៅនឹង -- មានមែននៅក្នុងរហូតដល់ទៅដល់ខែតុលា កញ្ញា ១៩៧៦ ដែល -- ហើយក៏បាន -- មិនបានចេញវិលែកជាទូទៅ ហើយគេក៏ដកមកវិញ អំពីការអនុវត្ត ប៉ុន្តែពាក្យស្លោកថា “បីតោនមួយហិកតានោះ” គឺអនុវត្តទូទាំងរបបនោះឯង។ ខ្ញុំគិត បាទ សូមលោកសហព្រះរាជអាជ្ញាទៅមុខទៀត។ សូមទោស។

[១៣:៤៣:៥១]

**ស៖** សូមអរគុណ។ ទាក់ទងទៅនឹងគោលការណ៍បីតោនក្នុងហិកតា ដែលគេបន្តប្រើជារៀងរហូតនោះ។ តើមានផលប៉ះពាល់អ្វីទៅលើការអនុវត្តគោលនយោបាយ និងអនុវត្តទូទាំងប្រទេសដែរឬទេ?

**ឆ៖** ពិតហើយ គឺថាធ្វើឲ្យមនុស្សមានការភ័យខ្លាចក្នុងការអនុវត្ត។ គឺថាកម្មាភិបាលថ្នាក់ស្រុក ថ្នាក់តំបន់ និងតំបន់ គឺថាគេត្រូវគោរពផែនការនេះឲ្យៗដូចផែនការ។ ដល់កម្រិតមួយគឺថា -- អ៊ីចឹងគឺយើងមិនដឹងថា គេសម្រេចបានប៉ុន្មានៗ យើងមិនមានព័ត៌មាននោះទេ។ ប៉ុន្តែមានភស្តុតាងមួយចំនួន ដើម្បីសម្រេចឲ្យបានកៀកផែនការ គេបានកាត់ផលស្រូវខ្លះ សម្រាប់ជាពូជ សម្រាប់ចិញ្ចឹមប្រជាជននៅក្នុងមូលដ្ឋាន ប៉ុន្តែគឺថាផលដែលបានសម្រេចហ្នឹង គឺវាមានកម្រិតបែបនេះ។ ហើយភ្ជាប់ទៅនឹងគំនិតដែលថា គោលការណ៍ខ្លួនទីពឹងខ្លួនរបស់កម្ពុជា មិនពឹងផ្អែកលើជំនួយបរទេសនោះគឺថាត្រូវតែ -- ពេលខ្លះយើងឃើញថាមានស្រូវ អង្កររាប់រយតោនដែលនាំទៅប្រទេសចិន។ ហើយគេបានផលិតស្រូវដែលលើសពីសេចក្ដីត្រូវការយកទៅប្រទេសចិន ហើយគេអាចនឹងផ្លាស់ប្ដូរនូវទំនិញផ្សេងទៀតដែរ។ ទូទាំងប្រទេសនោះគឺយើងមានភស្តុតាងមួយចំនួន គឺថាមានការផ្គត់ផ្គង់ចំណីអាហារហ្នឹងគឺចុះទាបទៅៗ ហើយកង្វះអាហារូបត្ថម្ភធ្វើឲ្យមានមនុស្សស្លាប់ច្រើននៅទូទាំងប្រទេសនោះផងដែរ។ ហើយគុណភាពមិនគ្រប់គ្រាន់ទៅតាមបីតោនក្នុងមួយហិកតានោះគឺថា ផែនការហ្នឹងគឺវាតានតឹង គឺថាគេមិនអាចបដិសេធបាន ហើយការងារនោះខ្លាំងណាស់ដែលត្រូវឆ្លើយតបទៅនឹងផែនការនេះនោះ។

[១៣:៤៦:០៤]

**ស៖** ឥឡូវនេះចូលទៅដល់តំបន់មួយដែលលោកបានពិនិត្យមើល។ ហើយនៅក្នុងសៀវភៅដែល

មានចំណងជើងថា "បងធំទី១"។ ហើយ ERN ពាក់ព័ន្ធជាភាសាខ្មែរនោះគឺ 00821782។ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ ប្រសិនបើលោកមើលក្នុងអត្ថបទលើក្រដាសហ្វឹងទំព័រ១១៧ ERN អង់គ្លេស 00393031។ តើលោករកឃើញចំណុចនេះហើយឬនៅ? គឺជាផ្នែកបាទ។

សេចក្តីដកស្រង់៖ "ការងារភាគច្រើននៅក្នុងភូមិភាគពាយ័ព្យគឺថា ធ្វើឡើងដោយមនុស្សរាប់លាន ដែលជាប្រជាជន១៧មេសា មកពីភ្នំពេញ ហើយមកពីទីក្រុងភ្នំពេញ នៅបាត់ដំបង នៅតំបន់ជនបទនៅបាត់ដំបង។ នៅក្នុងរយៈពេលពីរឆ្នាំទៅទៀត ពួកគេបានបង្ខំឲ្យកាប់គាស់ រានដី ជីកប្រឡាយ កសាងទំនប់ទឹក និងភូមិឋាននានា។ មនុស្សរាប់ម៉ឺន រាប់ពាន់អ្នកត្រូវបានស្លាប់ ដោយសារខ្វះអាហារបរិភោគ ជំងឺការបាក់កម្លាំង ហើយនិងការសម្លាប់។ ពួកទាំងនេះស្លាប់ គឺគេបានដឹង គឺថា -- ហើយជូនដំណឹងទៅមេដឹកនាំនៅភ្នំពេញ ហើយគេចាត់ទុកថា អ្នកស្លាប់នោះគឺជាខ្មាំង ហើយជាខ្មាំងដែលនៅក្នុងជួរ។ ប្រជាជនថ្មី ដោយសារថាពួកគេមានច្រើនជាពួកខ្មាំងវណ្ណៈ។ ហើយបដិវត្តន៍ក៏អាចពន្យល់បាន គឺអ្នករស់ភាគច្រើនគឺអាចបង្ហាញពីកម្មាភិបាលចំអកឡកឡាយ និងធ្វើបាបពួកគេ ដោយគេនិយាយថា ទុកមិនចំណេញ ដកចេញមិនខាត"។ សូមចប់សេចក្តីដកស្រង់។

[១៣:៤៨:២៤]

ជាបឋមលោកសាស្ត្រាចារ្យ សូមលោកជម្រាបតុលាការ តើភស្តុតាងអ្វីដែលលោកបានពិនិត្យមើល ដើម្បីទាញយកសេចក្តីសន្និដ្ឋានថា មនុស្សរាប់ពាន់នាក់បានស្លាប់នៅក្នុងតំបន់មួយនេះបាទ?

**ឆ៖** ប្រភពសំខាន់នៃព័ត៌មានអំពីលក្ខខណ្ឌនៅភូមិពាយ័ព្យនោះគឺ ចម្លើយរបស់សាក្សីបន្ទាប់ពីសង្គ្រាមនោះមកដែលគេទៅប្រទេសថៃ គេចេញមកពីប្រទេសនោះ។ អ្នកទាំងអស់នោះសុទ្ធតែជាប្រជាជនថ្មីដែលទទួលការអប់រំទៅដល់កម្រិតមួយដែលគេយល់ថាជាអ្នកអាចនឹងផ្តល់សេចក្តីពណ៌នាពិស្តារពីអ្វីដែលកើតបាន។ ហើយខ្ញុំបានប្រមូលចម្លើយព័ត៌មានពីសៀវភៅមួយចំនួន ដែលបោះពុម្ពនៅសម័យកម្ពុជាប្រជាធិបតេយ្យ។ ភូមិភាគពាយ័ព្យនេះគឺថាមានប្រជាជនថ្មីច្រើន មិនមែនជាតំបន់មួយដែលស្ថិតនៅក្នុងប្រព័ន្ធនៃការត្រួតត្រារបស់ខ្មែរក្រហមក្នុងសង្គ្រាមស៊ីវិលទេ។

[១៣:៤៩:៤២]

គឺថាមានៗមនុស្សមួយចំនួនដែលមានសមត្ថភាព ប៉ុន្តែកម្មាភិបាលក្នុងស្រុកគឺជាអ្នកគ្រប់គ្រង។ ប៉ុន្តែវាខុសពីតំបន់ភូមិភាគនិរតី ហើយក៏ខុសពីភូមិភាគបូព៌ានៅក្នុងតំបន់ នៅជិតៗភ្នំពេញជាដើមនោះ ឧត្តរជាដើមនោះ។ នេះជាតំបន់ដែលថា កម្មាភិបាលមិនមានទំនាក់ទំនងទៅនឹងផ្នែកផ្សេងទៀត។ នេះជា

កត្តាសំខាន់។ ផ្នែកភាគច្រើននៃកម្ពុជាគឺថាមេដឹកនាំគឺថាគេត្រួតត្រានៅក្នុងតំបន់របស់គេ។ អ្វីដែលគេពិនិត្យមើលគឺថា តំបន់ខ្លះវាមានអ្នកទន់ភ្លន់ ប៉ុន្តែនៅក្នុងភូមិភាគពាយ័ព្យគឺថា កម្មាភិបាលមួយចំនួនមិននៅកន្លែងហ្នឹងទេនៅក្នុងសម័យខ្លះ នៅពេលដែលយើងពិនិត្យមើលថា បើសិនជាប្រជាជនថ្មី របបសម្រេចថាជាខ្មាំង ហើយកម្មាភិបាលគឺជាអ្នកសម្រេច ហើយចាត់តាំងជាអ្នកដឹកនាំនោះ។

នេះគឺបក្សកុម្មុយនីស្តកម្ពុជាកំណត់ថាខ្លួនជាមានអំណាចផ្តាច់មុខនៅលើការពិត ប៉ុន្តែការគិតបែបនេះខុសទេ ដែលថាគេមិនដែលគិតថាគោលនយោបាយហ្នឹងខុស គេមិនកែ។ គេគិតថា គោលនយោបាយហ្នឹងវាត្រូវ វាត្រូវតែមានហេតុផលដែលថា ធ្វើឲ្យបរាជ័យដែលមានចំណុចខ្វះខាតរបស់អ្នកអនុវត្ត។ នេះហើយគឺជា ដូចជា ស្តាលីន អ៊ីចឹងដែរគឺថា គឺបើផែនការបរាជ័យគឺថាមនុស្សនោះធ្វើមិនបាន។

[១៣:៥១:៣១]

**សៈ** នៅពេលដែលលោកពិភាក្សាចលនាជម្លៀសប្រជាជន១៧មេសា ជាងមួយលាននាក់នេះចេញពីភ្នំពេញទៅតំបន់នោះ តើលោកអាចបញ្ជាក់ឲ្យច្បាស់បានទេថា តើនេះជាលទ្ធផល -- សុំទោសខ្ញុំសួរផ្សេងពីនេះ។ តើលោកអាចបញ្ជាក់ឲ្យបានច្បាស់ដែរឬទេថា តើសេចក្តីសម្រេចណាមួយ ឬសេចក្តីសម្រេចណាដែលធ្វើឲ្យមានការជម្លៀសបែបនេះ?

**ផះ** ដោយខ្ញុំមិនមានឯកសារនោះ គឺថាខ្ញុំមានចំណុចដកស្រង់នេះគឺបង្ហាញថា គឺថា មិនត្រឹមត្រូវទេ គឺថាមនុស្សដែលជម្លៀសទៅពាយ័ព្យនោះគឺថា មិនមែនមកតែពីភ្នំពេញទេគឺថា ហើយក្រោយមកគឺថាគេបញ្ជូនទៅតំបន់ភូមិភាគពាយ័ព្យហ្នឹង គឺថាពេលខ្លះតាមរទេះភ្លើងតាមរថយន្ត តាមដំណើរថ្មើរជើង។ ប៉ុន្តែពីដំបូងហ្នឹង គឺមិនទៅភូមិភាគពាយ័ព្យទាំងអស់ទេ គឺថាប្រជាជនថ្មីនេះ។ ខ្ញុំកែតម្រូវប្រជាជនថ្មីមកពីបាត់ដំបង គឺគេនៅក្នុងទីក្រុងក៏ត្រូវបញ្ជូនទៅភូមិភាគពាយ័ព្យនោះដែរ គឺបាន -- ហើយជនភៀសខ្លួនដែលខ្ញុំបានសម្ភាសនៅកាលនោះ គឺថាគាត់បានឆ្លើយអ៊ីចេះគឺថា ប្រហែលជាគាត់ក្នុងចំនួនរាប់រយនាក់គាត់បានឆ្លើយថា គាត់ក្លាយទៅជាប្រជាជនថ្មីនៅសម័យនោះដែរ។ ភាគច្រើននៅពេលដែលគេទៅខេត្តនៅជិតភ្នំពេញ គេមានបងប្អូននៅទីនោះ។ ភ្នំពេញនៅសម័យកាលនោះគឺថាអាចមកពី -- ប្រជាជនមកពីតំបន់ណា គេត្រឡប់ទៅកន្លែងហ្នឹង។ ពេលខ្លះមកពីនិរតី ភូមិភាគបូព៌ា ឬក៏ភូមិភាគកណ្តាល គេប្រមូលនៅពេលដែលផែនការនោះគេប្រមូល ហើយគេប្រមូលហើយយកប្តូរទីតាំងឲ្យទៅភូមិភាគពាយ័ព្យហើយគេ -- យើងហៅថាជាពលករជាទាសករជាដើមនោះគឺថា ដើម្បីឲ្យធ្វើការងារទៅ

តាមផែនការបីតោនមួយហិកតានោះឯង ហើយក៏គេបញ្ជូនភាគច្រើននោះទៅភូមិភាគពាយ័ព្យ។ អ៊ីចឹង គឺថាការជម្លៀសពីភ្នំពេញនៅសៀវភៅនេះគឺមិនមែនន័យថា ចេញតែពីភ្នំពេញ *ឌីរិច* ទៅបាត់ដំបងផ្ទាល់នោះទេបាទ។

[១៣:៥៤:០២]

**ស៖** ដើម្បីកុំឲ្យមានការសង្ស័យនៅក្នុងចំណុចនេះ ទាក់ទងទៅនឹងការជម្លៀស ឬក៏ការចលនាប្រជាជននៅដើមឆ្នាំ១៩៧៦ នោះ ថាតើសេចក្ដីសម្រេចហ្នឹងចេញមកពីថ្នាក់ណា? ពីស្ថាប័នណា? តើលោកដឹងទេ?

**ឆ៖** មកពីមជ្ឈិមបក្ស គឺវាផ្សារភ្ជាប់ទៅនឹងផែនការនយោបាយទាំងមូល ដែលថាត្រូវធ្វើផែនការបីតោនមួយហិកតានោះឯង។ មិនមានអ្វីដែលនិយាយថា ជាពិសេសទេ គឺជាទូទៅគឺសេចក្ដីសម្រេចមកពីកំពូលទាំងអស់។

**ស៖** ចុងក្រោយនៅក្នុងសេចក្ដីដកស្រង់នេះ លោកបានបញ្ជាក់ថា លោកបានសម្ភាសជាមួយអ្នករស់រានមានជីវិត ហើយនិងជនភៀសខ្លួន។ តើលោកអាចរកឃើញអ្វីបន្ថែមទៀតទេ ដែលឃ្លាមួយនិយាយថា "ទុកក៏មិនចំណេញ ដកចេញមិនខាត" គេនិយាយទៅប្រជាជនថ្មី។ តើគេយកទៅ អនុវត្តដែរឬទេ? បើសិនជាអនុវត្តក្នុងភាពជាក់ស្ដែងនោះ វាចេញជាផលវិបាកដូចម្ដេច?

**ឆ៖** សូមអរគុណ។ គឺថា ឃ្លានេះធ្វើឲ្យប្រជាជនមានការភ័យខ្លាច ឲ្យគេប្រឹងធ្វើការ គេតែងតែនិយាយជាញឹកញាប់ គឺថាតាំងពីដំបូងដើម គឺថានៅពេលដែលគេ គេនិយាយជាញឹកញាប់ចាប់តាំងចាប់ផ្ដើមរបបខ្មែរក្រហមហ្នឹង គឺក្រោយពីរបបហ្នឹងដួលរលំ។ គឺថាជាពាក្យស្លោក អ្វីដែលគេចង់ប្រាប់ប្រជាជន គឺថាត្រូវប្រាប់ប្រជាជនថ្មីបែបនេះ។ គឺថាទូទៅប្រទេសគេប្រើពាក្យស្លោកបែបនេះ។ ចង់និយាយថា អ្នកឯងគ្មានតម្លៃទេ ប៉ុន្តែបើអ្នកឯងចង់នៅរស់ ធ្វើការឲ្យខ្លាំងទៅ។ ហើយយើងនឹងសម្រេចថា តើអ្នកឯងត្រូវរស់ ឬត្រូវស្លាប់ មួយថ្ងៃទៅមួយថ្ងៃ។ នេះហើយជាពាក្យស្លោកទូទាំងប្រទេសដែលគេប្រើ ដែលគេប្រើសម្រាប់កំណត់ប្រជាជនថ្មីហ្នឹង។

[១៣:៥៦:២០]

**ស៖** សូមអរគុណ។ ខ្ញុំនឹងចូលទៅដល់បញ្ហាដែលនិយាយអំពីការស្លាប់ ឬក៏ចំនួនបរិមាណការប៉ាន់ស្មានចំនួនមនុស្សស្លាប់ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។ ជាក់ស្ដែងនោះ លោកបានសិក្សាជាច្រើនឆ្នាំហើយ គឺមានលេខយោងជាច្រើន ឯកសារយោងជាច្រើន ហើយខ្ញុំនឹងជូនជាលេខទំព័រ ឬក៏

លេខឯកសារ។ នៅក្នុងសៀវភៅនិយាយអំពីសោកនាដកម្មនៅកម្ពុជា នៅអង់គ្លេស ERN 00422860 អាចជាទំព័រ២៣៣។ នៅនេះ គឺថាយើងមានខ្មែរ ERN ប៉ុន្តែខ្ញុំរកមិនទាន់ឃើញ។ សូមអភ័ទោស។ នេះមានតែជាភាសាអង់គ្លេសទេបាទ។ ហើយខ្ញុំនឹងពិនិត្យមើលថាតើ ERN ដែលខ្ញុំឲ្យនោះត្រឹមត្រូវ។ មើលសៀវភៅសោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា គឺថាERN ដែលត្រឹមត្រូវនោះ គឺ 00193084 ជាភាសាអង់គ្លេស។ ហើយជាភាសាខ្មែរ ហើយយើងមិនមានភាសាខ្មែរទេ តាមដែលខ្ញុំគិត លើកលែងតែលេខ 00820993។ លោកបាននិយាយដូចខាងក្រោមនេះ៖

"ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ប្រជាជនខ្មែរ១លាន ឬក៏មួយក្នុងប្រាំបី ដែលស្លាប់ដោយសង្គ្រាមអត់អាហារ ធ្វើការបាក់កម្លាំង ឬក៏ជំងឺដែលមិនបានព្យាបាល ហើយនិងការកាប់សម្លាប់"។ នេះគឺជាខ្លឹមសារនៅក្នុងសៀវភៅ "សោកនាដកម្មប្រវត្តិសាស្ត្រកម្ពុជា"។

[១៣:៥៨:៣២]

នៅពេលដែលលោកសិក្សា ដើម្បីសរសេរសៀវភៅនេះ គឺឯកសារ D366/7.1.69។ លោកបានផ្តល់ការប៉ាន់ប្រមាណដូចខាងក្រោមនេះ៖ "ទោះបីជាមានពាក្យស្លោកប្រឆាំងនឹងវៀតណាមមិនត្រឹមត្រូវដែលបង្ករឲ្យមានការស្លាប់ ដោយសារការអត់អាហារ លើសការងារ លើសកម្លាំង ហើយនិងជំងឺ ហើយនិងការបោសសម្អាត គឺជិតដល់២លាននាក់ ឬក៏មួយនាក់ក្នុងចំណោមប្រាំនាក់បានស្លាប់"។ នេះគឺជាសៀវភៅដែលបោះពុម្ពឡើងវិញនៅឆ្នាំ២000។ អ៊ីចឹងគឺថា ការប៉ាន់ប្រមាណនេះ តើលោកអាចបង្ហាញមូលដ្ឋានថា តើលោកឈានដល់សេចក្តីសន្និដ្ឋានប៉ាន់ប្រមាណនេះ បើសិនជាផ្អែកតាមការសិក្សាមុននឹងសរសេរសៀវភៅនេះ?

**ឆ៖** ខ្ញុំនឹងគិតថា ការប៉ាន់ស្មានចុងក្រោយ គឺជាការប៉ាន់ស្មានចុងក្រោយ គឺថា ពិនិត្យមើលការងារប្រជាសាស្ត្រជាច្រើន មិនដោយខ្ញុំទេ ខ្ញុំចូលរួមដោយអ្នកផ្សេងទៀតក្នុងការប៉ាន់ប្រមាណចំនួនប្រជាសាស្ត្រ របាយការណ៍ប្រជាសាស្ត្រនេះ។ បាទ សូមលោកកុំទាន់មើលសៀវភៅនេះ សូម -- ចំណុចនោះគឺថាមានការធ្វើជំរឿននៅឆ្នាំ២000 អំពីចំនួនមនុស្សស្លាប់នៅក្នុងគោលការណ៍ប្រជាសាស្ត្រនៅក្នុងសៀវភៅដែលខ្ញុំបានដាក់សេចក្តីប៉ាន់ប្រមាណនេះ ហើយខ្ញុំៗមិនបន្ថយ ឬក៏បន្ថែមចំនួនទេ។

នៅក្នុងការសន្ទនាដែលខ្ញុំទុកចិត្តហ្នឹង ខ្ញុំ -- គាត់មិនចង់ឲ្យដកស្រង់ ភស្តុតាងនេះ គឺថាអាចខ្ពស់ជាងដែលសន្និដ្ឋាននេះ គឺថា គឺជិត២លាន ប៉ុន្តែខ្ញុំប្រកាន់យកគឺថា ១.៥លាន ឬក៏មួយ ១.៧លាន ប៉ុន្តែនៅក្នុងខណៈពេលនេះ ខ្ញុំរីករាយនឹងកែតម្រូវប្រសិនបើមានភស្តុតាងណាបញ្ជាក់ខុសពីនេះ។

[១៤:០០:៥៥]

**ស៖** សូមអរគុណ។ ដើម្បីជាអត្ថប្រយោជន៍ដល់ភាគីទាំងអស់នោះ ខ្ញុំនឹងបង្ហាញរបាយការណ៍របស់អ្នកប្រជាសាស្ត្រនៅពេលដែលវិវត្តន៍ទៅមុខ គឺថាខ្ញុំក្នុងគោលបំណងនេះ ខ្ញុំនឹងបង្ហាញដើម្បីនៅពេលក្រោយនោះបាទ។ ឥឡូវនេះ ខ្ញុំសូមអនុញ្ញាតចូលទៅដល់--

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ហើយខ្ញុំចង់ឲ្យបញ្ជាក់ឲ្យច្បាស់ថា តើយើងយល់ច្បាស់ទេ ខ្ញុំថាតើឯកសារណាមួយដែលលោក ដេវីដ ឆេនដ័ល័រ ចង់ពិភាក្សាថាតើគាត់បានមើលខ្លឹមសារដែរឬអត់ទេ? ហើយបើសិនជាគាត់បានមើលខ្លឹមសារ ហើយឥឡូវនេះគាត់ថាមិនអានទេ។ ឥឡូវយើងមិនចង់ដឹង -- មិនយល់ច្បាស់ទេ អ៊ីចឹងសហព្រះរាជអាជ្ញាគប្បីតែបំភ្លឺ តើឯកសារហ្នឹងយ៉ាងដូចម្តេច ដើម្បីផ្ទៀងផ្ទាត់ថាតើការចេះដឹងរបស់គាត់ ចំណេះដឹងរបស់គាត់ពីរឿងនេះ ផ្អែកលើឯកសារនេះ ឬក៏លើការសិក្សារបស់គាត់។

[១៤:០២:១៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

ខ្ញុំនឹងសូមឆ្លើយតបឯកសារដែលនៅក្នុងបាច់ឯកសារនេះ ដែលយើងចាត់ទុកថា យកត្រូវមកបង្ហាញលោក ឆេនដ័ល័រ ហ្នឹងគឺរបាយការណ៍អ្នកជំនាញខាងប្រជាសាស្ត្រនៅក្នុងសំណុំរឿងផងដែរ ដើម្បីកំណត់ត្រាគឺឯកសារនោះ គឺមានលេខថា D140/1។ ហើយប្រហែល -- ដើម្បីចៀសវាងនូវការសង្ស័យនោះ យើងសួរទៅសាស្ត្រាចារ្យ។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ថាតើ បាទឥឡូវខ្ញុំមួយជំហានម្តង។ សួរថាតើលោកបានមើលទូរលេខនៅក្នុងរបាយការណ៍ហ្នឹងទេលោកសាស្ត្រាចារ្យបាទ?

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំបានទទួលឯកសារ ប៉ុន្តែខ្ញុំមិនទាន់បានអានទេ។ ខ្ញុំមិនៗបានមើលជាលម្អិតទេ ខ្ញុំបានមើលមួយក្រឡេក មិនបានមើលជាលម្អិតទេ ហើយទៅមើលចុងក្រោយ ទៅមើលសេចក្តីសន្និដ្ឋាន។

សេចក្តីសន្និដ្ឋាននៅក្នុងលេខយោង ឯកសារជាជំរឿន ដែលធ្វើទៅលើប្រភពផ្សេងៗដែលគេយោងទៅរកប្រភពផ្សេងៗ។ នេះហើយជាចំណុចដែលខ្ញុំឯកភាពជាមួយ ដែលខ្ញុំយល់ស្របជាមួយ។ ខ្ញុំមិនបានពិនិត្យឯកសារហ្នឹងជាផ្លូវការទេ ខ្ញុំ -- ក្នុងសេចក្តីសន្និដ្ឋានគឺថា ខ្ញុំនៅតែប្រកាន់សេចក្តីសន្និដ្ឋានរបស់ខ្ញុំ។ ប៉ុន្តែខ្ញុំបានមើលជំរឿននូវសេចក្តីសន្និដ្ឋាននៅឯកសារនេះ នៅរបាយការណ៍នេះ គឺថាគឺ ១.៥ទៅ ១.៧ លាននាក់ ដែលចំនួនមនុស្សស្លាប់នោះបាទ។

[១៤:០៤:០០]

**ស៖** នេះហើយជាចំណុចដែលយើងចង់បានសេចក្តីសន្និដ្ឋានរបស់លោកនោះបាទ។ បើអ៊ីចឹងលោកសាស្ត្រាចារ្យមិនមានកំហុសអ្វីទេ គឺលោកផ្អែកទៅលើការសន្និដ្ឋានរបស់លោកទេ។ លោកបានមើលតែខាងក្រោយតែប៉ុណ្ណោះ។ ឥឡូវនេះ យើងមានសេចក្តីសន្និដ្ឋានរបស់លោកដែលលោកបានឆ្លើយជម្រាបតុលាការហើយ។ ដូចដែលខ្ញុំបញ្ជាក់ ខ្ញុំនឹងចូលទៅដល់ប្រធានបទមួយទៀត។ វាពាក់ព័ន្ធមួយផ្អែកទៅនឹងសំណួរដែលលោកត្រូវបានចោទសួរដោយចៅក្រម ខាតវ៉ាយថ៍ កាលពីម្សិលមិញ។ ចំណុចទាំងអស់នោះ គឺនិយាយអំពីការចាត់តាំង តែងតាំងអង្គការមួយចំនួននៅក្នុងបក្ស នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

[១៤:០៥:០៣]

អ្វីដែលខ្ញុំចង់ចាប់ផ្តើមលើប្រធានបទនេះនោះគឺ ការដកស្រង់សម្តីមួយចេញពីសៀវភៅលោក យើងចូលទៅសៀវភៅ "បងធំទី១" វិញ យើងមានជាភាសាខ្មែរ ដែលអាចបញ្ចាំងលើអេក្រង់បាន គឺ E3/17 ខ្មែរ ERN គឺ 00821773 ទៅដល់ 4, ERN ជាភាសាអង់គ្លេសគឺ 00393021 រហូតទៅដល់ 022 វាគឺជាការដែលលោកពិចារណាទៅលើទំនាក់ទំនងរវាងបក្ស និងអង្គការផ្សេងទៀតនៅក្នុងបក្សដែលខ្ញុំចង់ដឹង។ នេះ ចំណុចនេះគឺអ្វីដែលលោកបាននិយាយនៅក្នុងនោះ។ បាទ សូមបើក -- សូមដាក់លើអេក្រង់ ដើម្បីឲ្យយើងបានមើលទាំងអស់គ្នា "បក្សគឺមានអង្គការបដិវត្តន៍បិទបាំង ឈ្មោះនេះគឺប្រជាជនកម្ពុជាគេសន្មតដូច្នេះ ហើយវានៅតែលាក់កំបាំងនៅក្នុងរណសិរ្ស ដែលមានព្រះបាទនរោត្តម សីហនុជាប្រមុខរដ្ឋ។ មានឈ្មោះបដិវត្តន៍និងកិច្ចការសម្ងាត់ ហើយបានការពារ សាឡុត ស ពីការគិតគូរពិចារណាវិនិច្ឆ័យរបស់ប្រជាជន។ អ្នកកម្មាភិបាលដែលមានទទួលខុសត្រូវ គឺមានឈ្មោះបដិវត្តន៍បិទបាំង។ យើងឃើញមានការបិទបាំងទៅលើអ្នកទាំងអស់នោះ ដែលជួរថ្នាក់ដឹកនាំ គឺមានការគ្រប់គ្រងទៅលើបដិវត្តន៍"។

[១៥:០៧:០១]

ចំណុចទីមួយ ប្រសិនបើខ្ញុំអាចសួរលោកសាស្ត្រាចារ្យ ផេនដ៍ល័រ នោះគឺ តើលោកពិចារណាយ៉ាងម៉េចទៅលើកំណត់ហេតុគណៈអចិន្ត្រៃយ៍ ដែលក្នុងនោះនិយាយអំពីរបបនោះ? នៅទីនេះខ្ញុំនិយាយអំពីឆ្នាំ១៩៧៥ គឺពាក់ព័ន្ធនឹងអ្វីដែលលោកបានឆ្លើយកាលពីម្សិលមិញផងដែរ។

**ផ៖** បាទ លោកអាចសន្មតអ៊ីចឹងបាន។

**ស៖** សំណួរមួយនេះប្រហែលជាមិនសំខាន់នោះទេ ក៏ប៉ុន្តែនៅពេលដែលយើងមើលអត្ថបទនេះមានព័ត៌មានសំខាន់ផ្សេងទៀត។ លោកមើលទៅលើកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ខែតុលា ឆ្នាំ៧៥ ហើយនៅពេលដែលលោកមើលកំណត់ហេតុនោះ លោកបានកត់សម្គាល់ឃើញការតែងតាំងបុគ្គលមួយចំនួន ហើយខ្ញុំគិតថា ចំណុចនេះប្រហែលជាបានពិភាក្សារួចមកហើយ។ ក៏ប៉ុន្តែខ្ញុំចង់លើកឡើងចំណុចដែលមិនទាន់បានដេញដោល។ លោកបាននិយាយអំពីអនុលេខាបក្ស នួន ជា ដែលទទួលខុសត្រូវលើការចាត់តាំងការងាររបស់បក្ស និងការអប់រំ ហើយ អៀង សារី គឺធ្វើការងារខាងការបរទេស និងការងារបក្ស។ ខៀវ សំផន នៅតែជាមន្ត្រីទំនាក់ទំនងជាមួយនឹងរណសិរ្ស គឺទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ ហើយ ខៀវ សំផន ទទួលបន្ទុកទៅលើការវាយតម្លៃបញ្ហាសេដ្ឋកិច្ច។

[១៥:០៨:៤៧]

គឺបន្ថែមទៅលើតួនាទីរបស់គាត់នៅក្នុងទសវត្សរ៍ឆ្នាំ៦០។ តាមការស្រាវជ្រាវរបស់លោក ហើយប្រហែលជាលោកបានឆ្លើយមួយផ្នែករួចមកហើយ ក៏ប៉ុន្តែមិនបានឆ្លើយទាំងស្រុង តើតួនាទីទាំងអស់នេះកាន់កាប់ដោយបុគ្គលជាជនជាប់ចោទនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ផ៖** គឺពិតជាកាន់កាប់មែន។ ពាក្យទាំងអស់នោះនៅក្នុងអត្ថបទនោះ គឺវានៅពេលដែលយើងនិយាយថា មានការសង្ស័យទៅលើចំណុចទាំងអស់នោះ វាជាការមួយចម្លែក។ យើងឃើញថា បុគ្គលមួយចំនួនគាត់មានតួនាទីរបស់គាត់នៅក្នុងនោះ។ នៅដែលពេលយើងពិចារណាទៅមើលអត្ថបទនេះយើងឃើញមានចំណុចល្អជាច្រើន។ ហើយចំណុចដែលនៅនិយាយថាភាពសង្ស័យនោះ គឺយើងអាចពិចារណា។ យើងដឹងហើយថា អៀង សារី គាត់ទទួលបន្ទុកកិច្ចការបរទេស។ នួន ជា មានបទពិសោធន៍ច្រើននៅក្នុងការអប់រំកម្មាភិបាលនៅតាមភូមិភាគតំបន់ផ្សេងៗ។ ខៀវ សំផន គាត់មានតួនាទីខាងផ្នែកពាណិជ្ជកម្ម ហើយបំពេញការងារនេះយ៉ាងល្អ។ គាត់ដឹងទៅលើការងារនេះយ៉ាងច្បាស់ ធ្វើទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ នៅក្នុងទសវត្សរ៍ទី៦០។ ដូច្នេះហើយមិនមែនថាគេចេះតែជ្រើសរើសបុគ្គល

ទាំងអស់នេះដោយចោះៗនោះទេ។ នេះគឺតួនាទីដែលអ្នកទាំងអស់នោះមាននៅពេលនោះ។

អៀង ធីរិទ្ធ ទទួលការងារឃោសនាការបណ្តុះបណ្តាល...។ល។ ដូច្នេះហើយបុគ្គលមួយចំនួនត្រូវបានគេចាត់តាំង សុន សេន គឺជាអ្នកទទួលខុសត្រូវខាងយុទ្ធជន ហើយនៅក្នុងសង្គ្រាម ពេលសង្គ្រាមនោះ គឺ សុន សេន បង្ហាញសមត្ថភាពរបស់គាត់នៅក្នុងជួរយុទ្ធជន។ ដូច្នេះហើយគឺតួនាទីទាំងអស់នោះ គឺវាមានភាពយុត្តិធម៌ចំពោះពួកគាត់ ហើយអ្នកទាំងអស់នោះគឺជាអ្នកដែលគេទុកចិត្តក្នុងការចាត់តាំងពួកគេ។ ដូច្នេះហើយ គឺសម្ភារៈឯកសារទាំងអស់នេះ គឺបានបង្ហាញទៅលើចំណុចទាំងអស់នេះ។

[១៤:១០:៥៨]

**ស៖** បន្តទៅលើឯកសារខែតុលា ឆ្នាំ៧៥ ដែលជាកំណត់ហេតុ ឬសេចក្តីសម្រេចនោះ គឺខ្ញុំសូមចូលសួរអំពីការអនុម័តិរដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។ ពាក់ព័ន្ធទៅនឹងការស្រាវជ្រាវរបស់លោកលោកសាស្ត្រាចារ្យ ហើយដោយពិចារណាទៅលើការពិភាក្សាមុនៗអំពីអត្ថិភាពនៃរណសិរ្ស ថាតើរណសិរ្ស និងស្ថាប័នមួយចំនួនត្រូវបានដំណើរការដែរឬទេក្រោយឆ្នាំ៧៥ ហើយបានបំពេញការងារនីតិប្រតិបត្តិរបស់ខ្លួនដែរឬទេទៅតាមអ្វីដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ?

**ឆ៖** គឺសឹងតែគ្មាន។ វានៅតែបន្តដដែល ការងារទាំងអស់នោះ សម្តេច សីហនុ គាត់បានវិលត្រឡប់មកប្រទេសកម្ពុជា ហើយគាត់ជាប្រមុខរដ្ឋ ហើយបានធ្វើទស្សនកិច្ចនៅក្នុងក្រុង ហើយគាត់បានបំពេញការងារនេះ។ ខៀវ សំផន ធ្វើទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ ហើយដើរតួនាទីដែលគាត់កាន់កាប់នោះធ្វើទំនាក់ទំនងជាមួយនឹងសម្តេច សីហនុ។ គឺវាជាការតួនាទីដែលគេដំណើរការនៅទីនោះ។ យើងដឹងហើយថា នៅពេលនោះមានដំណើរការដូច្នេះកើតឡើង ក៏ប៉ុន្តែសម្តេច សីហនុ គាត់មិនមានតួនាទីជាក់លាក់ និងធ្វើសកម្មភាពជាក់លាក់របស់ទ្រង់នោះឡើយ។ នៅចន្លោះថ្ងៃទី១៧ មេសា ឆ្នាំ៧៥ នោះគឺយើងឃើញថាមានការងារច្រើនដែលបក្សគាត់បានដំណើរការ និងគ្រប់គ្រង ហើយបក្សនោះគឺធ្វើការងារទៅលើការងាររបស់ខ្លួន។ ហើយគឺគេមិនមានការពិភាក្សាជាចំហទៅលើសកម្មភាពទាំងអស់នោះឡើយ។

[១៤:១២:៥៦]

**ស៖** សូមអរគុណ។ នៅពេលដែលយើងពិចារណាទៅលើដំណើរការនៃការអនុម័តិរដ្ឋធម្មនុញ្ញ យើងឃើញមានឯកសារបោះពុម្ពផ្សាយជាច្រើន នៅក្នុងឯកសាររបស់កម្ពុជាប្រជាធិបតេយ្យ។ ដូច្នេះ ខ្ញុំ

ចង់យកឯកសារទាំងអស់នោះមកពិចារណាមួយចំនួន។ ឯកសារ E3/273 គឺរបាយការណ៍ផ្សព្វផ្សាយពីបរទេស ហ្វីប៊ីស ដែលចេញផ្សាយអំពីរបាយការណ៍ពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន ស្ដីអំពីសេចក្ដីព្រាងរដ្ឋធម្មនុញ្ញ គឺចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ៧៥។ ថ្ងៃ១៤ ខែធ្នូ ឆ្នាំ៧៥។ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ តើលោកធ្លាប់ជួបប្រទះព័ត៌មានផ្សព្វផ្សាយពីកាសែត ឬក៏ការផ្សព្វផ្សាយខាងឯកសារបរទេសដែរឬទេ?

**ឆ៖** ឃើញមាន។ យើងឃើញមានការដឹងជាទូទៅនៅក្នុងផ្ទៃក្នុងប្រទេស គឺក្នុង៧៥ ទៅដល់៧៨ ក៏ប៉ុន្តែក៏យ៉ាងណាក៏ដោយ ខ្ញុំឃើញថាមានឯកសារផ្សព្វផ្សាយដោយស្ថាប័នបរទេស។

**ស៖** សូមអរគុណ។

[១៤:១៤:២៤]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោក លោកស្រីចៅក្រម យើងខ្ញុំសូមបង្ហាញនៅលើអេក្រង់ គឺ ERN ជាភាសាអង់គ្លេស គឺ 00657439 ដល់ 40, បារាំងគឺ 00257996 ដល់ 97, អង់គ្លេស ERN គឺ 00167811។ អ្វីដែលយើងចង់ធ្វើនេះ គឺបង្ហាញឯកសារជាភាសាខ្មែរលើអេក្រង់ ហើយបន្ទាប់មក ខ្ញុំនឹងផ្ដល់ជូនឯកសារជាក្រដាសទៅលោកសាស្ត្រាចារ្យ។ សូមអនុញ្ញាតពីលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** លោកសាស្ត្រាចារ្យសូមឲ្យលោកមើលឯកសារក្រដាសដែលយើងខ្ញុំបានចង្អុលលេខ ERN 96 ដល់ 97 នេះ សូមឲ្យលោកមើលទៅលើឯកសារនេះ។ ខ្ញុំចាប់អារម្មណ៍ទៅលើចំណុចនៅក្នុងឯកសារចន្លោះ 96, 97។ ឯកសារនេះ គឺបានចេញរបាយការណ៍នៅក្នុងសន្និបាត -- ក្នុងពេលសន្និបាត ដែលបានធ្វើឡើងនៅចុងខែមេសា ឆ្នាំ៧៥។ នេះបើតាមឯកសារនេះ។

ព្រឹត្តិការណ៍ដែលកើតឡើងក្រោយសន្និបាតនោះគឺមានដូចតទៅ៖ សេចក្ដីសម្រេចរបស់សន្និបាតគឺជាមូលដ្ឋានសម្រាប់រដ្ឋធម្មនុញ្ញរបស់យើង។ សន្និបាតពិសេស គឺបានបង្កើតគណៈកម្មាធិការរដ្ឋធម្មនុញ្ញដែលត្រូវរៀបចំសេចក្ដីព្រាងរដ្ឋធម្មនុញ្ញ។ រដ្ឋធម្មនុញ្ញ គឺគណៈកម្មាធិការរដ្ឋធម្មនុញ្ញ គឺបង្កើតឡើងដោយមហាសន្និបាត ដែលត្រូវប្រជុំក្នុងពេលចាំបាច់ ដើម្បីពិចារណាទៅលើសេចក្ដីព្រាង ហើយចុងក្រោយត្រូវសម្រេចចុងក្រោយទៅលើរដ្ឋធម្មនុញ្ញ ហើយបន្ទាប់មកដាក់ជូនឲ្យមានការពិចារណាម៉ត់ចត់ដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ ក្រុមប្រឹក្សារដ្ឋមន្ត្រី ត្រូវតែស្នើឡើងសម្រាប់ការធ្វើវិសោធនកម្ម... ។ល។

[១៤:១៦:៥៤]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបាទ!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ សូមអនុញ្ញាតឲ្យសហព្រះរាជអាជ្ញាសួរសាក្សីជំនាញ ថាតើលោកបានស្គាល់ឯកសារនេះពីមុនមកទេ? ពីព្រោះកាលណារៀបរាប់ខ្លឹមសារច្រើនពេកទៅ ហើយមិនបានបញ្ជាក់អំពីថាតើគាត់បានស្គាល់ប្រឹក្សាពីឯកសារនេះអត់ផង? វាធ្វើឲ្យមានការច្របូកច្របល់ បាទ។ សូមអរគុណ។

**លោក អាប់ឌុលឡាក់ ថាវីក៖**

ប្រហែលជាអត់មានការបកប្រែតាមរយៈឧបករណ៍ ឬក៏យ៉ាងម៉េច? ក៏ប៉ុន្តែលោកសាស្ត្រាចារ្យបានបញ្ជាក់ហើយថា គាត់បានធ្លាប់ឃើញឯកសារនេះ។ បើសិនអនុញ្ញាតឲ្យខ្ញុំបន្តទៅមុខទៀតនោះ។ លោកប្រធាន សូមអរគុណ។

**សួរដោយលោក អាប់ឌុលឡាក់ ថាវីក៖**

**ស៖** ក្រុមប្រឹក្សារដ្ឋមន្ត្រី បន្ទាប់មក ដាក់ជូនគណៈកម្មាធិការមកវិញ នូវយោបល់ទាំងឡាយលើបញ្ហាកែប្រែរដ្ឋធម្មនុញ្ញ ដើម្បីឲ្យសេចក្តីព្រាងនោះពេញលេញ។ សម្តេចដែលជាប្រមុខរដ្ឋ ក៏បានឯកភាពទៅលើការបង្កើតរដ្ឋធម្មនុញ្ញថ្មីនេះផងដែរ។ បច្ចុប្បន្ន សម្តេចគឺគាត់ធ្វើទស្សនកិច្ចនៅបរទេស ហើយមិនអាចចូលរួមវត្តមាននៅក្នុងមហាសន្និបាតទីបីរបស់យើងនោះទេ។ សម្តេចនាយករដ្ឋមន្ត្រីនៅទីនេះ ក៏បានឯកភាពទៅលើការរៀបចំរដ្ឋធម្មនុញ្ញនេះផងដែរ។

[១៤:១៨:២០]

របាយការណ៍នេះ ដូចដែលលោកសាស្ត្រាចារ្យបានឃើញ គឺរៀបរាប់អំពីដំណើរការដែលគេរៀបចំសេចក្តីព្រាងរដ្ឋធម្មនុញ្ញ ក្រោយមកមានក្រុមប្រឹក្សារដ្ឋមន្ត្រីធ្វើយោបល់ ហើយចុងក្រោយបានដាក់ជូនអនុម័ត។ ផ្អែកតាមការស្រាវជ្រាវរបស់លោក ស្តីអំពីដំណើរការព្រឹត្តិការណ៍នៅពេលនោះ ថាតើវាឆ្លុះបញ្ចាំងយ៉ាងត្រឹមត្រូវអំពីនីតិវិធីដែលគេបានបង្កើតរដ្ឋធម្មនុញ្ញនោះ នាពេលនោះដែរឬទេ?

**លោក ឆេវីដ ឆេនដ័ល័រ៖**

**ឆ៖** ខ្ញុំមិនប្រាកដថា នីតិវិធីនោះត្រឹមត្រូវ ឬក៏យ៉ាងនោះទេ។ ខ្ញុំត្រូវតែពិនិត្យមើលឯកសារ។ ខ្ញុំមិនដឹងថាតើនៅពេលនោះ មានការផ្សព្វផ្សាយអំពីសន្និបាតដែលគេប្រជុំនៅទីក្រុងភ្នំពេញ។ ក្រុមប្រឹក្សា

រដ្ឋមន្ត្រី ពាក្យដែលគេប្រើនោះ ខ្ញុំមិនដឹងថាតើគេបានបង្កើតក្រុមប្រឹក្សារដ្ឋមន្ត្រី ឬក៏យ៉ាងម៉េចនោះដែរ។ សម្តេចនាយករដ្ឋមន្ត្រី សីហនុ និង ប៉ែន នុត នោះ គឺវាជាការយល់តែប៉ុណ្ណោះ។ គឺការយល់នៅពេលនោះ ថាមានអ៊ីចឹងមែន។ ក៏ប៉ុន្តែឯកសារជាច្រើនមិនបាននិយាយអំពីនីតិវិធីដែលបានអនុវត្តដូច្នោះនោះទេ។ យើងដឹងហើយថា មានការផ្សព្វផ្សាយដែលគេបានតាមដាន និងគ្រប់គ្រងយ៉ាងម៉ត់ចត់។ ដូច្នេះហើយចំណុចនេះ វាហាក់ដូចជាដំណាក់កាលនៃនីតិវិធីដែលបានគេបានអនុវត្ត។ អ្វីដែលយើងស្តាប់ពីកាលម្សិលមិញនិងនៅក្នុងថ្ងៃនេះ គឺយើងឃើញនីតិវិធីដែលគេអនុវត្ត ក៏ប៉ុន្តែយើងមិនដឹងថា វាឆ្លុះបញ្ចាំងជាក់ស្តែងយ៉ាងណានោះទេ។ ទោះបីជាយ៉ាងក៏ដោយ ខ្ញុំនៅតែមិនច្បាស់លាស់ទៅលើចំណុចនេះដដែល។

[១៤:២០:០០]

**ស៖** សូមអរគុណ។ ក្រោយពីអនុម័តរដ្ឋធម្មនុញ្ញ ឯកសារដែលខ្ញុំនឹងបង្ហាញជូនលោកនោះគឺរបាយការណ៍ដែលផ្សាយអំពីការបោះឆ្នោតធ្វើឡើងនៅថ្ងៃទី២០ ខែមីនា។ ឯកសារបន្ទាប់មួយទៀតគឺនិយាយអំពីបញ្ហានេះផងដែរនោះគឺ E3/274 ដូចដែលខ្ញុំបានបញ្ជាក់គឺជារបាយការណ៍ស្តីអំពីការបោះឆ្នោត ឬក៏ការតែងតាំង ហើយវាជាការដកស្រង់ឯកសារមួយទៀតចេញពីឯកសារទាំងមូល។ ខ្ញុំអាចបញ្ជូនឯកសារនេះជាក្រដាសជូនទៅលោកសាស្ត្រាចារ្យបាន។

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអនុញ្ញាតពីលោកប្រធាន ប្រសិនបើសមស្រប។ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** ERN ពាក់ព័ន្ធនោះគឺខ្មែរលេខ 00700118 បារាំងគឺ ដែលវាមិនបកប្រែទាំងស្រុងនោះទេគឺ 00700112, អង់គ្លេសគឺ ERN 00167986។ ខ្ញុំមិនស្នើសុំចូលលម្អិតទៅលើឯកសារនេះទេ ក៏ប៉ុន្តែនៅក្នុង ERN ដែលខ្ញុំទើបតែអានអម្បាញ់មិញនេះគឺចែងសរសេរថា “ថ្ងៃទី២០ ខែមីនា ការបោះឆ្នោតនោះធ្វើឡើងដោយជោគជ័យ ដោយនៅពេលនោះប្រជាជនមានការសប្បាយទៅនឹងការបោះឆ្នោត”។ ហើយលទ្ធផលបោះឆ្នោតនៅទូទាំងប្រទេសមានដូចតទៅ៖ បន្ទាប់មក យើងឃើញមានទូរលេខនៅក្នុងនោះ។ នៅក្នុងនោះគេបានលើកឡើងថា៖ “អ្នកបោះឆ្នោត ៩៨ភាគរយដែលត្រឹមត្រូវនោះបានចូលរួមក្នុងការបោះឆ្នោត។ ដូច្នេះ បើយើងមើលទៅលើការស្រាវជ្រាវរបស់លោកនៅក្នុងពេលនោះ ដែលលោកបានសម្ភាសជាមួយនឹងអ្នករស់រានមានជីវិត ហើយនិងប្រភពឯកសារផ្សេងទៀតដែលលោកបានយកមកធ្វើជាមូលដ្ឋាននោះ តើលោកបានដឹងអំពីករណីដែលថានៅពេលនោះមានការបោះឆ្នោត ហើយមាន

ប្រជាជនដែលបានបោះឆ្នោតត្រឹមត្រូវនោះ ៩៨ភាគរយ។ តើលោកបានដឹងទៅលើចំណុចនេះដែរឬទេ?

[១៤:២២:៤៦]

**លោក ដេវីដ ឆេនដ័ល័រ៖**

**ឆ៖** ៩០ភាគរយនោះគឺយើងឃើញមានការបោះឆ្នោត ក៏ប៉ុន្តែប្រជាជនថ្មីមិនត្រូវបានអនុញ្ញាតឲ្យគេបោះ -- ឲ្យបោះឆ្នោតនោះទេ។ មានតែអ្នកមូលដ្ឋាន និងយោធាប៉ុណ្ណោះដែលធ្វើការបោះឆ្នោត។ ហើយយើងមិនដឹងថា តើមានការបោះឆ្នោត ឬយ៉ាងណានោះទេ? ៩៨ភាគរយនៃចំនួនអ្នកបោះឆ្នោតនោះ គឺវាជាចំនួនមួយដែលវាអស្ចារ្យណាស់នៅក្នុងប្រវត្តិសាស្ត្រកម្ពុជា។ ៩៨ភាគរយនៃចំនួនអ្នកបោះឆ្នោតនោះគឺវាមិនត្រឹមត្រូវនោះទេ។ ហើយគឺមិនដឹងថាវាឆ្លុះបញ្ចាំងអំពីអ្នកណាដែលជាអ្នកបោះឆ្នោតនោះទេ។

[១៤:២៣:២៦]

យើងឃើញមិនដឹងថាអ្នកណាគេជាអ្នកចាញ់នៅក្នុងការបោះឆ្នោត បុគ្គលមួយចំនួនគាត់ចាំថាគាត់បានទៅបោះឆ្នោត។ ក៏ប៉ុន្តែបើសិនជាមិនមានទេគេប្រាកដជាមិននិយាយថា មានចំនួនអ្នកបោះឆ្នោតនោះទេ ក៏ប៉ុន្តែការបោះឆ្នោតប្រហែលធ្វើនៅតាមកន្លែងជាក់លាក់ប៉ុណ្ណោះ។ ហើយវាមិនបានឆ្លុះបញ្ចាំងអំពីដំណើរការនៃការបោះឆ្នោតនោះទេ។ ខ្ញុំគិត និងបញ្ជាក់សាជាថ្មីថា ចំនួននេះគឺវាចំនួនច្រើនណាស់ ហើយមិនដឹងថាតើវាជាការផ្ទេរអំណាចយ៉ាងត្រឹមត្រូវពីរណសិរ្សទៅដល់របបថ្មី ឬក៏យ៉ាងណានោះទេ។ ក៏ប៉ុន្តែការបោះឆ្នោតនេះ គឺយើងមិនអាចជឿជាក់ទាំងស្រុងទេ ចំពោះអ្វីដែលខ្ញុំគិតនោះចំនួនប៉ុណ្ណោះនោះ។

[១៤:២៤:១៨]

**ស៖** សូមអគុណ។ នៅពេលនេះគឺខ្ញុំសូមមើលឯកសារមួយទៀតដែលលោកបានពិភាក្សាឆ្លើយជូនលោកចៅក្រម ខាតវ៉ាយថ៍ កាលពីម្សិលមិញ គឺសេចក្ដីសម្រេចរបស់គណៈមជ្ឈិម ថ្ងៃទី៣០ មីនា ឆ្នាំ៧៦ ឯកសារ E3/12 យើងមានឯកសារនេះជាក្រដាសផងដែរលោកសាស្ត្រាចារ្យ។

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតផ្ដល់ឯកសារនេះជូនលោកសាស្ត្រាចារ្យ។ សូមអរគុណលោកប្រធាន។

**សួរដោយលោក អាប់ឌុលឡាក់ ថារីក៖**

**ស៖** អ្វីដែលយើងព្យាយាមសួរនេះគឺថានៅពេលដែលយើងសួរទៅលើឯកសារនោះមួយ យើងនឹង -- ខ្ញុំនឹងផ្ដល់ឯកសារជាក្រដាសជូនលោក។ យើងខ្ញុំនឹងព្យាយាមពិនិត្យមើលឯកសារនេះមួយៗ។

អ្វីដែលខ្ញុំចាប់អារម្មណ៍នៅក្នុងឯកសារនេះគឺ ERN ជាភាសាអង់គ្លេសគឺ 00182813, ខ្មែរគឺ 00003140, ហើយបារាំងលេខ ERN 00224366។ ឯកសារនេះគឺលើកឡើងអំពីការបង្កើតអង្គការរដ្ឋ។ ខ្ញុំសូមអានផ្នែកមួយនៅក្នុងឯកសារនេះ សូមបញ្ចាំងជាភាសាខ្មែរ សូមអរគុណ។ ចំណុចដែលខ្ញុំចង់អាននោះគឺ ប្រហែលជាពិបាកសម្រាប់លោកអានជាភាសាខ្មែរនៅលើអេក្រង់។

[១៤:២៦:០០]

"លក្ខណៈពិតនៃអង្គការរដ្ឋរបស់យើងនៅពេលនោះ គឺមានលក្ខណៈខុសពីមុន។ លក្ខណៈជាក់ស្ដែងនោះគឺថា អង្កាល់ពីមុនមានរណសិរ្ស យើងឃើញថា រណសិរ្សកាលពីមុនគឺជាអង្គការរដ្ឋ។ ដូច្នេះអង្គការរបស់យើងត្រូវមានអង្គការរដ្ឋដែលត្រូវតំណាងទៅលើស្ថាប័ននៅក្នុងប្រទេស ហើយឆ្លុះបញ្ចាំងអំពីបក្សនៅក្នុងប្រទេស ហើយនិងនៅក្រៅប្រទេសផងដែរ។ នេះគឺជាគោលនយោបាយ នយោបាយរបស់យើងផងដែរ"។ តើចំណុចនេះ គឺឆ្លុះបញ្ចាំងនូវអ្វីដែលលោកយល់ដែរឬទេ?

[១៤:២៦:៥៣]

**លោក ដេវីដ ឆេនដ៍ល័រ៖**

**ឆ៖** ខ្ញុំគិតថា គឺស្របនឹងអ្វីដែលគេធ្វើ។ ឯកសារនេះគេនិយាយអំពីផ្ទៃក្នុងរបស់បក្ស។ ដូច្នេះហើយគេមិនមានអ្វីលាក់គ្នានោះទេ វាជាការពិតហើយដែលគេសរសេរនៅក្នុងឯកសារនេះ។

**ស៖** នៅពេលនេះ យើងចូលទៅដល់រដ្ឋធម្មនុញ្ញវិញម្ដង។ នៅពេលនេះគឺយើងមើលលើបទប្បញ្ញត្តិមួយចំនួននៅក្នុងរដ្ឋធម្មនុញ្ញ យើងមិនចង់ចំណាយពេលច្រើននោះទេ។

មាត្រា៥ នៃរដ្ឋធម្មនុញ្ញ គឺចែងអំពីអំណាចនីតិបញ្ញត្តិ។ ប្រយោគទីមួយនៃមាត្រានោះចែងថា "អំណាចនីតិបញ្ញត្តិគឺមានផ្ដល់ជូនទៅដល់សភាប្រជាជន កម្មករកសិករ និងពលករ"។ ហើយយើងឃើញមានសមាជិក១៥០នាក់នៅក្នុងនោះ។

ឯកសារដែលយើងមើលមុននេះគឺ របាយការណ៍ដែលពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន គឺ E3/273 របាយការណ៍ស្ដីអំពីរដ្ឋធម្មនុញ្ញ ដែលចែងដូចតទៅ៖ "រដ្ឋធម្មនុញ្ញចែងថា អំណាចធ្វើច្បាប់គួរតែផ្ដល់ទៅដល់សភាតំណាងប្រជាជន ដែលត្រូវបានជ្រើសតាំងដោយប្រជាជន ដូចដែលមានចែងនៅ

ក្នុងមាត្រា៦។ ជាការពិត អំណាចធ្វើច្បាប់នេះ គឺផ្តល់ទៅសភា ដើម្បីបង្កើតមាគ៌ានយោបាយ ទាំងនៅខាងក្នុង និងគោលនយោបាយទាំងខាងក្រៅបក្ស"។

[១៤:២៨:៣៥]

មុនពេលខ្ញុំសួរសំណួរមួយចំនួនទៅដល់លោកសាស្ត្រាចារ្យ គឺយើងឃើញថា នៅពីក្រោយបទប្បញ្ញត្តិ និងរបាយការណ៍ទាំងអស់នោះ គឺយើងអាចមើលកំណត់ហេតុរបស់គណៈអចិន្ត្រៃយ៍ -- គណៈមជ្ឈិម -- កែតម្រូវ គណៈអចិន្ត្រៃយ៍។ ឯកសារ E3/322 ចុះថ្ងៃទី -- ចុះឆ្នាំ១៩៧៦។ ឯកសារទំព័រពាក់ព័ន្ធ ERN គឺ 0017118, អង់គ្លេស 00182630, បារាំងគឺ 00323933។

ប្រសិនបើអាចនោះ សូមបញ្ចាំងឯកសារនេះនៅលើអេក្រង់។ សូមអរគុណ។

[១៤:២៩:៥១]

បំណងរបស់ខ្ញុំដែលចង់ផ្តោតទៅលើឯកសារនេះ គឺយោបល់មួយដែលសរសេរនៅក្នុងឯកសារនេះ ដែលចែងសរសេរដូចតទៅ ការដកស្រង់សម្តី៖ "ប្រសិនបើគេសួរ យើងត្រូវពន្យល់ កុំច្រងេងច្រងាង កុំឲ្យឃើញថា យើងចង់បង្ក្រាប។ ទន្ទឹមនេះ ក៏កុំនិយាយលេងពីសភានៅមុខប្រជាជន ឲ្យគេឃើញថា យើងបន្តឹមបន្តំ ហើយសភាពយើងគ្មានតម្លៃអី។ ការពិតនៅតែជាភារកិច្ចរបស់បក្សដដែល"។

ដោយពិចារណាទៅលើចំណុចនេះ នៅក្នុងរដ្ឋធម្មនុញ្ញ និងយោបល់ដែលគេសរសេរនៅក្នុងនេះលោកសាស្ត្រាចារ្យ តើយោបល់ដែលគេធ្វើឡើងនេះឆ្លុះបញ្ចាំងភាពជាក់ស្តែងដែរឬទេ? ឬក៏មានការអនុវត្តតាមរដ្ឋធម្មនុញ្ញត្រឹមត្រូវដែរឬទេ ដែលមានចែងអំពីបញ្ហាអំណាចសភា?

**ឆ៖** នេះ គឺជាឯកសារកម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំមិនដែលឃើញពីមុននោះទេ "កុំនិយាយលេងនៅមុខប្រជាជន កុំច្រងេងច្រងាង ហើយនៅស្ងៀមនោះ" គឺទោះបីជាពាក្យថា ច្រងេងច្រងាង ឬក៏និយាយលេងនោះ គឺពាក្យតែមួយនោះទេ។ បានន័យថា គេឲ្យនិយាយឲ្យបានត្រឹមត្រូវ ហើយគឺគេចង់ដំណើរការការងាររបស់គេទៅតាមអ្វីដែលគេចង់បាន។ នេះគឺជាឯកសារដែលចេញមកពីខាងលើសភាដែលយើងដឹងនោះ គឺថាគេបានកោះប្រជុំម្តងក្រោមការណែនាំរបស់ នួន ជា។ វាពិបាកឲ្យយើងគិតណាស់ដែលថាសមាជិកមួយចំនួន គឺជាសមាជិករបស់គណៈមជ្ឈិម ហើយក៏បានចូលរួមនៅក្នុងសភាផងដែរ។

[១៤:៣១:៥៣]

អ្នកមួយចំនួនដែលគាត់ជាកម្មករស្លៀកពាក់ខោអាវពណ៌ខៀវ ហើយ គឺគាត់ក៏ចូលរួមនៅក្នុង

នោះដែរ។ វាពិបាកឲ្យយើងគិតណាស់ ចំណុចនេះ ថាតើគេប្រជុំ ជួបប្រជុំគ្នាយ៉ាង បានប៉ុន្មានដងនោះ ក៏ប៉ុន្តែយើងឃើញថា មានការជួបប្រជុំគ្នាម្តង។ ហើយដូចជាមិនមានការកោះប្រជុំឡើងវិញនោះទេ។ ឯកសារនេះ គឺគេបាននិយាយថា កុំខ្វល់អី ប្រសិនបើឮអ្វី យើងនៅឲ្យស្ងៀម កុំនិយាយអ្វីទាំងអស់អំពីសភា។ យើងកុំនិយាយថាសភានោះអត់មាន ឬក៏មានតែឈ្មោះទេ។ យើងកុំនិយាយអ្វីទាំងអស់។

**ស៖** ចំណុចមួយចុងក្រោយទាក់ទងទៅនឹងប្រធានបទនេះ និយាយអំពីស្ថាប័នដែលទាក់ទងទៅនឹងការបង្កើតនូវស្ថាប័ន។ លោកបានយោងដោយប្រុងប្រយ័ត្នទៅរកវគ្គនៃការប្រជុំគណៈប្រធានរដ្ឋ នៃកម្ពុជាប្រជាធិបតេយ្យ ឯកសារមួយនៅក្នុងសំណុំរឿងដែលកត់ត្រានៅមហាសន្និបាតនៃសភាតំណាងប្រជាជនកម្ពុជានោះ គឺឯកសារ E3/165។ សូមថយក្រោយមួយជំហានមុននឹងបង្ហាញឯកសារនេះជូនទៅលោក។

[១៤:៣៣:២១]

ខ្ញុំនឹងត្រឡប់ទៅសេក្តីសម្រេចថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ គឺ E3/12 មើលឯកសារនោះ គឺថាដែលគេយោងទៅរកការតែងតាំងមនុស្សមួយចំនួន។ ឯកសារ E3/12 ចំណុចដែលពាក់ព័ន្ធ ហើយ ERN នោះគឺ ខ្មែរ 00003141, ភាសាអង់គ្លេស 00182813 រហូតដល់ 14 ហើយភាសាបារាំង 00224366 រហូតទៅដល់ 67។ នេះគឺជាការពិភាក្សាជាមួយចៅក្រម ខាតវ៉ាយថ៍ ពីម្សិលមិញរួចហើយ។ អ្វីដែលខ្ញុំចង់ឲ្យលោកបញ្ជាក់នោះ គឺយើងចង់ឲ្យលោកបង្ហាញ ចំណុចពាក់ព័ន្ធនៅលើអេក្រង់ ដើម្បីបញ្ជាក់អំពីការចាត់តាំងបុគ្គលមួយចំនួន ហើយយើងមានឯកសារនេះនៅលើអេក្រង់ហើយ។ លោកសាស្ត្រាចារ្យ លោកមានសេចក្តីសម្រេចនេះនៅក្នុងដៃលើក្រដាសហើយ។

នេះជាឯកសារ សូមខាង អេ.វី ជួយផ្សាយ។ ហើយផ្នែកនោះ គឺចាប់ផ្តើមដោយពាក្យថា គឺថាអង្គការចាត់តាំងសភា រៀបរាប់ គឺថាគោលការណ៍ការងារហ្នឹងដូចខាងក្រោម៖

[១៤:៣៤:៥៩]

១) តំណាងទាំងអស់ស្ថិតនៅជាមួយប្រជាជនរបស់ខ្លួនតទៅទៀត។២) គណៈកម្មការអចិន្ត្រៃយ៍នៃសភាតំណាងប្រជាជនកម្ពុជា ប្រធាន សមមិត្ត នួន, អនុប្រធានទីមួយ សមមិត្ត ភឹម, អនុប្រធានទីពីរ សមមិត្ត ម៉ុក។ ហើយនៅខាងក្រោមនេះ និយាយអំពីការចាត់តាំងគណៈប្រធានរដ្ឋគឺ ប្រធានគណៈប្រធានរដ្ឋ គឺប្រធានសមមិត្ត ហែម, អនុប្រធានទីមួយគឺ ប៉ែន នុត ហើយនៅក្នុងរដ្ឋាភិបាល ហើយនៅក្នុងផ្នែកមួយក្នុងរដ្ឋាភិបាល។ រដ្ឋាភិបាលត្រូវតែជាអង្គការរបស់បក្សសុទ្ធសាធ ជារដ្ឋរបស់យើង

ផ្ទាល់។ សំណូមពរឲ្យខ្លាំងដែរ។ ត្រូវមានឥទ្ធិពលនៅក្នុងបក្ស នៅក្នុងប្រទេស នៅក្រៅប្រទេស ចំពោះប្រទេសជាតិជាមិត្តក្តី ចំពោះខ្មាំងក្តី។ សមមិត្ត ប៉ុល ជានាយករដ្ឋមន្ត្រីទីមួយ, សមមិត្ត វ៉ាន់ ឧបនាយកទទួលបន្ទុកការបរទេស, សមមិត្ត វន ឧបនាយកទទួលបន្ទុកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, សមមិត្ត ខៀវ ឧបនាយកទទួលបន្ទុកខាងការពារប្រទេស។ ហើយយើងពិនិត្យមើលស្ថាប័នចុងក្រោយ ថាតើបុគ្គលម្នាក់ៗនេះ សមមិត្ត ប៉ុល ជាអ្នកណា?

[១៤:៣៦:១៦]

**ឆ៖** ពិតហើយ គឺគួរឲ្យចាប់អារម្មណ៍ហ្នឹង គណៈអចិន្ត្រៃយ៍ ហើយជាសមាជិករួមគ្នា តាម៉ុក ហើយនិង សោ ភឹម ហើយ នួន ជា ហើយគឺជាមានសមាជិកជាន់គ្នា។ ហើយទីពីរសមមិត្ត ប៉ុល គឺ ប៉ុល ពត, សមមិត្ត វ៉ាន់ គឺ អៀង សារី, វន គឺ វន វ៉េត, សមមិត្ត ខៀវ គឺ ខៀវ សំផន នេះហើយ គឺទីបួន។

**ស៖** ដើម្បីចៀសវាងការសង្ស័យ សមមិត្តខៀវ -- អត់ទេ ខៀវ ហ្នឹង គឺ សុន សេន ទេ នៅការពារប្រទេសនេះគឺថា ខៀវ គឺឈ្មោះកាត់របស់ សុន សេន។

**ឆ៖** សូមទោស ខ្ញុំខុស។

**ស៖** នៅក្នុងពេលពិនិត្យតទៅទៀត គឺយើងនឹងត្រូវប្រុងប្រយ័ត្ន ពាក្យកាត់នេះ។ ប្រធានគណៈប្រធានរដ្ឋហ្នឹងដែលហៅថា សមមិត្ត ហែម។ តើលោក ហែម នោះជានរណា? លោកយល់ទេ? បាទ សូមលោកឆ្លើយម្តងទៀត ដោយសារ--

**ឆ៖** ហែម គឺខៀវ សំផន។

**ស៖** តើមានមេដឹកនាំជាន់ខ្ពស់នោះទេ ដែលរកឃើញនោះ គឺតាមការស្រាវជ្រាវ ដែលថាស្ថិតនៅក្នុងក្រុមដែលថា នៅក្នុងឋានានុក្រមបក្សកុម្មុយនីស្តកម្ពុជាទូលាយនោះ ដែលមានឈ្មោះហៅក្រៅថា ហែម ដែរឬទេ?

**ឆ៖** *ណូ!* តាមដែលខ្ញុំរកឃើញគឺមានឈ្មោះតែមួយ ហើយគាត់បានទទួលស្គាល់នៅក្នុងប្រវត្តិរូបរបស់គាត់រួចហើយ គឺម្នាក់ៗគេដឹងថាគាត់។

[១៤:៣៨:០៥]

**ស៖** សូមអរគុណ។ ឥឡូវនេះ ខ្ញុំត្រឡប់មកឯកសារទាក់ទងទៅនឹងនីតិបញ្ញត្តិ គឺ E3/165 ហើយយើងមានអត្ថបទជាភាសាខ្មែរ គឺជាភាសាដើម ច្បាប់ដើម សូមបង្ហាញនៅលើអេក្រង់ គឺ ERN

សម្រាប់ផ្នែកដែលយោងនេះ គឺចាប់ផ្ដើមពី 00053634, អង់គ្លេស ERN 00134608, បារាំង ERN 00301354។ នេះជាចំណុចចាប់ផ្ដើមនៃវគ្គនេះ។ ឯកសារនេះគឺចុះថ្ងៃទី -- ជារបាយការណ៍ពីមហាសន្និបាតដែលធ្វើឡើងនៅថ្ងៃទី១១ ដល់១៣ ខែមេសា ឆ្នាំ១៩៧៦។ ឥឡូវនេះខ្ញុំនឹងពិនិត្យមើលតាមឈ្មោះជាជាងខ្លឹមសារ។ ហើយចំណុចថាតើមនុស្សមួយចំនួនដែលយើងពិភាក្សាខាងដើម គឺយើងមើលឃើញថា នៅក្នុងសភាជាអ្នកអនុម័តការតែងតាំងគណៈប្រធានរដ្ឋ ដែលសមមិត្ត ខៀវ សំផន ជាប្រធានទីមួយ។

[១៤:៣៩:៣៩]

ហើយបន្ទាប់មកទៀត នៅចំណុចទី៦ និយាយអំពីការជ្រើសតាំងរដ្ឋាភិបាលថ្មីនៃកម្ពុជាប្រជាធិបតេយ្យ ហើយយើងអាចឃើញ ប៉ុល ពត, អៀង សារី, វន វ៉េត ហើយនិង សុន សេន នៅក្នុងមុខតំណែងដែលលោកបានបញ្ជាក់ខាងដើម។ ហើយបន្ទាប់ពីនោះមក តាមការតែងតាំង -- ជាការចាត់តាំងគណៈកម្មាធិការមួយចំនួនដែលឆ្លើយតបទៅនឹងរដ្ឋមន្ត្រីទទួលបន្ទុកសេដ្ឋកិច្ច វន វ៉េត។

តើលោកអាចធ្វើសេចក្ដីសន្និដ្ឋានដូចម្ដេច ផ្អែកលើអង្គហេតុថា នៅពេលដែលសភារាយការណ៍ចង្អុលបង្ហាញថា រដ្ឋសភាបានពិភាក្សាយ៉ាងលម្អិតទៅលើបញ្ហានេះហើយ នៅថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែមេសា ឆ្នាំ១៩៧៦?

ដូចដែលយើងបានឃើញនៅទីនេះ នៅថ្ងៃទី៣០ ខែមីនា យើងបានឃើញថា មានការតែងតាំងមនុស្សមួយចំនួនស្រដៀងគ្នានេះដែរ ទៅក្នុងគណៈមជ្ឈិម។ តើលោកអាចទាញសេចក្ដីសន្និដ្ឋានដូចម្ដេចអំពីហេតុការណ៍ដែលមានរបាយការណ៍របស់សភា ហើយនិងការតែងតាំងនៅក្នុងសេចក្ដីសម្រេចថ្មីនេះបាទ?

**ឆៈ** ខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា ការចាត់តាំង គឺមិនធ្វើឡើងដោយការពិភាក្សានៅក្នុងរដ្ឋសភាទេ គឺសេចក្ដីសម្រេចធ្វើ គឺការប្រជុំសភាមានតែម្ដងទេ។ ការចាត់តាំងគឺត្រូវបានធ្វើឡើង អត់ទេ នៅពេលដែលមានការព្រមព្រៀង ដោយសភា ដែលគេថ្នាក់លើបង្ហាញ។ នេះជាវិធីដែលធ្វើការ។ គឺសំណើបញ្ជូនពីលើមកក្រោម មិនមែនពីក្រោមទៅលើទេ។ នេះហើយជារយៈពេលដែលថា ពីថ្ងៃ១៣ មេសា មកដល់ថ្ងៃទី៣០ មីនា ជាដើមនោះក្នុងឆ្នាំហ្នឹង។

[១៤:៤១:៥១]

**សៈ** សូមអរគុណ លោកអ្នកជំនាញ។

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះដល់ពេលសមល្មមសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការផ្តល់កន្លែងសម្រាកសមរម្យនៅបន្ទប់សម្រាកសម្រាប់រង់ចាំ សម្រាប់សាក្សី និងអ្នកជំនាញ ហើយនិងឲ្យអញ្ជើញអ្នកជំនាញមកកាន់កន្លែងផ្តល់សាក្សីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅវេលាម៉ោងបី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង១៤:៤២ នាទី ដល់ម៉ោង ១៥:០២នាទី)*

[១៥:០២:០០]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ លោកមេធាវីអន្តរជាតិការពារក្តី លោក នួន ជា សូមអញ្ជើញ!

**លោក ហ្សាស្តើ ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអធ្យាស្រ័យដែលខ្ញុំកាត់លោកសហព្រះរាជអាជ្ញា។ យើងដឹងថា យើងហត់ហើយ ខ្ញុំសូមលើកឡើងថា សំណួរដែលខ្ញុំចង់សួរនោះ ពាក់ព័ន្ធទៅនឹងការតាំងសំណួររបស់ខ្ញុំទៅលោក ដេវីដ ឆេនដ័ល័រ នាពេលក្រោយ ហើយខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះ។ យើងខ្ញុំមិនចង់ធ្វើការរំលោភទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះនោះទេ។ ពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចរបស់លោកប្រធាន ដែលមិនទទួលយកឯកសាររបស់យើងតាមវិធាន៨៧/៤ នោះ គឺយើងខ្ញុំចង់ឲ្យលើកឡើងលើបញ្ហានេះឡើងវិញនោះទេ ក៏ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់បំភ្លឺទៅលើផលវិបាកដែលកើតចេញពីសេចក្តីសម្រេចនេះ ដើម្បីកុំឲ្យយើងខ្ញុំរំលោភបំពានទៅលើដីកាបង្គាប់របស់អង្គជំនុំជម្រះ។

[១៥:០៣:១៩]

យើងខ្ញុំយល់ថា ឯកសារទាំងអស់នោះមិនអាចទទួលយកធ្វើជាភស្តុតាង ហើយមិនអាចទទួលយកដោយអង្គជំនុំជម្រះតាមវិធាន៨៧/៤ នោះឡើយ។ ក៏ប៉ុន្តែយើងខ្ញុំចង់ដឹងឲ្យបានច្បាស់ថាតើយើងអាចផ្អែកលើខ្លឹមសារនៃឯកសារនោះដោយរបៀបណា? បញ្ហាដែលយើងខ្ញុំលើកចំណុចនេះឡើង គឺដោយសារតែនៅក្នុងសេចក្តីសម្រេចមុនលើសំណើរបស់ អៀង សារី លោកប្រធានបានសម្រេចថាឯកសារមួយចំនួនដែលមិនបំពេញលក្ខខណ្ឌ៨៧(៤) គឺត្រូវតែអាចឲ្យយើងយកមកធ្វើមូលដ្ឋានដដែលជាពិសេសទៅលើខ្លឹមសារនៃឯកសារទាំងអស់នេះ ដើម្បីឲ្យយើងអាចយកមកដេញដោលសាក្សីរូបនេះបាន។ ដូច្នេះយើងខ្ញុំសូមសួរថា តើមានមធ្យោបាយណាមួយដែលយើងអាចប្រើប្រាស់ខ្លឹមសារនៃឯកសារដែលយើងខ្ញុំស្នើសុំនេះបានដែរឬទេ ដើម្បីរៀបចំសំណួរសួរទៅកាន់លោក ដេវីដ ឆេនឌ័ល័រ? បន្ថែមបន្តិចទៅលើចំណុចដែលខ្ញុំសួរបំភ្លឺនេះ។ គឺនៅពេលដែលយើងដាក់សំណើសុំតាមវិធាន៨៧(៤) នេះគឺយើងបានព្យាយាមគោរពតាមសេចក្តីសម្រេចមុនៗរបស់អង្គជំនុំជម្រះ ដែលយើងត្រូវតែធ្វើដូច្នេះដើម្បីអាចយើងសួរឲ្យមានការជឿជាក់ទៅលើអ្នកជំនាញសាក្សីនេះបាន ជាពិសេសការផ្អែកទៅលើឯកសារ។

[១៥:០៤:៤៦]

ខ្ញុំមិនចង់ឲ្យវាពិបាកសម្រាប់យើងទាំងអស់គ្នានោះទេ ក៏ប៉ុន្តែយើងខ្ញុំមិនអាចមានសិទ្ធិក្នុងសួរទៅកាន់អ្នកជំនាញនោះឡើយ។ យើងខ្ញុំបានដាក់សំណើសុំនេះទៅហើយ ហើយចៅក្រម ឡាវែន៍ គឺគាត់ គិតថា ឯកសារមួយចំនួននោះ គឺវាមានភាពពាក់ព័ន្ធ។ ក៏ប៉ុន្តែយ៉ាងណាក៏ដោយ យើងខ្ញុំមិន ចង់លើកឡើងបញ្ហានេះឡើងវិញ តាមវិធាន៨៧(៤) នោះទេ។ ក៏ប៉ុន្តែយើងខ្ញុំសូមបញ្ជាក់ថា យើងខ្ញុំត្រូវផ្អែកទៅលើខ្លឹមសារឯកសារទាំងអស់នេះ ដើម្បីសួរដេញដោលឲ្យមានប្រសិទ្ធភាពទៅសាក្សីអ្នកជំនាញ។

ការមិនប្រើប្រាស់ឯកសារទាំងអស់នេះ សម្រាប់យើងខ្ញុំនោះ គឺមិនអាចយើងខ្ញុំសួរទៅលើភាពជឿជាក់លើអ្នកជំនាញនេះទេ។ ដូច្នេះ ហើយខ្ញុំសូមសួរថា តើយើងអាចផ្អែកទៅលើខ្លឹមសារនៃ ឯកសារទាំងអស់នោះបានដែរឬទេ? ហើយប្រសិនបើយើងខ្ញុំមិនអាចផ្អែកទៅលើខ្លឹមសារនៃឯកសារទាំងអស់នោះទេ គឺយើងខ្ញុំសូមការណែនាំពីអង្គជំនុំជម្រះ ថាតើយើងខ្ញុំធ្វើយ៉ាងណាសួរទៅលើអ្នកជំនាញនេះបានដើម្បីឲ្យវាជាផលប្រយោជន៍ទៅដល់សាធារណជន។ ដូច្នេះហើយ គឺឲ្យអង្គជំនុំជម្រះនោះ ជួយបញ្ជាក់ណែនាំយើងខ្ញុំផង ថាតើធ្វើយ៉ាងម៉េច ទើបយើងខ្ញុំអាចផ្អែកទៅលើខ្លឹមសារនៃឯកសារដែលយើងបានស្នើសុំ ហើយបានបដិសេធនោះបាន?

[១៥:០៦:១១]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:១០:០០]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីឆ្លើយតបទៅនឹងសំណើសុំបញ្ជាក់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា។

សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងសូមអរគុណទៅលើចំណុចដែលមេធាវីការពារក្តីបានលើកឡើងនេះ។ ដូច្នេះយើងខ្ញុំសូមឆ្លើយតបដូចតទៅ៖ ទាក់ទងទៅនឹងអនុស្សរណៈ ដប់ -- អនុស្សរណៈចុះថ្ងៃទី១៦ កក្កដា ឯកសារ E3/172/24/4 ដែលឆ្លើយតបទៅនឹងលោក អៀង សារី បញ្ហានេះគឺបានសរសេរនៅក្នុងកថាខណ្ឌ៥ ហើយខ្ញុំសូមលើកឡើងសាជាថ្មីម្តងទៀត នូវអ្វីដែលអង្គជំនុំជម្រះបានសម្រេចឆ្លើយតប ទៅនឹងពាក្យសុំរបស់មេធាវីការពារក្តី អៀង សារី។ ដោយសារតែវាអាចអនុវត្តចំពោះពាក្យ -- ចំពោះក្រុមមេធាវីការពារក្តី នួន ជា ផងដែរ។

[១៥:១០:១០]

យើងត្រូវបញ្ជាក់ថាអង្គជំនុំជម្រះមិនបានពិចារណាទៅលើឯកសារ E3/172/24/4 ដោយសារត្រូវពិចារណាផ្អែកទៅតាមលក្ខខណ្ឌ៨៧(៤) សេចក្តីសម្រេចនេះបានចែងយ៉ាងច្បាស់ថាមិនមានឧបសគ្គណាមួយចំពោះមេធាវី អៀង សារី ផ្អែកទៅលើខ្លឹមសារនៃឯកសារទាំងអស់នោះនោះទេ នៅពេលដែលសួរសំណួរទៅកាន់អ្នកជំនាញ។ ដរាបណាមេធាវី អៀង សារី ផ្តល់ឯកសារជូនព័ត៌មានអំពីឯកសារទាំងអស់នោះដល់អង្គជំនុំជម្រះ។ អៀង សារី ក៏ត្រូវផ្តល់ជូន -- មេធាវី អៀង សារី ក៏ត្រូវផ្តល់ជូនលេខ ERN ដល់អង្គជំនុំជម្រះផងដែរ។ ដូច្នេះហើយ ចំណុចទាំងអស់នេះហើយយើងបានសម្រេចនៅក្នុងសេចក្តីសម្រេចរបស់យើង។ ដូច្នេះហើយថា តើវាអាចឆ្លើយតបទៅនឹងការរៀបចំផែនការរបស់លោកក្នុងការរៀបសំណួរសួរទៅកាន់អ្នកជំនាញដែរឬទេ?

[១៥:១២:០៨]

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកចៅក្រម។ ច្បាស់លាស់ហើយ ខ្ញុំសូមបញ្ជាក់ថា យើងបានរកឯកសារមក

ទាំងអស់ហើយ ដែលយើងនឹងផ្អែកសួរទៅកាន់អ្នកជំនាញ ហើយយើងនឹងចែកជូនទៅដល់ភាគីទាំងអស់នេះនៅក្នុងបន្ទប់សវនាការ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមផ្តល់វេទិកាទៅតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ។

[១៥:១២:៤៣]

**លោក អាប់ឌុលឡាក់ ថារីក៖**

សូមអរគុណលោកប្រធាន។

ប្រសិនបើ ខ្ញុំអនុញ្ញាតនោះគឺថាចំពោះលោក ដេវីដ ឆេនដ៍ល័រ គឺយើងខ្ញុំសូមឲ្យលោកនិយាយឲ្យបានយឺតៗបំផុតតាមដែលអាចធ្វើទៅបាន។ ខ្ញុំសូមអធ្យាស្រ័យផងដែរលើចំណុចនេះ។ ជាពិសេស ការនិយាយយឺតនោះដើម្បីឲ្យអ្នកបកប្រែ និងអ្នកស្តាប់ជាភាសាខ្មែរអាចតាមបាន -- តាមទាន់បាន។ ខ្ញុំដឹងហើយ ថាខ្ញុំចូលទៅលើឯកសារជាច្រើន ដូច្នេះហើយគឺសូមឲ្យលោក ដេវីដ ឆេនដ៍ល័រ និយាយឲ្យបានយឺតៗជាងមុន។ ចំណុចទីពីរ ខ្ញុំមានបំណងលើកឡើងចំណុចនេះក្រោយពេលឈប់សម្រាក ជាពិសេសទៅលើកាលវិភាគ និងពេលវេលា។

[១៥:១៣:២៨]

ខ្ញុំគ្រាន់តែចង់ឲ្យអង្គជំនុំជម្រះយល់ឃើញថា -- ហើយអង្គជំនុំជម្រះក៏អាចពិចារណាទៅលើចំណុចនេះផងដែរ ជាពិសេសនៅពេលដែលយើងឈប់សម្រាកវគ្គបន្ទាប់ទៀតនោះ។ យើងទទួលបានពីរថ្ងៃកន្លះនៃពេលវេលាសរុប ដែលសរុបទៅ១២ម៉ោង ប្រសិនបើខ្ញុំគណនាតាមគណិតសាស្ត្រទៅត្រឹមត្រូវ។ ដូច្នេះហើយមកត្រឹមថ្ងៃនេះ គឺយើងប្រហែលជាទើបប្រើប្រាស់អស់៧ម៉ោងតែប៉ុណ្ណោះ។ ដូច្នេះហើយនៅសល់ ៥ម៉ោងទៀត សម្រាប់ថ្ងៃស្អែក។ ដូច្នេះហើយនៅថ្ងៃស្អែកនេះយើងអាចចំណាយពេលមួយថ្ងៃពេញ ហេតុដូច្នេះអង្គជំនុំជម្រះអាចធ្វើយ៉ាងណាពិចារណា មុនពេលដែលយើងត្រឡប់មកវិញនោះឲ្យមានការណែនាំទៅដល់យើងខ្ញុំ ថាតើ -- ហើយយើងខ្ញុំនឹងព្យាយាមបញ្ចប់ឲ្យបានត្រឹមថ្ងៃស្អែកវគ្គដំបូង។

[១៥:១៤:៣៤]

ហើយយើងនឹងទុកពេលវេលាដែលនៅសល់ទៅដល់ក្រុមផ្សេង។ ហើយក្រុមខ្ញុំសង្ឃឹមថា ក្រុម

មេធាវីការពារក្តីនឹងអនុគ្រោះចំពោះបញ្ហានីតិវិធី ទុកមួយឡែកសិនទៅលើបញ្ហាទាំងអស់នេះនៅពេលដែលចង់លើកឡើង។

**សួរដោយលោក អាប់ឌុលឡាក់ ថារីកៈ**

**សៈ** លោក ដេវីដ ឆេនដ៍ល័រ សូមអរគុណលោកដែលលោកត្រឡប់មកផ្តល់សក្ខីកម្មវិញ។ យើងដឹងថាវានៅ -- វារសៀលជិតចប់ហើយ។ ហើយខ្ញុំដឹងថាវាមានការហត់នឿយណាស់។ យើងខ្ញុំសូមថ្លែងអំណរគុណ ដែលលោកមកជួយផ្តល់ចម្លើយចំពោះសំណួរដែលទាក់ទងទៅនឹងប្រធានបទមួយចំនួនដែលយើងខ្ញុំចោទសួរ។ នៅមានប្រធានបទតូចមួយទៀត ពាក់ព័ន្ធទៅនឹងស្ថាប័នរបស់កម្ពុជាប្រជាធិបតេយ្យ ដែលខ្ញុំចង់លើកឡើងមុនពេលដែលខ្ញុំចូលទៅដល់ប្រធានបទផ្សេងមួយទៀត។

[១៥:១៥:៣៣]

បញ្ហាប្រធានបទដែលខ្ញុំចង់ចោទសួរ គឺពាក់ព័ន្ធទៅនឹងការលាលែងរបស់សម្តេច នរោត្តម សីហនុ នៅក្នុងខែមីនា និងខែមេសា ឆ្នាំ១៩៧៦ និងហេតុការណ៍ជុំវិញបញ្ហានេះ។ លោកបានលើកឡើងបញ្ហាប្រធានបទនេះលម្អិតហើយនៅក្នុងសៀវភៅ បងធំលេខ១ E3/17 ហើយនិងអត្ថបទ ដែលពាក់ព័ន្ធ 00821775 ជាភាសាខ្មែរ លេខ ERN ជាភាសាខ្មែរ, ចំពោះលេខ ERN ជាភាសាអង់គ្លេស 00393023។ ខ្ញុំចង្អុលបញ្ជាក់ទៅអត្ថបទនេះ ដោយសារតែឲ្យយើងទាំងអស់គ្នានោះត្រៀមអត្ថបទនេះរួចជាស្រេច ដោយសារតែនៅក្នុងអត្ថបទនោះលោកបានលើកឡើង។ ឯកសារមួយដែលខ្ញុំនឹងបង្ហាញជូនលោក។ ដូច្នេះហើយលោកអាចនិយាយចូលត្រង់ៗ ទៅដល់ចំណុចឯកសារនេះតែម្តង។

[១៥:១៦:៤៧]

លោកសាស្ត្រាចារ្យ នៅឆមាសទី១ ខែមីនា ឆ្នាំ៧៦ តាមឯកសារដែលចង្អុលបញ្ជាក់នេះ ឯកសារពាក់ព័ន្ធទីមួយ គឺកំណត់ហេតុគណៈអចិន្ត្រៃយ៍ ចុះថ្ងៃ១១ ខែមីនា ឆ្នាំ១៩៧៦ គឺវាលើកឡើងអំពីថ្ងៃទី១១ និង១៣ ខែមីនា ឯកសារ E3/197។ កម្មវត្ថុនៅក្នុងទំព័រដំបូងនោះ របៀបវារៈដែលគេសរសេរនៅក្នុងចំណុចដំបូងនោះគឺ ការលាលែងរបស់សម្តេច នរោត្តម សីហនុ ហើយយើងខ្ញុំនឹងចូលទៅដល់ប្រធានបទដែលយើងចាប់អារម្មណ៍នៅក្នុងថ្ងៃនេះ។ ខ្មែរ ERN គឺ 00000744, ERN ជាភាសាអង់គ្លេស គឺ 00182638, បារាំងលេខ ERN គឺ 00334961។ ខ្ញុំដឹងថា លោកសាស្ត្រាចារ្យបានទទួលឯកសារជាក្រដាសជាភាសាអង់គ្លេសរួចមកហើយ។

[១៥:១៨:០៧]

អត្ថបទនេះគឺសរសេរដូចតទៅ៖ ខ្ញុំនឹងអានជាភាសាអង់គ្លេស ដើម្បីជាប្រយោជន៍ទៅដល់អ្នកដែលមានឯកសារនេះជាក្រដាស។ ដូច្នេះ ខ្ញុំក៏សូមបង្ហាញឯកសារនេះជាភាសាខ្មែរនៅលើអេក្រង់ផងសម្រាប់អ្នកដែលនិយាយភាសាខ្មែរ។ ចំណុចទី៣ លោក ដេវីដ ឆេនដ៍ល័រ ប្រធានបទទី៣៖ "យោបល់របស់អង្គការ ការប្រជុំនៅថ្ងៃទី១៣ ល្ងាចថ្ងៃ១៣ ខែមីនា សមមិត្ត ហែម រាយការណ៍ទៅគណៈអចិន្ត្រៃយ៍អំពីបញ្ហាសម្តេច សីហនុ ទ្រង់បានសម្រេចលាលែងពីតំណែង លោកបានពន្យល់ថា អង្គការគួរតែអាណិតអាសូរទៅដល់សម្តេច។ ហើយគាត់ សម្តេចនៅតែគោរពលើអង្គការដដែល ទុកឲ្យសម្តេចលាលែងពីតំណែងនោះទៅ។ លិខិតលាលែងនេះ គឺមិនមានអ្វីផ្ទុយទៅនឹងយើងនោះឡើយ"។

[១៥:១៩:១០]

អត្ថបទបន្ទាប់គឺលេខាបក្សបានពន្យល់ថា "វាជាបញ្ហាធំ ហើយឲ្យខាងមជ្ឈិមជាអ្នកសម្រេច" ក៏ប៉ុន្តែលេខាបានលើកឡើងថា "គោលការណ៍ចម្បងដែលគណៈអចិន្ត្រៃយ៍ បានឯកភាពនោះគឺមានដូចតទៅ៖ ទីមួយ កុំទុកសម្តេច សីហនុ។ ទីមួយ កុំឲ្យសម្តេច សីហនុ ចេញពីប្រទេស។ នេះជាវិធានការទីមួយ។ ចំណុចទីពីរ ត្រូវតែកោះប្រជុំគណៈក្រុមប្រឹក្សារដ្ឋមន្ត្រី ដើម្បីឲ្យសម្រេច ហើយបន្ទាប់មកទៅជួបសម្តេច សីហនុ សាជាថ្មីដោយមាន ប៉ែន នុត ចូលរួម"។

[១៥:១៩:៥៣]

យើងមានអត្ថបទខ្លីពីរទៀត ដែលខ្ញុំចង់អាន ហើយយើងខ្ញុំនឹងត្រឡប់ចូលសួរទៅដល់ចំណុចទាំងអស់នោះឡើងវិញ។ ចុះមកក្រោមបន្តិច ទៅលើប្រធានបទដដែលនៅក្នុងចំណុច ខ ដែលចាប់ផ្តើមពីចំណុចដែលសរសេរដូចតទៅថា "ដែលវាពាក់ព័ន្ធនឹងការពិភាក្សាទៅលើការលាឈប់ពីសម្តេច -- របស់សម្តេច សីហនុ។ លោកបានចូលរួមជាមួយនឹងបដិវត្តន៍របស់យើង ទោះបីជាយ៉ាងណាក៏ដោយដូច្នេះហើយគឺយើងសម្រេចថា គាត់ -- លោកគួរតែជាប្រធានរដ្ឋ។ ក៏ប៉ុន្តែសម្តេចគាត់មិនឯកភាព។ ដូច្នេះ មិនថាសម្តេចគាត់លាលែង ឬក៏នៅដដែលនោះ គឺវាជាបញ្ហារបស់ទ្រង់។ យើងនៅតែរក្សាទុកជានិមិត្តរូប យើងមិនសម្លាប់ទ្រង់នោះឡើយ។ ក៏ប៉ុន្តែដើម្បីជាតិ និងប្រជាជន លោកបានប្រព្រឹត្តកំហុស។ ដូច្នេះ សេចក្តីសម្រេចរបស់យើង គឺមានលក្ខណៈសមហេតុផល យើងនៅតែរក្សាទុកទ្រង់ដដែល មិន -- ដូច្នេះ គឺមិនថាទ្រង់ព្យាយាមរស់នៅដោយរបៀបណានោះទេ គឺយើងត្រូវតែផ្តល់សេរីភាពទៅដល់ទ្រង់"។

[១៥:២១:១៩]

អត្ថបទបន្ទាប់ ដែលចាប់ផ្តើមទៅលើចំណុចលេខ៥ "ការណែនាំ និងការបង្កើតរបស់បដិវត្តន៍។

យើងត្រូវតែបញ្ចប់សក្តិភូមិ។ ល្បែងនេះ គឺដល់ចំណុចនេះហើយ។ សក្តិភូមិត្រូវបានកម្ទេច ហើយបានជីកដោយបដិវត្តន៍។ ស្តេចមានមក២ពាន់ឆ្នាំមកហើយ ទីបំផុតត្រូវស្អាត។ យើងគ្មានផ្លូវអ្វីចេញក្រៅពីនេះទេ”។

លោកសាស្ត្រាចារ្យ នៅពេលដែលយើងមើលចំណុចនេះ និងការរំដោះជាតិទាំងអស់នេះ តាមការស្រាវជ្រាវរបស់លោក គឺលោកបានស្រាវជ្រាវលើហេតុការណ៍ពាក់ព័ន្ធទៅនឹងគោលនយោបាយរបស់គណៈមជ្ឈិមនាពេលនោះ។ តើលោកអាចផ្តល់ជាយោបល់អំពីអត្ថបទចុងក្រោយដែលយើងទើបតែអានអម្បាញ់មិញទាក់ទងទៅនឹងតួនាទីរបស់សម្តេចសីហនុ ដែល -- ហើយជាពិសេសនោះត្រង់ចំណុចដែលថាកម្ទេចរបបសក្តិភូមិ ហើយស្តេចដែលមក២ពាន់ឆ្នាំមកហើយនោះ ទីបំផុតត្រូវស្អាតដូច្នេះ ហើយថា តើវាជាការអនុវត្តតាមគោលនយោបាយរបស់បក្សដែរឬទេ?

**លោក ផេរីង ឆេនដ័រ៖**

**ឆ៖** គឺគេចង់ដកសម្តេចចេញ ហេតុផលមួយនោះ គឺគេមិនចង់ទុកទ្រង់នោះទេ ក៏ប៉ុន្តែគេចង់ឲ្យទ្រង់នៅជាមួយពួកគេ ដែលឲ្យនៅដូចតែ ជូ អេនឡាយ នៅប៉េកាំង អ៊ីចឹង។ នៅពេលដែល ជូ អេនឡាយ ស្លាប់នោះ គឺគាត់បាត់បង់នូវការទទួលការគ្រប់គ្រងដោយផ្ទាល់ពីប្រទេសចិន។ ដូច្នេះហើយ វាជាការគិតគូររបស់ពួកគាត់ដែលថា ពួកគេត្រូវតែដកគាត់ចេញ ដកទ្រង់ចេញពីតំណែង ក៏ប៉ុន្តែត្រូវតែឃុំឃាំងទ្រង់។ ដូច្នេះចំពោះបញ្ហាសក្តិភូមិវិញ គឺជាការប្រើប្រាស់ពាក្យសំដៅទៅលើរាជានិយមនៅក្នុងការប្រើប្រាស់ពាក្យរបស់ខាងបក្សកុម្មុយនីស្តកម្ពុជា។

[១៥:២៣:៣៤]

ដូច្នេះហើយ ការតម្រូវឲ្យសម្តេច ទ្រង់សម្តេច សីហនុ នៅពេលនោះឈប់ពីតំណែង ហើយគេនៅតែគិតថា សម្តេច គឺមានតម្លៃសម្រាប់ក្រុមរបស់គេ។ យើងដឹងហើយថា ក្រុមទាំងអស់នោះ បានចងសម្ព័ន្ធគ្នានៅទសវត្សរ៍ឆ្នាំ៧០។ ក៏ប៉ុន្តែគេចង់ឲ្យវាមានរក្សាទំនាក់ទំនងដដែលទៅនឹងប្រទេសខាងក្រៅ។ ដូច្នេះហើយ នេះ ទាំងអស់នេះ គឺជាបញ្ហានយោបាយ ហើយគេចង់ធ្វើឲ្យមានភាពស្អាតស្អំ។ ដូច្នេះនៅពេលដែលទុកទ្រង់នៅក្នុងរូបភាពនោះ គឺក៏វាមិនជួយទៅដល់ក្រុមគេប៉ុន្មាននោះដែរ។ ដូច្នេះហើយ យើងឃើញថា នេះជាសំណើរបស់សម្តេចដែលរាយការណ៍ដោយ ខៀវ សំផន។ ហើយសម្តេចនៅពេលនោះក៏មានការភ័យខ្លាចដោយការកាប់សម្លាប់ផងដែរ។ ទើបទ្រង់បានធ្វើការលាលែងគ្រប់មុខតំណែងទាំងអស់។ យើងដឹងហើយថា លេខា ប៉ុល ពត នោះគឺគាត់គិតថា វាមិនសមរម្យនោះទេដែលត្រូវតែបន្ត

សង្គ្រាមជាមួយនឹងសក្តិភូមិនោះ។

[១៥:២៤:៥៣]

**ស៖** នៅពេលដែលលើកឡើងថា លេខាសម្រេចចាត់វិធានការមួយចំនួននោះ ដូច្នេះចំណុចនេះតើមានន័យថា សេចក្តីសម្រេចនេះ គឺវាមានលក្ខណៈខុសពីសេចក្តីសម្រេចរួមដែលយើងបានលើកឡើងកាលពីម្សិលមិញដែរឬទេ?

**ឆ៖** មិនដូច្នោះទេ យើងដឹងហើយថា យើងឃើញលោកម្នាក់នុ៎ង នៅពេលនុ៎ង គឺស្តាប់ទៅលើការពិភាក្សាដែរ ដូច្នេះហើយនៅក្នុងបន្ទប់នោះគឺគេបានពិភាក្សាគ្នា ហើយមិនមាននរណានៅក្នុងនោះគឺគាំទ្រការលើកឡើងដូច្នេះ។ ក៏ប៉ុន្តែនេះគឺជាបញ្ហារបស់នាយករដ្ឋមន្ត្រីដែលត្រូវធ្វើការសម្រេចទៅបញ្ហារបស់ប្រធានរដ្ឋ។ នៅពេលនោះក៏គេមានក្រុមរដ្ឋមន្ត្រីរបស់គេ ដែលគេពិចារណាផងដែរ។ ហើយខ្ញុំប្រាកដជាដឹងថា គណៈអចិន្ត្រៃយ៍ក៏ប្រហែលជាអាចមានការឯកភាពគ្នាទៅលើចំណុចនោះដែរ ដែលថាគេមិនចង់ឱ្យសម្តេចនោះមានតួនាទី ដើរតួនាទីជាក់លាក់នៅក្នុងប្រទេសកម្ពុជាបន្តទៅទៀត។

[១៥:២៦:០៣]

**ស៖** សូមអរគុណ មុនពេលដែលយើងចេញពីប្រធានបទនេះ នោះគឺយើងខ្ញុំចង់ឱ្យលោកមើលឯកសារមួយដែលចុះថ្ងៃ០៤ ខែមេសា ឆ្នាំ១៩៧៦ គឺមិនដល់មួយខែផង គិតពី៧៥ មក។ ឯកសារ E3/275។ វាមិនមានជាភាសាខ្មែរនិងបារាំងនោះទេ វាជាការគួរឱ្យសោកស្តាយ។ អង់គ្លេស ជាភាសាអង់គ្លេសគឺ 00170605។ យើងមានឯកសារជាក្រដាសសម្រាប់លោកសាស្ត្រាចារ្យ។ ERN ជាភាសាអង់គ្លេស 00176605។ យើងខ្ញុំផ្តល់ឯកសារជាក្រដាសជូនលោកសាស្ត្រាចារ្យមួយច្បាប់ដែរ។ ឯកសារនេះ គឺពាក់ព័ន្ធទៅនឹងលោក ខៀវ សំផន។ គឺ ការផ្សព្វផ្សាយនៅថ្ងៃទី០៤ ខែមេសា ឆ្នាំ៧៦ ដែលមានចំណងជើងថា “សេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យតាមសំណើរបស់ប្រធានរដ្ឋសម្តេច សីហនុ ដែលសុំនិវត្តន៍”។ ខ្ញុំសូមអានទៅលើអត្ថបទនេះ ប្រសិនបើមិននៅលើអេក្រង់នេះ គឺយើងខ្ញុំសូម អាននៅខាងក្រោមហ្នឹងបន្តិច។

[១៥:២៧:៤៥]

“ក្រុមប្រឹក្សារដ្ឋមន្ត្រីយល់ឃើញថា សម្តេច នរោត្តម សីហនុ គឺជាព្រះរាជាដែលមានសេចក្តីស្នេហាជាតិ ហើយបានចូលរួមចំណែកយ៉ាងសកម្មនៅក្នុងការតស៊ូដើម្បីរំដោះជាតិ ប្រឆាំងនឹងសង្គ្រាមឈ្លានពានយ៉ាងខ្លាំងក្លាអំពីចក្រពត្តិអាមេរិក និងបរិវាររបស់វា” ។

ចំណុចទីបីនៃសេចក្តីសម្រេចរបស់មហាសន្និបាតជាតិចុះថ្ងៃទី២៧ ខែមេសា ៧៥ បានបញ្ជាក់យ៉ាងច្បាស់អំពីសេចក្តីល្អរបស់សម្តេច ហើយនិងការអះអាងរបស់ទ្រង់ក្នុងការរក្សាឋានៈរបស់សម្តេច នរោត្តម សីហនុ ជាប្រមុខរដ្ឋនៅក្នុងប្រវត្តិសាស្ត្រ នៅក្នុងដំណាក់កាលថ្មីរបស់ប្រទេសកម្ពុជា និងនៅក្នុងសង្គមកម្ពុជាថ្មី ក៏ប៉ុន្តែសម្តេចមានបំណងចូលនិវត្តន៍។ ដូច្នេះហើយទ្រង់នឹងមានពេលវេលារស់នៅជីវិតឯកជនជាមួយគ្រួសាររបស់ខ្លួនក្រោយពីព្រះអង្គបានធ្វើសកម្មភាពនយោបាយរយៈពេល ៣៥ឆ្នាំ។

[១៥:២៨:៥៩]

រដ្ឋមន្ត្រី -- គណៈរដ្ឋមន្ត្រី បានបង្ហាញការសោកស្តាយចំពោះសំណើសុំនិវត្តន៍ -- ចូលនិវត្តន៍របស់សម្តេច នរោត្តម សីហនុ។ ក៏ប៉ុន្តែ ដោយគោរពទៅលើគោលបំណងខ្ពង់ខ្ពស់របស់សម្តេច ក្រុមប្រឹក្សារដ្ឋមន្ត្រី បានសម្រេចយល់ព្រមតាមសំណើសុំចូលនិវត្តន៍។ លោកសាស្ត្រាចារ្យ ឆេនដ៍ល័រ ផ្អែកទៅលើការស្រាវជ្រាវរបស់លោកទៅលើព្រឹត្តិការណ៍មួយនេះ។ តើរបាយការណ៍មួយនេះ ដែលពាក់ព័ន្ធនឹងក្រុមប្រឹក្សារដ្ឋមន្ត្រីនោះ គឺវាផ្អែកទៅលើអ្វីដែលគេបានសម្រេចពាក់ព័ន្ធទៅនឹងការចូលនិវត្តន៍របស់សម្តេច សីហនុ ដែរឬទេ?

**ឆ៖** គឺវាប្រាកដអ៊ីចឹងមែន ប្រសិនបើយើងឃើញឯកសារនេះ។ យើងឃើញហើយថា ឯកសារនេះគឺវាពាក់ព័ន្ធនឹងគោលនយោបាយ ដែលថា ត្រូវតែឃុំខ្លួនលោក ក៏ប៉ុន្តែមិនសម្លាប់ទ្រង់នោះ ហើយដោយសារតែគុណបំណាច់របស់ទ្រង់នៅក្នុងការធ្វើនយោបាយរយៈពេល ៣៥។ នេះគឺជារបាយការណ៍ដែលបានធ្វើឡើង មិនមានៗការបកប្រែជាភាសាខ្មែរនោះទេ ក៏ប៉ុន្តែយើងបានស្តាប់ហើយ វាជាការល្អមួយ។ ការផ្សព្វផ្សាយនេះ គឺដើម្បីគេត្រួតពិនិត្យទៅលើព្រឹត្តិការណ៍នោះ។ ហើយគេៗធ្វើយ៉ាងណាកុំឱ្យមានការយល់ច្រឡំអំពីឋានៈរបស់សម្តេច សីហនុ។ គេមិនធ្វើការបោះបង់សម្តេច សីហនុ នោះទេ ដោយសារតែលោកក៏ជាប់ពាក់ព័ន្ធទៅនឹងរណសិរ្សផងដែរ។ ដូច្នេះ ការផ្សព្វផ្សាយ ដើម្បីឱ្យអ្នកដែលនៅខាងក្រៅនោះ គាត់ជឿទៅលើចំណុចនេះ។ របាយការណ៍នេះ គឺជាការផ្សព្វផ្សាយមួយត្រឹមត្រូវដែលថារបបនោះ គឺជារបបមានហេតុផល ហើយមានការគោរពទៅលើនិមិត្តរូប ឬក៏បុគ្គលមួយរូបដែលគាត់មានគុណបំណាច់ទៅនឹងប្រទេសកម្ពុជា។ ដូច្នេះ នេះជាចម្លើយរបស់ខ្ញុំ។ ដូច្នេះហើយ នៅក្នុងឯកសារនេះ គឺយើងមានឃើញហេតុផលពីរនៅក្នុងហ្នឹង ហើយមានឃើញហេតុផលអ្វីដែលគេបានសម្រេច និងធ្វើឡើងនៅពេលនោះ។

[១៥:៣១:១៨]

**សៈ** សូមអរគុណលោកសាស្ត្រាចារ្យ។ ឥឡូវនេះ យើងចូលទៅប្រធានបទមួយទៀត ជាប្រធានបទដែលនិយាយអំពីនយោបាយដែលគេបានលើកឡើង ដែលគេសំដៅកម្ទេចខ្មាំងរបស់បក្ស ហើយផ្នែកនេះ ដែលយើងនិយាយជាលម្អិតទៅទាក់ទងទៅនឹងមន្ទីរ ស-២១ ទោះបីជាមិនផ្នែកនៃសវនាការភាគទីមួយនេះក្តី។ ហើយតុលាការបានណែនាំមិនឲ្យយើងចូលលម្អិតទៅក្នុងព័ត៌មានជាក់លាក់ទេ។ ហើយយើងនឹងសង្កត់ធ្ងន់ទៅលើនយោបាយ ហើយនិងស្វែងរកមើលភាសាដែលគេប្រើក្នុងការអនុវត្តគោលនយោបាយ។

ជាសេចក្តីផ្តើមទូទៅ ទាក់ទងទៅនឹងលំដាប់លំដោយដែលត្រូវចាប់ផ្តើម តើលោកនៅក្នុងរយៈពេលពីរមីនុត ឬតិចជាងនេះ អាចរៀបរាប់អំពីដំណើរការបង្កើត ស-២១ ដែរឬទេ? ផ្អែកលើការសិក្សាស្រាវជ្រាវរបស់លោកអំពីការបង្កើត ស-២១ នេះ។ ជាសេចក្តីអធិប្បាយជាមូលដ្ឋានសង្ខេបបាទ។

**ឆៈ** ស្ថាប័នដែលគេហៅ ស-២១ នេះ ត្រូវបានបង្កើតពីដំបូងនៃរបបនេះ។ ខ្ញុំមិនចាំខែច្បាស់ទេ ប្រហែលជានៅក្នុងចុងឆ្នាំ១៩៧៥ នៅពេលដែលស្ថិតនៅក្នុងមន្ទីរពេទ្យឆ្កួតតាខ្មៅ ហើយជាមន្ទីរនគរបាល ហើយក្រោយមក គឺគេសម្រេច ហើយមានឯកសារមួយចំនួនបាត់បង់ ពីកន្លែងហ្នឹង ហើយយើងមិនអាចរកតាមដាន ថាតើគេកម្ទេចនរណាខ្លះ ជាអតីតសមាជិក លន់ នល់ ហើយប្រហែលជាបរទេស ហើយជនជាតិភាគតិចនោះផងដែរ ដែលគេចោទថា ជាជនក្បត់ពីដំបូងនោះ។ ប៉ុន្តែវាមិនមានលក្ខណៈជាប្រព័ន្ធទេ កំណត់ហេតុមិនបានរក្សាទុកជាប្រព័ន្ធទេ។ នៅខែមេសា ឆ្នាំ១៩៧៦ ដែលគេៗពិនិត្យឃើញថា អ្នកដែលគេចាប់ផ្តើមនោះ គឺថាគេយល់ថាមានខ្មាំងនៅក្នុងបក្ស ជាពិសេសមកពីភូមិភាគបូព៌ា ដែលជាអ្នកទទួលខុសត្រូវអំពីការបោកគ្រាប់បែកនៅក្នុងភ្នំពេញ។ ហើយភ្លាមៗបន្ទាប់ពីនោះ កាំង ហ្កេកអ៊ាវ ហៅ ឌុច បានកាន់កាប់នៅទីតាំងមួយ គឺជាវិទ្យាល័យទួលស្លែង គឺដែលថាឥឡូវនេះ ជាបង្កើតឡើងនៅក្នុងខែឧសភា ឆ្នាំ៧៥នោះ។

[១៥:៣៤:១៣]

ឥឡូវនេះ គឺថាគេមានដើម្បីសួរចម្លើយ ប៉ុន្តែយើងមិនច្បាស់ថាជាពិតទេ ប៉ុន្តែពីដំបូងនោះ ស-២១ នោះ គឺដែលកើតនៅទួលស្លែងនោះ សម្រាប់សួរចម្លើយនៅក្នុងករណីភាគច្រើន គឺធ្វើទារុណកម្ម ហើយក្នុងករណីទាំងអស់ ឬក៏មួយចំនួននោះ គឺត្រូវសម្លាប់ជនរងគ្រោះ។

**សៈ** សូមអរគុណ។ ខ្ញុំមានសំណួរពីរបីទៀតទាក់ទងទៅនឹង -- បាទ មិនចូលលម្អិតទេ គ្រាន់តែជាព័ត៌មានមូលដ្ឋាន។ ក្រៅពីទីតាំងដែលលោកបានរៀបរាប់នៅក្នុងភ្នំពេញ ថាតើស្ថាប័ននេះបានប្រើ

ទីតាំងណាផ្សេងទៀតដែរឬទេ?

**ឆ៖** នេះជាកន្លែងមួយដែលថា ប្រើលេខ មានទីតាំងមួយទៀតហៅ "ព្រៃស" ដែលហៅថា "ស-២៤" ជាមណ្ឌលអប់រំកែប្រែដែលថា គេបញ្ជូនចេញពីស-២១ ទៅទីនោះ។ ហើយចំពោះអ្នកដែលគេបញ្ជូនមកស-២១ គឺអ្នកទោសធ្ងន់ រីឯព្រៃស គឺមិនសម្រាប់អ្នកទោសធ្ងន់ទេ ជាអ្នកទោសនយោបាយដែលស្ថិតនៅក្នុងរបប លន់ នល់។ ប៉ុន្តែចំពោះនៅវិទ្យាល័យទួលស្លែងដែលគេប្រើមន្ទីរស-២១ សម្រាប់អ្នកទោសធ្ងន់នោះបាទ។

[១៥:៣៦:០៥]

**ស៖** ពិនិត្យមើលសៀវភៅរបស់លោក ដែលនិយាយអំពីទីតាំងដែលសៀវភៅនិយាយពីស -- "សំឡេងពីស-២១" នេះ។ ឯកសារ D នោះគឺ D108/50/1.4.6 លោកបានពិភាក្សាចំណុចមួយចំនួនបាទ គឺអំពីការសម្រេចបង្កើតនូវទីតាំង ឬកន្លែងនេះ ខ្មែរ ERN គឺ 00191845 រហូតទៅដល់ 46, អង់គ្លេស ERN 00192693 រហូតទៅដល់ 94, បារាំង ERN 00357277 រហូតទៅដល់ 78។ សូមអនុញ្ញាតប្រគល់ច្បាប់លើឯក -- លើក្រដាសជូនលោកសាស្ត្រាចារ្យ ហើយសូមអនុញ្ញាតបង្ហាញអត្ថបទភាសាខ្មែរនៅលើអេក្រង់ផងដែរ សម្រាប់ឲ្យសាធារណជន ហើយនិងភាគីដែលអានភាសាខ្មែរលោកតាមដានបាន។

នៅក្នុងផ្នែកនេះ លោកសាស្ត្រាចារ្យ ឆេនដ័ល័រ លោកបាននិយាយដូចខាងក្រោមនេះ៖ "ប្រទេសត្រូវបានកាន់កាប់ដោយមេដឹកនាំមួយក្តាប់តូច អ្នកខ្លះជាអតីតគ្រូបង្រៀន សាស្ត្រាចារ្យដែលធ្វើការងារជាយូរ ដើម្បីដាក់ទណ្ឌកម្ម ហើយនិងតាមដានលើមនុស្សដែលគេត្រួតត្រា។ កម្មាភិបាលដែលទទួលបន្ទុក ស-២១ គឺស្ថិតនៅក្រោមការតាមដានរបស់មជ្ឈិមបក្ស ដែលហៅថា "មជ្ឈិមបក្ស"។ ហើយបានលាក់កំបាំងជាសមាជិករបស់កងវរសេនាតូច ហើយនៅខាងក្រោមនេះនៅក្នុងអត្ថបទដដែលនេះគឺមានខ្លឹមសារ និងប្រយោគដូចតទៅនេះ "បេសកកម្មរបស់មន្ទីរនេះ គឺការពារមជ្ឈិមបក្ស។ មួយផ្នែកគឺត្រូវសម្លាប់អ្នកទោសទាំងអស់ ហើយមួយផ្នែកទៀតដោយការប្តូរជីវប្រវត្តិផ្ទាល់ខ្លួនរបស់អ្នកទោសទាំងនោះដើម្បីឆ្លើយតបទៅតាមតម្រូវការ និងការសង្ស័យរបស់បក្ស"។

[១៥:៣៨:៥២]

សាស្ត្រាចារ្យ ខ្ញុំចង់សួរលោកឲ្យពន្យល់ ផ្អែកលើការសន្និដ្ឋានរបស់លោកគឺថា ជាបេសកកម្មរបស់មន្ទីរគឺដើម្បីការពារមជ្ឈិមបក្ស។ ថាតើលោកផ្អែកលើអ្វីបានជាទាញសេចក្តីសន្និដ្ឋានបែបនេះ? តើ

លោក -- តើអ្វីជាបេសកកម្មសំខាន់របស់មន្ទីរនេះ?

**ឆ៖** ខ្ញុំមិនប្រាកដពីសំណួរចុងក្រោយ ប៉ុន្តែតើបេសកកម្មនោះលោកមានន័យថាម៉េច?

**ស៖** សូមអភ័យទោស ខ្ញុំថាតើៗចំណុច -- តើអ្វីដែលនាំឲ្យលោកកំណត់ថា ជាបេសកកម្ម? ឬក៏លោកផ្អែកលើចំណុចណា? ឯកសារអីដើម្បីឲ្យសន្និដ្ឋានបែបនេះ? ហើយបើសិនបើស្នើសុំឲ្យលោកឆ្លើយឲ្យបានយឺតៗ ផងដែរ។

**ឆ៖** ខ្ញុំឃើញថា បេសកកម្មនេះ គឺថាបង្ហាញឲ្យឃើញគឺថា ឌុច ជាអ្នកអនុវត្តដែលថា គាត់មានការងារពីមុន ពីអមលាំង ជាមន្ទីរមួយនៅក្នុងសម័យសង្គ្រាមស៊ីវិល ដើម្បីការពារមជ្ឈិមបក្ស ដើម្បីកំណត់ ដើម្បីបោសសម្អាត ជាពាក្យខ្មែរសម្រាប់ការកម្ទេច នោះគឺថាធ្វើម៉េចកុំឲ្យមានអ្នកជំទាស់នោះ។ ការបោសសម្អាត គឺថាអ្នកប្រឆាំងពិតប្រាកដ ប៉ុន្តែពិនិត្យចម្លើយសារភាពក្នុងការរកឲ្យឃើញថា តើអ្នកណាជាអ្នកណា? នេះហើយគឺជា -- អ្នកដែលប្រឆាំងនឹងគឺតាមការសន្មតរបស់គេទេ។ ចំណុចដែលខ្ញុំបានបញ្ជាក់ក្នុងសៀវភៅដែលផ្អែកទៅលើការសិក្សារបស់ ស្ទីវ ហេដឌ័រ នោះគឺជាការបំពេញបន្ថែមនូវគោលបំណងនៃទីតាំងនេះ គឺដើម្បីផ្តល់ឲ្យមជ្ឈិមបក្សនូវប្រវត្តិនៃការជំទាស់ អ្នកណាដែលជំទាស់នឹងបក្ស ឬក៏ត្រូវតែកម្ទេច បំបាត់នូវការជំទាស់ទាំងអស់នោះឲ្យអស់។ យើងត្រូវប្រើ -- យើងពិតជាយន្តការមួយដែលប្រតិបត្តិការដើម្បីលុបបំបាត់ ដើម្បីកម្ទេច គឺថាមតិទស្សនៈរបស់អ្នកដែលប្រឆាំងហ្នឹង គឺថា ត្រូវតែអត់មាន។

[១៥:៤១:៣០]

ហើយទស្សនៈរបស់ស-២១ តែងតែមានការគាំទ្រ នេះគឺស្របទៅនឹងបទពិសោធន៍របស់សហភាពសូវៀត នៅក្នុងបក្សកុម្មុយនីស្តរបស់ស្តាលីន គឺថាគេធ្វើយ៉ាងម៉េចដើម្បីវែកមុខ ឬក៏បំបាត់ខ្មាំងចេញពីរបបរបស់គេ។ នេះគឺវាមានលក្ខណៈស្រប ហើយមានសញ្ញាណគឺថា ត្រូវតែការពារគណៈមជ្ឈិម គឺថាត្រូវធ្វើយ៉ាងណាគឺយកខ្មាំង ដែលគេយល់ថាខ្មាំង គឺថាត្រូវយកមកស-២១ ដូចជាករណីសម្តេច សីហនុ គេមិនឲ្យចេញនៅក្រៅកន្លែងដែលគេកំណត់ឲ្យនៅទេ គឺត្រូវតែនៅកន្លែងណាមួយដែលគេកំណត់ឲ្យនោះឯង បើមិនដូច្នោះទេ គេនឹងកម្ទេច។

**ស៖** ដោយពិចារណាទៅលើបេសកកម្មរបស់មន្ទីរនេះ ដូចដែលលោកបានរៀបរាប់ បើយើងពិនិត្យមើលបញ្ហាទាក់ទងទៅនឹងការអប់រំកែប្រែវិញ ដែលយើងបានពិភាក្សាបន្តិចហើយនៅពេលដែលយើងពិនិត្យមើលប្រធានបទពីខាងដើមនោះ តាមទស្សនៈរបស់លោក តើមានទំនាក់ទំនងអ្វីដែរឬទេ បើ

មិនមានលោកឆ្លើយថា មិនមាន រវាងទស្សនទានការអប់រំកែប្រែ ហើយមួយទៀតគឺទស្សនទាននៃការកម្ទេច។ អ៊ីចឹង តើមានការទាក់ទងទេ រវាងការអប់រំកែប្រែ និងការកម្ទេចនេះ?

[១៥:៤៣:០៧]

**ឆ៖** មិនមានមានទំនាក់ទំនងផ្ទាល់ទេ នេះគឺនីតិវិធីពីរដាច់ដោយឡែកពីគ្នា ដែលគេចាត់ទុកថាគេត្រូវយកមកប្រើនៅពេលដែលយើងយកខ្មាំងមកដោះស្រាយនោះ ភស្តុតាងមួយចំនួននោះគឺថា មិនច្បាស់លាស់ ឬក៏វាផ្ទុយគ្នា។ កាលណាគេចាត់ទុកថា នរណាម្នាក់ជាខ្មាំង ជាអ្នកណាម្នាក់សម្រាប់អប់រំកែប្រែ បើមិនមែនជាអ្នកត្រូវដោយសម្លាប់ទេនោះ គឺចំណាត់ការវាខុសៗគ្នា។ នេះជាកន្លែងមួយដែលគេបែងចែកដាច់ស្រឡះពីគំរូប្រទេសចិន។ នេះគឺជាការប៉ុនប៉ង ដើម្បី -- គេមិនចង់ដាក់នយោបាយចិននៅក្នុងស-២១ ទេ។ គេប្រើពេលអប់រំច្រើនជាងនៅក្នុងករណីប្រទេសចិន គេប្រើពេល២០ឆ្នាំ ឬ៣០ឆ្នាំជាដំណើរការ ប៉ុន្តែកម្ពុជាគឺមិនគោរពទៅតាមទម្រង់អប់រំកែប្រែៗនេះទេ ប៉ុន្តែសមាជិកបក្សគឺថា បញ្ជូនទៅការវគ្គសិក្សាកែលម្អ ឱ្យគេទៅជាសមាជិកល្អក្នុងបក្ស។ អានេះបើនិយាយបក្ស។ ប៉ុន្តែគេនិយាយពីការអប់រំកែប្រែ ប៉ុន្តែមិនកើតឡើងនៅស-២១ទេ ពីព្រោះថា បើវាកើតមានប្រហែលជាមានអ្នកគេលែងហើយ។ ប្រហែលជា២៤ ជាដើម ដែលគេអាចនឹងដូចជា អ្នកថតរូប អ្នកជាង គឺថាជាអ្នកថតរូបឱ្យប៉ុល ពត គេអាច អាចនឹងថតទុកតែហ្នឹងជាដើមហ្នឹង គឺថាមិនមានអ្នកណាម្នាក់ត្រូវបានដោះលែងទេនៅស-២១នេះ។

[១៥:៤៤:៥៣]

**ស៖** ហើយផ្តោតអារម្មណ៍ដោយសង្ខេប ទៅលើគំនិតដែលថាគេមិនដោះលែងអ្នកណាម្នាក់នោះទេនោះ។ លោកនិយាយម្សិលមិញថា លោកបានសម្ភាសអ្នករស់រានមានជីវិតពីស-២១ ខ្លះ ដោយផ្អែកលើព័ត៌មាននៅក្នុងព័ត៌មាន ហើយឯកសារដែលលោកបានសម្ភាសនោះ ថាតើមានអ្នករួចរស់រានមានជីវិតប៉ុន្មាននាក់ពីស-២១ តាមដែលលោកដឹង? ប្រសិនជាលោកមិនដឹងច្បាស់ លោកអាចនឹងប្រាប់តុលាការតាមនោះ។

**ឆ៖** ដោយសារថាមានតែប្រហែលជា១០ ឬក៏១២នាក់ ហ្នឹង គឺថាមានកុមារខ្លះ គឺកុមារដែលមកជាមួយអ្នកទោសផ្សេងទៀតត្រូវបានសម្លាប់ ប៉ុន្តែតាមដែលខ្ញុំដឹង ប្រហែលជាមានតែពីរនាក់ទេដែលនៅរស់រានមានជីវិត។ ប៉ុន្តែអ្នកៗរស់រានមានជីវិតនោះ នៅក្នុងឆ្នាំ១៩៧៩ នោះ គឺការដែលកំណត់រកអ្នកទាំងអស់នេះ ដើម្បីផ្តល់ទិន្នន័យថាតើស-២១ ដំណើរការដូចម្តេចនោះ គឺៗត្រូវតែអ្នកទាំងនោះគឺ

បានធ្វើការប្រឆាំងនឹង ប៉ុល ពត ឬមតិប្រឆាំង ប៉ុល ពត ហើយគេកំណត់ថាអ្នកនោះគឺថាគេបាន គេឆ្លើយថា គេបានយកចិត្តទុកដាក់បានល្អ គេឲ្យការងារ ឬក៏ឲ្យជាប្រាក់ខែជាដើម។

[១៥:៤៦:៤២]

**ស៖** បើយើងមើលដោយសង្ខេបទៅលើឯកសារ ដែលនិយាយពីស-២១ តើលោកអាច -- ខ្លឹមសារដោយសង្ខេបអំពីឯកសារទាំងអស់នោះបានដែរឬទេ? និយាយដោយសង្ខេបខ្លី។

**ឆ៖** នោះតាមសមាមាត្រនៃឯកសារនោះវាមានច្រើន ដូចជាចម្លើយសារភាព ឯកសារទាំងនេះគឺមានគួរឲ្យចាប់អារម្មណ៍ណាស់ដោយថា ដើម្បីយើងចង់ដឹងសំឡេងដែលចេញពីមន្ទីរនេះ ហើយនិងប្រើជាភស្តុតាងបង្ហាញ គឺថាដូចជាប្រវត្តិរូបដែលថាអាចនឹងបញ្ជាក់ ប៉ុន្តែឯកសារហ្នឹងគឺថាសំខាន់សម្រាប់ការវិភាគ គឺថាឯកសាររដ្ឋបាលនៅក្នុងគុកនេះ ហើយនិងសៀវភៅណែនាំ ហើយនិងការងារនយោបាយដែលត្រូវធ្វើជាមួយអ្នកទោស ដូចក្នុងការសួរចម្លើយ វគ្គសិក្សាដែលកម្មាភិបាលនៅស-២១ បានរក្សាទុកនៅស-២១ នេះ។ ខ្ញុំប្រើពាក្យថា ចម្លើយសារភាពរបស់សមាជិកបុគ្គលិកស-២១ ខ្លះ ដែលគេចាប់ដែលនោះ ហើយបង្ហាញថាជាការកុហក គឺថាដូចជាអ្នកយាមក៏ត្រូវបានគេចាប់ខ្លួនដោយសារប្រព្រឹត្តកំហុសនោះ កាលណាៗចម្លើយសារភាពនោះ គាត់និយាយថាមានកំហុសនោះ គាត់ប្រើទីកន្លែងនោះ គឺថាជាចម្លើយសារភាពរបស់អតីតបុគ្គលិកហ្នឹងក៏មានដែរ។

[១៥:៤៨:៣៨]

ឥឡូវនេះ អ្វីដែលយើងឃើញនោះ គឺកំណត់ហេតុប្រចាំថ្ងៃរបស់អ្នកសួរចម្លើយនោះ គឺសំខាន់ណាស់ ខ្ញុំបានប្រើភាគច្រើន ដែលផ្ដល់ឲ្យយើងនូវពន្លឺមួយ ពីរបៀបដែលគេធ្វើការងារ ដែលគេយល់ពីការងារ ដែលគេយល់ពីបដិវត្តន៍ ហើយនិងការប្ដេជ្ញាដែលគេបានធ្វើការងាររបស់គេ ហើយនិងការ -- ព័ត៌មានទាំងនេះនៅក្នុងសំណុំរឿងនោះ គឺជាក្រុមមនុស្សដែលធ្វើពលិកម្មចំពោះការងារណាស់ ទោះបីជាការងាររបស់គេគួរឲ្យក្តី -- បង្កនូវក្តីរន្ធត់ក៏ដោយ ប៉ុន្តែគឺការងារគេធ្វើការម៉ឺងម៉ាត់ដើម្បីបោសសម្អាតឲ្យស្អាត គឺថាលុបបំបាត់នូវខ្មាំងឲ្យអស់ពីប្រទេស -- ប្រទេសនៅខាងកំពូលនោះ គឺថាជា គឺមានគុកផ្សេងៗទៀតនៅក្នុងប្រទេសហ្នឹង គឺថាសេចក្តីសម្រេចនោះ គឺថា -- ហើយកម្មាភិបាលបក្សមិនត្រួតត្រាផ្ទាល់ទៅលើមន្ទីរសន្តិសុខផ្សេងៗទេ លើកលែងតែស-២១។ ហើយនៅពេលដែលស-២១ នេះគឺទទួលអ្នកទោស ដូចជាកម្មាភិបាល អតីតមន្ត្រីជាន់ខ្ពស់ជាដើម។

[១៥:៥០:០៣]

**ស៖** ឥឡូវនេះ គឺមិនផ្តោតអារម្មណ៍ការងារប្រចាំថ្ងៃរបស់គុកនោះទេ ប៉ុន្តែឥឡូវនេះខ្ញុំនឹងចូលទៅដល់សេចក្តីលម្អិតទៅលើឯកសារអ្វី លើសពីអ្វីចង់សួរលោកតែមួយសំណួរទៀត។ លោកនិយាយថាលោកបានពិនិត្យមើលចម្លើយសារភាព តើលោកអាចរៀបរាប់ប្រាប់តុលាការទេ តើឯកសារហ្នឹងវាមានទ្រង់ទ្រាយដូចម្តេច វាមានផ្នែកដាច់ដោយឡែក ឬក៏គេសរសេរដោយផ្ទាល់ដៃ ឬក៏ជាអង្គុលីលេខ ឬក៏ឯកសារហ្នឹងវែង ឬខ្លីយ៉ាងដូចម្តេច?

**ឆ៖** ប្រហែលជាខ្ញុំមានតួលេខហ្នឹង ប្រហែលជា៣.៨០០ ហើយ១០០ទៀត នៅឃើញកន្លែងផ្សេងអីចឹង។ ហើយគេនិយាយថា ជាច្រើនឆ្នាំហើយ គឺថាអ្នកទោសប្រហែល១៤.០០០នាក់។ អីចឹងហើយគឺថា អីចឹងហើយ ចម្លើយសារភាពប្រហែល១៤.០០០។ អីចឹងហើយគឺ មានអ្នកខ្លះមិនមានចម្លើយសារភាពនោះទេ នៅពេលដែលគេដឹកអ្នកទោសតាមឡានមក គឺបញ្ជូនចេញភ្លាមជាដើម។ គឺថាវាមានលទ្ធភាពបី។ ទីពីរ ចម្លើយសារភាពគឺមិន -- រកមិនបានឃើញ -- មិនបានរកឃើញទេ គឺបាត់បង់គឺនៅក្នុងឆ្នាំ១៩៧៩នោះ គឺថាមួយចំនួនទៀត គឺថាចម្លើយសារភាពខ្លះគឺថារបស់ជនជាតិវៀតណាម គឺថានៅពេលដែលគេពិនិត្យមើលចម្លើយសារភាពនេះ វៀតណាមថាតើមានអ្វីកើតឡើង។ ហើយខ្ញុំថា -- ប៉ុន្តែគេរកឃើញចម្លើយសារភាពនៅពេលនោះ ប៉ុន្តែគឺយើងឃើញថា៤.០០០ កម្មាភិបាលជាន់ខ្ពស់ គឺថាមានចម្លើយសារភាពវែង គឺថា៣០០ ទៅ៤០០ទំព័រឯណោះ ចំពោះយុទ្ធជនតូចតាចវិញ គឺថាសរសេរផ្ទាល់ដៃទេ គឺដោយជនរងគ្រោះខ្លួនឯង គឺថាពេលខ្លះ គឺថាមានវាយអង្គុលីលេខដែរដោយសង្ខេបទៀត។ ពេលខ្លះគឺខ្លឹមសារហាក់ដូចជាការក្លែងទេ ការបង្កើតនោះ។

[១៥:៥២:២៥]

ខ្ញុំមើលកថាខណ្ឌនៅក្នុងចម្លើយសារភាពផ្សេងៗ គឺថាដូចគ្នាបេះបិទ នោះគ្រាន់តែវាយចម្លងចម្លើយសារភាពរបស់ទាហាន គឺដូចៗគ្នា គឺថាគ្រាន់តែដាក់បញ្ចូល ហើយបញ្ជូនចេញ។ ប៉ុន្តែយើងឃើញថា យើងមាន*ហ្វូតណូត* មួយសំខាន់ លេខយោងនោះ គឺថាជាការចង្អុលបង្ហាញបក្សកុម្មុយនីស្តកម្ពុជា យើងមិនឃើញមាន -- មិនឃើញមានកំហុសទេ។ គឺថាការវាយអង្គុយលីលេខនោះ គឺថាវាយបានត្រឹមត្រូវ ពីព្រោះថាគឺវាយអង្គុលីលេខដ៏ត្រឹមត្រូវ គឺថារៀបចំយ៉ាងត្រឹមត្រូវ បើថាវាយខុសមួយអាហ្នឹងគឺថាមានកំហុស មានទោសអាហ្នឹង។ ដូច្នេះ យើងឃើញថាឯកសារជាច្រើនដែលថាអ្នកទាំងអស់នោះ មិនដឹងថាមានរឿងអ្វីកើតឡើងទេ។ ដូច្នេះហើយ គេព្យាយាមសរសេរៗ ដើម្បីបានរស់។ ហើយប៉ុន្តែគាត់មិនបានដឹង -- ហើយខ្ញុំដឹងថាអ្នកទាំងអស់នេះ គឺនៅពេលក្រោយត្រូវបានគេសម្លាប់។

នេះគឺជាការសិក្សាមួយដែលឃើញនូវក្ដីរន្ធត់ ដែលខ្ញុំមិនអាចនិយាយបាន។

[១៥:៥៣:៣៨]

**ស៖** ហើយសូមអរគុណដែលលោកបានឆ្លើយសំណួរលម្អិតនេះ ដោយមានសេចក្ដីរៀបរាប់អំពីទម្រង់ ជាជាងអំពីរចនាសម្ព័ន្ធនៃចម្លើយសារភាព ថាតើមានទម្រង់អីជាគំរូផ្លូវការដែរឬទេ?

**ឆ៖** គេចាប់ផ្ដើមឡើងដោយប្រវត្តិរូប ហើយបន្ទាប់មកគឺនិយាយពីអង្គហេតុ ហើយបន្ទាប់មកក៏មាននិយាយអំពីទីកន្លែងកំណើត វណ្ណភាពដើម ទំនាក់ទំនង ហើយប្រវត្តិសកម្មភាពនៅក្នុងបក្ស។ បន្ទាប់មកទៀត គេនិយាយជាទូទៅដូចគ្នាទាំងអស់នៅក្នុងប្រវត្តិរូបមួយៗហ្នឹង។ ដូចជាបុគ្គលិកត្រូវតែគោរពតាមទម្រង់បែបបទនេះ នៅក្នុងប្រវត្តិរូបដែលគេត្រូវបង្ហាញទៅថ្នាក់លើរបស់គេ។ ហើយបន្ទាប់មក គេនិយាយចំណុចពីរ។ មួយគឺថា ប្រវត្តិសកម្មភាពក្បត់របស់ខ្ញុំ។ អានេះគឺជាចម្លើយសារភាពដែលគេសារភាពថា ធ្វើអី ឬក៏បានប្រព្រឹត្តខុសអ្វីៗ។ ខ្ញុំបានធ្វើ*កាតាឡុក* ក្នុងសៀវភៅរបស់ខ្ញុំ។ គឺថាពេលខ្លះគួរឲ្យចម្លែកណាស់មើលទៅ។ កន្លែងខ្លះក៏គេសារភាពតែរឿងមិនពិតទាល់តែសោះក៏មានដែរ។ អ៊ីចឹងហើយគឺថា គឺបន្ទាប់មកគេបានដាក់បញ្ជីអ្នកដែលពាក់ព័ន្ធ គឺថាគេហៅថាខ្សែវែង ខ្សែដែលជាប់ជាមួយគាត់នោះ គឺអ្នកនោះគឺថាគ្រាន់តែ -- ជនរងគ្រោះគ្រាន់តែនឹកឃើញតែឈ្មោះអ្នកណាដែលខ្លួនស្គាល់ដាក់ទាំងអស់ ទោះបីពិតមិនពិតក៏ដោយ។ ចំពោះអ្នកទោសណាដែលគេនាំមក ស-២១ ដោយសារមានកំហុស ហើយត្រូវតែឆ្លើយទៅអ្នកផ្សេង គឺថាត្រូវឆ្លើយ -- មានចម្លើយសារភាពឆ្លើយបី គឺត្រូវទៅរកអ្នកហ្នឹងហើយ។ បើសិនជាមានមនុស្សបីនាក់ អ្នកទោសបីនាក់ឆ្លើយដាក់មនុស្សតែម្នាក់ គេត្រូវទៅរកអ្នកហ្នឹងហើយ។ អ៊ីចឹងហើយគឺថា ការការពារមជ្ឈិមបក្សនោះគឺថា ទំហំអ្នកទោសដែលគេឆ្លើយដាក់ហ្នឹង កាន់តែច្រើនទៅៗ។ នេះហើយជាទម្រង់ដែលមានលក្ខណៈជាស្ដង់ដារ។

[១៥:៥៥:៥៥]

ជាញឹកញាប់នោះគឺថា ដូចជា វន វ៉េត, កុយ ធួន ជាដើមនោះ គេឆ្លើយ -- សួរចម្លើយហ្នឹងវែង ហើយចម្លើយសារភាពហ្នឹង គឺដាក់មួយកន្លែងសិន ហើយឥឡូវនេះគឺថា ឥឡូវនេះឲ្យប្រាប់ការពិត ហើយអ៊ីចឹងសរសេររឿងមួយផ្សេងទៀត ដែលគិតថា អាចនឹងបំពេញទៅតាមលក្ខខណ្ឌតម្រូវ។ ពេលនោះគេប្រាប់ថា អត់ទេ កុំសរសេរបែបនេះ ឥឡូវសរសេរពីទំព័រខុសពីហ្នឹង។ អ៊ីចឹងគឺអ្នកសួរចម្លើយគេមានសិទ្ធិធ្វើបែបហ្នឹង ដើម្បីធ្វើយ៉ាងណាគេចង់ឲ្យបានការពិត ប៉ុន្តែខ្ញុំឃើញថា ឯកសារចេញពីបុគ្គលម្នាក់មកគឺថា គឺគ្មានអត្ថន័យអី អ្នកសរសេរក៏មិនដឹងថាការពិត ឬមិនពិតផងពេលនោះ អ្នកសរសេរនោះ។

[១៥:៥៦:៤៤]

**ស៖** សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះដល់ពេលសមល្មមនឹងសម្រាកហើយ ប៉ុន្តែដោយអង្គជំនុំជម្រះត្រូវពិភាក្សាជាមួយនឹងភាគីពាក់ព័ន្ធនឹងពេលវេលា ដែលត្រូវដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ័ល័រ ហើយម្យ៉ាងទៀតកត់សម្គាល់ឃើញថា លោកសាស្ត្រាចារ្យដេវីដ ឆេនដ័ល័រ ដែលជាអ្នកជំនាញបានខិតខំប្រឹងប្រែងផ្តល់សក្ខីកម្មឆ្លើយតបនឹងសំណួរជាច្រើន ឃើញថានឿយហត់ ដើម្បីរំដោះស្ថានភាពឲ្យធូរស្រាលហ្នឹង អង្គជំនុំជម្រះអនុញ្ញាតឲ្យលោកសាស្ត្រាហ្នឹង ជាអ្នកជំនាញហ្នឹងសម្រាកមុន។ ហើយអង្គជំនុំជម្រះសូមជម្រាបដែរថា ការស្តាប់សក្ខីកម្មអ្នកជំនាញគឺមិនទាន់ចប់នៅឡើយទេ សវនាការត្រូវបន្តធ្វើនៅថ្ងៃស្អែកទៀត។ ដូច្នេះអង្គជំនុំជម្រះសូមអញ្ជើញលោកមកបន្តផ្តល់សក្ខីកម្មនៅថ្ងៃស្អែកទៀត គឺថ្ងៃសុក្រទី២០ ខែកក្កដា ឆ្នាំ២០១២។

ហើយមន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី អ្នកជំនាញ ក្នុងការជូនអ្នកជំនាញវិលត្រឡប់ទៅទីកន្លែងដែលគាត់ស្នាក់នៅ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់កន្លែងផ្តល់សក្ខីកម្មវិញ នៅក្នុងបន្ទប់សវនាការនេះ នៅព្រឹកថ្ងៃស្អែកនៅវេលាម៉ោងប្រាំបួន។

[១៥:៥៨:៣៨]

លោកសាស្ត្រាចារ្យអញ្ជើញទៅចុះ! ព្រោះខាងអង្គជំនុំជម្រះនឹងបន្តកិច្ចការ មិនមែនជាការដេញដោលទេ គឺជាពិភាក្សាអំពីពេលវេលា ដើម្បីកំណត់ឲ្យបានច្បាស់លាស់ក្នុងការតាំងសំណួរដេញដោលចំពោះលោកសាស្ត្រាចារ្យនាពេលចាប់ពីថ្ងៃស្អែកទៅនេះ។ អញ្ជើញចុះបាទ! ទៅចុះ! មានការអី?

**លោក អាប់ឌុលឡាក់ ថាវីក៖**

សូមអភ័យទោសចំពោះការរំខាននេះ ដោយហេតុថា យើងនឹងចង់ឲ្យលោក ឆេនដ័ល័រ ចេញទៅនោះ។ ខ្ញុំចង់ធ្វើសំណើពីរទាក់ទងទៅនឹងឯកសារ ខ្ញុំចង់ឲ្យគាត់ពិនិត្យសម្រាប់ថ្ងៃស្អែកនោះ ដើម្បីធានាថាភាគីទាំងអស់បានត្រៀមរៀបចំ។ ខ្ញុំសូមអនុញ្ញាតលោកសាស្ត្រាចារ្យសូមលោក ដែលលោកអាចធ្វើបាននោះ គឺពិនិត្យមើលចំណារផ្ទាល់ដៃទៅលើមួយចំនួន ដែលទាក់ទងទៅនឹងឯកសារមួយចំនួន។ ហើយបើសិនជាលោកអាចដឹងប្រភព ឬក៏ឋានៈរបស់លោក ខៀវ សំផន ទាក់ទងទៅនឹងគណៈមជ្ឈិមនូវបញ្ហាដែលយើងបានដែលយើងបានពិភាក្សានេះ តើលោកអាចរកប្រភពនឹកឃើញដែរទេ។ សូម

អភ័យទោសលោកប្រធានបាទ អ៊ីចឹងយើងដើម្បីឲ្យគាត់អាចនឹងតាមដាន ឬក៏អាចនឹងធ្វើការបាន។ សូមអភ័យទោស។

**ប្រធានអង្គជំនុំ៖**

ចប់ហើយលោកសាស្ត្រាចារ្យ សូមអញ្ជើញទៅចុះ។

ជាបន្តអង្គជំនុំជម្រះសុំសួរទៅតំណាងសហព្រះរាជអាជ្ញាថា តើលោកត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីអ្នកជំនាញ សាស្ត្រាចារ្យ ដេវីដ ឆេនដ៍ល័រ នេះ?

[១៦:០១:០១]

**លោក អាប់ឌុលឡាក់ ថារីក៖**

លោកប្រធាន ខ្ញុំជឿថាយើងត្រូវការពីចន្លោះមួយម៉ោងកន្លះ ទៅ ពីរម៉ោងសម្រាប់ថ្ងៃស្អែក។ ខ្ញុំរីករាយនឹងបញ្ចប់ត្រឹម២ម៉ោង តិចជាង ២ម៉ោងនៅថ្ងៃស្អែក។ ខ្ញុំគិតថា ១ម៉ោងកន្លះទៅ ២ម៉ោង ប្រសិនបើផ្តល់ជូនយើងខ្ញុំបាននោះ គឺយើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ចុះខាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី?

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំសូមអរគុណ។ ខ្ញុំសូម ៥ម៉ោង ប៉ុន្តែតាមពិតទៅ បើសិនជា ៣ម៉ោងទៅ ៣ម៉ោងកន្លះហ្នឹង ជាការគ្រប់គ្រាន់ហើយ។ សូមអរគុណលោកប្រធាន។ ខ្ញុំគិតថារយៈពេល ៣ម៉ោង ទៅ ៣ម៉ោងកន្លះនេះជារយៈពេលអប្បបរមា។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ក្រោយពីបានស្តាប់នូវសំណើសុំរបស់ភាគីទាំងពីរ គឺតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី អង្គជំនុំជម្រះសម្រេចផ្តល់ឲ្យនូវពេលវេលាសម្រាប់តំណាងសហព្រះរាជអាជ្ញា គឺមួយពេលដំបូង គឺចាប់ពីពេលចាប់ផ្តើមរហូតដល់ពេលឈប់សម្រាក។ ហើយនៅសល់ប៉ុន្មាននឹងផ្តល់វេទិកាជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ដោយហេតុថា យើងចាប់ផ្តើមពីរថ្ងៃកន្លងមកនេះ ឃើញថាមានបញ្ហាជាច្រើនដែលយើងដោះស្រាយដំបូងៗនៃពេលព្រឹកព្រលឹមចាប់ផ្តើមនោះឃើញថា អស់ពេលវេលាជាច្រើន ដូចព្រឹកមិញនេះអស់ពេល១ម៉ោងឯណោះ ហើយថ្ងៃដំបូងយើងអស់ច្រើនជាងហ្នឹងទៅទៀត។ អ៊ីចឹងហើយបានជាការ

ស្នើសុំនេះគឺសមរម្យ អង្គជំនុំជម្រះសម្រេចដូច្នេះ។

បាទ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះគឺដល់ពេលសមល្មមសម្រាកហើយ ហើយអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃសុក្រ ទី២០ ខែកក្កដា ឆ្នាំ២០១២ ដោយចាប់ផ្តើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនឹងបន្តធ្វើដោយការតាំងសំណួរដេញដោលចំពោះអ្នកជំនាញ ដេវីដ ឆេនដ៍ល័រ ដោយតំណាងសហព្រះរាជអាជ្ញា ហើយនិងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ សូមភាគី និងសាធារណជនជ្រាប។

[១៦:០៣:៤៤]

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងនាំឲ្យខ្លួនពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ សូមអញ្ជើញលោក!

**លោក ម៉ៃខល កាណាវាស៖**

សូមបំភ្លឺថា ខ្ញុំឃើញថាដើមបណ្តឹងរដ្ឋប្បវេណីមានពេលតែ គឺពេលមួយព្រឹក មិនមែនពេលល្ងាចទេ តាមដែលខ្ញុំស្តាប់តាមការបកប្រែទៅជាអង់គ្លេស។ ដូច្នេះ ខ្ញុំគិតថាមានន័យថានៅសល់ពីព្រះអាជ្ញាទាំងអស់ទៅបានដើមបណ្តឹងរដ្ឋប្បវេណីដែរឬទេ? អ៊ីចឹងសូមការបំភ្លឺសម្រាប់ថ្ងៃស្អែកនេះ។

**ប្រធានអង្គជំនុំ៖**

នៅក្នុងថ្ងៃស្អែកគឺមានភាគីពីរដែលតាំងសំណួរទីមួយគឺ តំណាងសហព្រះរាជអាជ្ញា គឺពេលទីមួយនៃពេលព្រឹក ចំណែកឯពេលទីពីរនៃពេលព្រឹក និងពេលល្ងាចជូនទៅក្រុមសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី។ ចំណែកឯមេធាវីការពារក្តី គឺនឹងបន្តចាប់ផ្តើមសួរដេញដោលនៅថ្ងៃចន្ទសប្តាហ៍ក្រោយបាទ៕

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*